UNDP Cambodia

# របាយការណ៍ប្រចាំឆ្នាំ ២០០៨



លើកតំកើងយោបល់ ជម្រើស និងអនាគតប្រកបដោយនិរន្តរភាព

# បុព្វកថា

ខ្ញុំមានសោមនស្សរីករាយក្នុងការបង្ហាញជូនរបាយការណ៍ប្រចាំឆ្នាំ ២០០៨ របស់យើងដែលគូសបញ្ជាក់ពីសមិទ្ធផលរបស់យើង និងបកស្រាយផងដែរអំពីភាពប្រឈមនានាដែលយើងបានជួបប្រទះក្នុងឆ្នាំកន្លងទៅ។

នៅក្នុងខែកក្កដា កម្ពុជាបានចាត់ចែងឱ្យមានការបោះឆ្នោតជាតិលើកទីបួន គិតចាប់ពីឆ្នាំ ១៩៩៣មក ដែលបង្ហាញពីកំណែលម្អលើការចាត់ចែងដំណើរការបោះឆ្នោត និង បង្ហាញពីការថយចុះគួរឱ្យកត់សំគាល់នូវអំពើហឹង្សាខាងនយោបាយ។ ការប្រឈមខ្លះៗនៅតែមាននៅឡើយដូច្នេះប្រការសំខាន់សម្រាប់យើង គឺត្រូវធ្វើការជាមួយគ្នាដើម្បីកែលម្អជាបន្ថែមនូវប្រសិទ្ធិភាព និងតម្លាភាពនៃការបោះឆ្នោតទៅអនាគត។ ទន្ទឹមនឹងនេះ យើងក៏កំពុងធ្វើការដើម្បីជួយធ្វើឱ្យកាន់តែស៊ីជម្រៅផងដែរនូវលទ្ធិប្រជាធិបតេយ្យដោយពង្រឹងសមត្ថភាពរបស់សមាជិកសភាក្នុងការធ្វើជាតំណាងឱ្យប្រជាពលរដ្ឋ តាក់តែងច្បាប់ និងត្រួតពិនិត្យការងារប្រតិបត្តិរបស់រដ្ឋាភិបាល។

នៅខែ ឧសភា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័ត ដែលបើកផ្លូវសម្រាប់ការបោះឆ្នោតនៅថ្នាក់ខេត្ត ក្រុង និងស្រុក។ ក្រុមប្រឹក្សាថ្មីទាំងនេះ នឹងជួយពង្រឹងគណនេយ្យភាព និងនាំយកយោបល់របស់ជនកម្ពុជា ឱ្យកាន់តែខិតមកជិតអ្នកធ្វើសេចក្តីសម្រេចនានា។ អង្គការយូអិនឌីភី បានជួយលើការកសាងគោលនយោបាយនៅថ្នាក់ជាតិ និងបានជួយពង្រឹងដំណើរការគោលនយោបាយ និងសមត្ថភាពនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក។ យើងបានផ្តល់ការគាំទ្រជាមូលនិធិវិនិយោគដែលមានទឹកប្រាក់ចំនួន ៧១ លានដុល្លា ដែលបានមកពីដៃគូផ្តល់ជំនួយចំនួន ១៦ ដើម្បីកែលម្អអភិបាលកិច្ចនៅមូលដ្ឋាន ដែលរួមទាំងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងធនធានធម្មជាតិ និងការពង្រឹងសមត្ថភាពបុគ្គលិក។ យើងក៏បានគាំទ្រផងដែរ ដល់ការអភិវឌ្ឍសមាគមនៃក្រុមប្រឹក្សាឃុំនៅក្នុងខេត្តនីមួយៗ។

ប្រការសំខាន់គឺ យើងបានគាំទ្រដល់ការកសាងគោលនយោបាយ ដែលនឹងកាត់បន្ថយវិសមភាពយេនឌ័រនៅកម្ពុជា។ ក្រុមការងារបញ្ជ្រាបយេនឌ័រ ត្រូវបានបង្កើតឡើងនៅតាមក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ហើយគោលការណ៍ណែនាំនានា ត្រូវបានបង្កើតឡើងដែលទាមទារឱ្យស្ត្រីមានសមាសភាពពី ២០ ទៅ ៥០ភាគរយ នៃចំនួនបុគ្គលិកថ្មីនៅក្នុងចំណោមមន្ត្រីស៊ីវិល។ ដូចគ្នានេះដែរ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា ឆ្នាំ២០០៨ បានផ្តល់ជាបន្ថែមទៀតនូវអនុសាសន៍ផ្នែកគោលនយោបាយដើម្បីកែលម្អគុណភាពយេនឌ័រ នៅក្នុងគ្រប់វិស័យ។

បន្ទាប់ពីវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាកាលពីឆ្នាំទៅ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើការកសាងប្រព័ន្ធសំណាញ់ សុវត្ថិភាពសង្គមចម្រុះរបស់ជាតិមួយ។ គណៈកម្មាធិការមួយត្រូវបានបង្កើតឡើង ដើម្បីធ្វើសារពើភ័ណ្ឌលើបណ្តាញសុវត្ថិភាព សង្គមដែលមានស្រាប់ និងបង្កើតយុទ្ធសាស្ត្រជាតិដើម្បីដោះស្រាយបញ្ហានេះ។ នេះជាប្រការដែលមានសារៈសំខាន់ជាសារវន្តក្នុងពេលដែលការចំណាយរបស់រដ្ឋាភិបាលលើវិស័យសង្គមកិច្ច មានត្រឹមតែ ៣,១ភាគរយ នៃផលទុនក្នុងស្រុកសរុប (GDP) ដែលជាអត្រាទាបជាងគេនៅក្នុងតំបន់នេះ។ អង្គការយូអិនឌីភី គាំទ្រដល់កិច្ចប្រឹងប្រែងរួមគ្នារវាងទីភ្នាក់ងារនានានៃអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ផ្សេងទៀត និងរដ្ឋាភិបាល ដើម្បីធានាឱ្យមានការបង្កើតឡើងនូវប្រព័ន្ធមួយ ដែលមានការពិចារណា ល្អិតល្អន់ត្រឹមត្រូវប្រកបដោយប្រសិទ្ធិភាព និងដែលមានតម្លៃសមល្មម។

អង្គការយូអិនឌីភី បានគ្រប់គ្រងមូលនិធិ ៣៣ លានដុល្លា នៅក្នុងឆ្នាំ ២០០៨ ដែលធ្វើឱ្យកម្ពុជាស្ថិតក្នុងលំដាប់ខ្ពស់ជាងគេទីប្រាំនៃប្រទេសនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ខាងផ្នែកកៀងគរធនធានដោយអង្គការយូអិនឌីភី។ ក្នុងពេលដែលរបៀបវារៈនៃប្រសិទ្ធិភាពជំនួយបានឈានទៅមុខ គេរំពឹងថានឹងមាននិន្នាការមួយឆ្ពោះទៅរកការគាំទ្រជាថវិកាដោយផ្ទាល់ពីម្ចាស់ជំនួយ និងអភិក្រមគ្របដណ្តប់លើវិស័យទាំងមូល។ នេះជាការវិវត្តគួរឱ្យស្វាគមន៍មួយដែលនឹងអនុញ្ញាតឱ្យយូអិនឌីភី ផ្តោតលើការពង្រឹងសមត្ថភាពនៅក្នុងកម្មវិធីគាំទ្រដោយពហុម្ចាស់ជំនួយ។ យើងកំពុងផ្តោតសកម្មភាពរបស់យើងដើម្បីឆ្លុះបញ្ចាំងពីការវិវត្តនេះ។

នៅខែ មីនា យើងបានជួយរដ្ឋាភិបាល នៅក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទអន្តរជាតិកម្ពុជាលើដំបូងមួយ ស្តីពីប្រេងកាត និងឧស្ម័ន។ សន្និសីទនេះបានផ្តួចផ្តើមឱ្យមានការពិភាក្សាអំពីវិធីល្អបំផុតសម្រាប់គ្រប់គ្រងធនធានប្រកបដោយសក្តានុពលមានតម្លៃទាំងនេះដើម្បីផ្តល់ផលប្រយោជន៍ដល់ជនកម្ពុជាគ្រប់រូប។ ការពិភាក្សាដ៏សំខាន់នេះ ដែលគ្របដណ្តប់រាល់ឧស្សាហកម្មនិស្សារណកម្ម រួមទាំងការធ្វើអាជីវកម្មរ៉ែផងដែរនោះ ត្រូវតែបន្តធ្វើទៀត។

កាលពីឆ្នាំទៅ យើងក៏បានឈានដល់ចំណុចកណ្តាលនៃកម្មវិធីរបស់យើងសម្រាប់ប្រទេសនេះ (ឆ្នាំ២០០៦-២០១០)។ យើងបានចាត់ទុកថានេះជាឱកាសមួយដើម្បីឆ្លុះបញ្ចាំង និងបន្ស៊ីការងាររបស់យើង ដើម្បីធានាថា យើងអាចសម្រេចចំណុចដៅរបស់យើង។ ការពិនិត្យមើលដោយឯករាជ្យនៅពាក់កណ្តាលអាណត្តិ បានបង្ហាញថាយើងស្ថិតនៅក្នុងលំនាំល្អសម្រាប់ចំណុចដៅរបស់យើងភាគច្រើន ប៉ុន្តែទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ថែមទៀត លើអន្តរាគមន៍របស់យើង និងផ្តោតលើភាពជាដៃគូ និងការអភិវឌ្ឍសមត្ថភាព។ ការប្រែប្រួលអាកាសធាតុ ត្រូវបានធ្វើអត្តសញ្ញាណថាជាការគំរាមកំហែងចំបងមួយចំពោះកំណើនសេដ្ឋកិច្ចរបស់កម្ពុជាប៉ុន្តែក៏មានការទទួលស្គាល់ផងដែរថា ការគិតគូរទុកជាមុនលើបញ្ហានេះអាចផ្តល់នូវឱកាសច្រើនផងដែរ។ អង្គការយូអិនឌីភី បានផ្តួចផ្តើមឱ្យមានការពិភាក្សានានាអំពីការប្រែប្រួលអាកាសធាតុជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ប៉ុន្តែវិស័យឯកជន និងសង្គមស៊ីវិល ក៏ត្រូវតែដើរតួនាទីផងដែរ។ ការកសាងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធជាច្រើន គឺជាគន្លឹះមួយសម្រាប់ការងាររបស់យូអិនឌីភីនៅក្នុងវិស័យនេះ។

គោលដៅរបស់យើងគឺរក្សាតួនាទីជាដៃគូអភិវឌ្ឍន៍មួយដែលអាចទុកចិត្តបាន មានប្រសិទ្ធិភាព និងដែលអាចពឹងពាក់បាន។ ដោយសម្លឹងមើលទៅខាងមុខ យើងនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល ប្រជាពលរដ្ឋកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់យើងដើម្បីសម្រេចគោលដៅរួមរបស់យើង និងរួមចំណែកទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជារហូតដល់ឆ្នាំ ២០១៥។

*ចូ ស្ក័យើរ*

នាយកប្រចាំនៅកម្ពុជា

*រូបលើក្របក្រៅ : យូអិនឌីភី/អ៊ីសាបែល លេសេរ*

*អ្នកយកព័ត៌មានសម្រាប់កម្មវិធីប្រចាំសប្តាហ៍ស្តីពីសមធម៌ ដែលគាំទ្រដោយយូអិនឌីភី*

*ធ្វើការសម្ភាសពលរដ្ឋមួយរូបសម្រាប់ ទ.ទ.ក អំពីបញ្ហាជីកយកខ្សាច់ ពីផ្លូវទឹកនានានៅកម្ពុជាសម្រាប់ការនាំចេញ។*

# មាតិកា


ទិដ្ឋភាពរួម ឆ្នាំ ២០០៨ ........ ២

តើយើងធ្វើការបែបណា ........ ៣

អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ........ ៤

ការកាត់បន្ថយភាពក្រីក្រ ........ ១៤

បរិស្ថាន និង ថាមពល ........ ២០

ធ្វើការជាមួយគ្នាដើម្បីការអភិវឌ្ឍ ........ ២៦

ធនធានពីម្ចាស់ជំនួយ ........ ២៨

ការចំណាយតាមផ្នែក ........ ២៨

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ........ ២៨

ពាក្យបំព្រួញ និង អក្សរកាត់ ........ ២៩


# ទិន្នន័យសំខាន់ៗអំពីកម្ពុជា

| | |
|---|---|
| ចំនួនប្រជាជននៅឆ្នាំ ២០០៨ | ១៣.៣ លាននាក់[១] |
| អត្រាកំណើនចំនួនប្រជាជនប្រចាំឆ្នាំ ១៩៩០-២០០៧ | ២,៣ភាគរយ[១] |
| ផលទុនក្នុងស្រុកសរុប ឆ្នាំ ២០០៧ | ៨.៣៤០លានដុល្លាអាមេរិក[២] |
| កំណើនផលទុនក្នុងស្រុកប្រចាំឆ្នាំ ជាក់ស្តែងសម្រាប់ឆ្នាំ ២០០៧ | ១០,២ភាគរយ[៣] |
| ចំណូលជាតិដុលក្នុងម្នាក់ៗ ឆ្នាំ ២០០៧ | ៥៤០ ដុល្លាអាមេរិក[៤] |
| ភាពក្រីក្រ (ភាគរយនៃចំនួនប្រជាជនដែលរស់ក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ) ឆ្នាំ ២០០៧ | ៣០,១ភាគរយ[៥] |
| អាយុកាលនៅពេលកើត (បុរស/ស្ត្រី) ឆ្នាំ ២០០៦ | ៥៩/៦៥[៥] |
| អក្ខរភាពក្នុងចំណោមពលរដ្ឋដែលមានអាយុច្រើនជាង ១៥ ឆ្នាំ (បុរស/ស្ត្រី) ឆ្នាំ ២០០៤ | ៨៤,៧ភាគរយ / ៦៤,១ភាគរយ[៧] |
| មរណភាពកុមារ អាយុក្រោម ៥ ឆ្នាំ (ក្នុងកំណើត ១.០០០ នាក់) ឆ្នាំ ២០០៦ | ៨២[៦] |
| អត្រាកុមារស្គមកម្រិតមធ្យម និងធ្ងន់ធ្ងរ (ដែលអាយុក្រោម ៥ ឆ្នាំ) ឆ្នាំ ២០០៥ | ៣៥,៦ភាគរយ[៨] |
| អត្រាមរណភាពមាតា ក្នុងកំណើត ១០០.០០០ នាក់ (រាយការណ៍) ឆ្នាំ ២០០៥ | ៤៧២[៨] |
| អត្រាប៉ាន់ស្មាននៃប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យ (អាយុ ១៥-៤៩) ឆ្នាំ២០០៧ | ០,៩ភាគរយ[៩] |
| ប្រជាពលរដ្ឋដែលប្រើប្រាស់ប្រភពទឹកស្អាត (ទីក្រុង/ជនបទ) ឆ្នាំ ២០០៦ | ៨០ភាគរយ / ៦១ភាគរយ[៦] |
| ជនស៊ីវិលរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ (ប្រចាំឆ្នាំ) ឆ្នាំ ២០០៨ | ២៨៨[១០] |

**១-** វិទ្យាស្ថានជាតិស្ថិតិ ការជម្រើនប្រជាជនកម្ពុជាឆ្នាំ ២០០៨ លទ្ធផលបណ្តោះអាសន្ន www.nis.gov.kh/index.php/statistics/surveys/census2008 **២-** វិទ្យាស្ថានជាតិស្ថិតិ គណនីជាតិកម្ពុជា ខែ មិថុនា ឆ្នាំ ២០០៨ http://www.unicef.org/infobycountry/cambodia_statistics.html **៣-** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ http://www.mef.gov.kh/macroeconomic.php

**៤-** ធនាគារពិភពលោក http://www.unicef.org/infocountry/cambodia_statistics.html **៥-** ការអង្កេតសេដ្ឋកិច្ច-សង្គមនៃកម្ពុជា ឆ្នាំ ២០០៧

**៦-** អង្គការសុខភាពពិភពលោក http://www.who.int/whosis/en/index.html **៧-** អង្គការយូណេស្កូ UNESCO_UIS Database_sep2007

**៨-** ការអង្កេតសុខភាពប្រជាជនកម្ពុជា **៩-** NCHADS (2007) របាយការណ៍នៃសិក្ខាសាលាឯកភាពមតិ : ការប៉ាន់ប្រមាណ និងការព្យាករណ៍អ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ឆ្នាំ ២០០៦-២០១២ **១០-** របាយការណ៍ប្រចាំខែ អំពីជនរងគ្រោះដោយសារគ្រាប់មីន/យុទ្ធភណ្ឌមិនទាន់ផ្ទុះ ខែ ធ្នូ ឆ្នាំ ២០០៨

# ទិដ្ឋភាពរួម ឆ្នាំ ២០០៨



រូបភាព: WCS/អេលេន័រ ប្រ៊ីកស៍

*អង្គការយូអិនឌីភីនៅកម្ពុជាផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍ ដែលផ្តល់ផលដល់អ្នកក្រ តាមរយៈការងារលើផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ការកាត់បន្ថយភាពក្រីក្រ ដោយផ្ទាល់ បរិស្ថាន និង ថាមពល។*

អង្គការយូអិនឌីភី នៅកម្ពុជាបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ នៅក្នុងវិស័យគន្លឹះនានានៅក្នុងឆ្នាំ ២០០៨។ ប្រការដែលលេចធ្លោរួមមានសមិទ្ធផលនៅក្នុងវិស័យបោះឆ្នោត វិមជ្ឈការរបស់រដ្ឋាភិបាល សមភាពរវាងបុរស និងស្ត្រី ពាណិជ្ជកម្មដែលផ្តល់ផលសម្រាប់អ្នកក្រ ប្រសិទ្ធភាពជំនួយ ការប្រែប្រួលអាកាសធាតុ និងការអភិរក្សជីវៈចម្រុះ។

អង្គការយូអិនឌីភី បានធ្វើការគាំទ្រឱ្យមានការបោះឆ្នោតដែលគ្មានអំពើហឹង្សានៅក្នុងការជ្រើសរើសតំណាងរាស្ត្រតាមរយៈការអប់រំ អ្នកពាក់ព័ន្ធនានាធ្វើឱ្យក្រុមអ្នកបោះឆ្នោតដែលតាមធម្មតាទទួលបានការយកចិត្តទុកដាក់តិចតួចបានចូលរួម និងលើកកំពស់ឱ្យមានការជជែកវែកញែកដោយសន្តិវិធីនៅតាមបណ្តាញផ្សព្វផ្សាយព័ត៌មាន និងវេទិកានៃការជួបដោយផ្ទាល់។ វគ្គណែនាំបង្ហាញលើកដំបូងដែលពុំធ្លាប់មានពីមុនមកសម្រាប់សមាជិកសភាត្រូវបានចាត់ចែងឡើង ហើយសិក្ខាសាលា និងទស្សនកិច្ចសិក្សានៅតាមខេត្តនានាបានជួយឱ្យសមាជិកទាំងនោះយល់ដឹងបានកាន់តែច្រើនអំពីបញ្ហាដែលម្ចាស់ឆ្នោតប្រឈម។

វិមជ្ឈការរបស់រដ្ឋាភិបាល បានឈានមួយជំហានយ៉ាងវែងដោយមានការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ យូអិនឌីភី បានផ្តល់យោបល់ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ការធានាលើប្រការផ្សេងទៀតដែលរាប់បញ្ចូលទាំងការគិតគូរអំពីសមភាពរវាងបុរស និងស្ត្រីផងដែរ។ យូអិនឌីភីក៏ផ្តល់យោបល់លើការបង្កើតបទបញ្ញត្តិដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ការបង្កើតរចនាសម្ព័ន្ធថ្មីដើម្បីឱ្យស្ថាប័ននៅថ្នាក់ខេត្ត និងស្រុកអាចផ្តល់ការគាំទ្រដល់រដ្ឋបាលនៅថ្នាក់មូលដ្ឋាន និងកម្មវិធីជាតិរយៈពេល ១០ ឆ្នាំ ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាមូលដ្ឋានខ្លួនឯងបានធ្វើការជាមួយគ្នាដើម្បីពង្រឹងសម្លេងរបស់ខ្លួននៅថ្នាក់ជាតិ ហើយ យូអិនឌីភីបានផ្តល់ទឹកប្រាក់ចំនួន ៧១ លានដុល្លា ដើម្បីកែលម្អអភិបាលកិច្ចនៅមូលដ្ឋានដែលរួមទាំងទឹកប្រាក់ ២៧ លានដុល្លា សម្រាប់អភិវឌ្ឍនហេដ្ឋារចនាសម្ព័ន្ធតាមវិធីដែលលើកកំពស់គណនេយ្យភាពនៃក្រុមប្រឹក្សាទាំងនេះផងដែរ។

ការយល់ដឹងអំពីបញ្ហានានាដែលស្ត្រីនៅក្នុងសង្គមកម្ពុជាកំពុងប្រឈមក៏ត្រូវបានបញ្ចូលនៅក្នុងកំណែទម្រង់របស់រាជរដ្ឋាភិបាលលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនៅក្នុងកម្មវិធីសិក្សានៃសាលាភូមិន្ទរដ្ឋបាលផងដែរ។ សេវាកម្មស៊ីវិលបានអនុម័តគោលការណ៍ណែនាំសម្រាប់ចំណាត់ការជាវិជ្ជមានដែលទាមទារឱ្យមានបុគ្គលិកថ្មីជាស្ត្រី ពី ២០ ទៅ ៥០ភាគរយ។

លទ្ធភាពទទួលបានសេវាកម្មយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានពង្រីកស្របជាមួយការបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ថ្មីៗនៅថ្នាក់ស្រុកចំនួន ១៦ កន្លែង និងគណៈកម្មការឃុំសម្រាប់ដោះស្រាយវិវាទ ចំនួន ៥៦ ថ្មីថែមទៀត។ គោលការណ៍ប្រពៃណីរបស់ជនជាតិដើមភាគតិចត្រូវបានប្រមូលផ្តុំ និងបានផ្សព្វផ្សាយទៅអ្នកតាក់តែងច្បាប់ និងមន្ត្រីយុត្តិធម៌។ វេទិកាថ្មីៗសម្រាប់ដោះស្រាយវិវាទពាក់ព័ន្ធជាមួយជនជាតិដើមភាគតិចដែលគេស្គាល់ផងដែរថា ជាតុសន្តិភាពបានជួយធ្វើឱ្យចំណែកដីដែលមានជម្លោះកំពុងត្រូវបានបង្វែរមកឱ្យសហគមន៍ទាំងនោះវិញ។

អង្គការ យូអិនឌីភី បានគាំទ្រដល់ការកំណត់គោលបំណងនិងផែនការតាមដានមួយសម្រាប់ អភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្មនៃរដ្ឋាភិបាល និងបានជួយវិភាគ និងផ្តល់ជំនាញដែលចាំបាច់សម្រាប់អនុវត្តអភិក្រមនេះ។ ផលិតផល និងសេវាកម្មនានាដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍពាណិជ្ជកម្មត្រូវបានកំណត់អត្តសញ្ញាណ ហើយសមាគមអ្នកផលិតបានក្លាយជាគោលដៅដែលត្រូវទទួលជំនួយគាំទ្រ។

ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កម្ពុជានៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបង្ហាញជូននូវរបាយការណ៍លើកទីពីររបស់កម្ពុជាស្តីពីប្រសិទ្ធភាពជំនួយ។ សន្និសីទអន្តរជាតិមួយស្តីពីសក្តានុពលនៃឧស្សាហកម្មប្រេងកាត និងឧស្ម័នបានផ្តោតលើការជជែកវែកញែកអំពីវិសាលភាពនៃផលចំណូលដើម្បីរួមចំណែកទៅក្នុងការកាត់បន្ថយភាពក្រីក្រ។ ការស្រាវជ្រាវអំពីទិដ្ឋភាពគន្លឹះនានានៃភាពប្រកួតប្រជែងរបស់កម្ពុជាបានធ្វើអត្តសញ្ញាណបញ្ហានានាដែលកំពុងប្រឈមចំពោះឧស្សាហកម្មចំបងៗ នៅចំពោះមុខនៃវិបត្តិហិរញ្ញវត្ថុពិភពលោក។

ផ្ទៃដីទំហំ ៦,៨ គីឡូម៉ែត្រការ៉េ ដែលញាំញីដោយសារគ្រាប់មីន និងសំណល់គ្រឿងផ្ទុះពីសម័យសង្គ្រាមត្រូវបានបោសសំអាត និងប្រគល់ទៅឱ្យសហគមន៍ជនបទជាបន្ថែមទៀត។ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនរងគ្រោះដោយសារមីនបានដាក់ឱ្យអនុវត្តស្តង់ដារថ្មីៗ និងបង្កើនការតាមដានលើសកម្មភាពដោះមីនរបស់ខ្លួន។

ការិយាល័យប្រែប្រួលអាកាសធាតុបានរៀបចំធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងការប៉ាន់ប្រមាណអំពីភាពងាយរងគ្រោះពីការប្រែប្រួលអាសធាតុ។ នៅក្នុងតំបន់ដែលមានជីវៈចម្រុះសំខាន់ៗចំនួនសត្វនៃប្រភេទដែលជិតផុតពូជបំផុត បានកើនឡើងដោយសារមានការកំណត់ព្រំប្រទល់ ការអប់រំការត្រួតពិនិត្យការចូលរួមពាក់ព័ន្ធរបស់សហគមន៍ និងការជម្រុញឱ្យមានជម្រើសជំនួសនៃការចិញ្ចឹមជីវិត។

# តើយើងធ្វើការបែបណា

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ គឺជាទីភ្នាក់ងារមួយក្នុងចំណោមទីភ្នាក់ងារចំនួន ២៣ នៃអង្គការសហប្រជាជាតិ ស្ថាប័នមូលនិធិ និងកម្មវិធីផ្សេងៗទៀត ដែលកំពុងប្រតិបត្តិការនៅកម្ពុជាក្រោមដំបូលនៃប្រព័ន្ធអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាដែលធ្វើការដើម្បីធានាថាសកម្មភាពនានារបស់អង្គការសហប្រជាជាតិផ្តល់នូវការបំពេញបន្ថែមរវាងគ្នាទៅវិញទៅមក និងមិនត្រួតគ្នា។ អង្គការយូអិនឌីភីផ្តោតការយកចិត្តទុកដាក់លើវិស័យការងារជាចំបងចំនួនបីគឺ លើកកំពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ កាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងថាមពល និងបរិស្ថាន សម្រាប់ការអភិវឌ្ឍដោយចីរភាព។ អាទិភាពក្នុងផ្នែកអន្តរវិស័យ គឺការអភិវឌ្ឍសមត្ថភាព ដែលធ្វើការដើម្បីពង្រឹងលទ្ធភាពរបស់បុគ្គល អង្គការ និងសមាគមនានា ដើម្បីសម្រេចបាននូវគោលបំណងនៃការអភិវឌ្ឍរបស់ពួកគេរៀងៗខ្លួន។ នៅក្នុងគ្រប់កិច្ចការរបស់ខ្លួនអង្គការយូអិនឌីភីធ្វើការដើម្បីការពារសិទ្ធិមនុស្ស និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី។

អង្គការយូអិនឌីភី បង្កើតភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អង្គការសហគមន៍ ទីភ្នាក់ងារផ្តល់ជំនួយពហុភាគី ម្ចាស់ជំនួយទ្វេភាគី និងក្រុមហ៊ុនឯកជន។

ប្រមាណ ៨០ ភាគរយនៃជំនួយពី យូអិនឌីភី ត្រូវបានអនុវត្តដោយផ្ទាល់ដោយអង្គភាពជាតិ ដូចជាក្រសួងពាក់ព័ន្ធក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សភា និងមន្ទីរ/ការិយាល័យនានានៅថ្នាក់ក្រោមជាតិ និងអង្គភាពនៅថ្នាក់ខេត្ត ស្រុក និងឃុំ។ ក្នុងករណីខ្លះ យូអិនឌីភីអនុវត្តគម្រោងដោយខ្លួនឯងផ្ទាល់ ដូចជានៅក្នុងការគាំទ្រដល់កំណែទម្រង់ការបោះឆ្នោត និងការដោះមីន។ ការអភិវឌ្ឍសមត្ថភាពត្រូវបានអនុវត្តតាមទម្រង់ជាច្រើន: កំណែទម្រង់ស្ថាប័ន និងយន្តការលើកទឹកចិត្ត ការអភិវឌ្ឍភាពជាអ្នកដឹកនាំ ការអប់រំ ការបណ្តុះបណ្តាល និងការរៀនសូត្រ គណនេយ្យភាព និងយន្តការតស៊ូមតិ។ ទីប្រឹក្សារបស់យូអិនឌីភី ធ្វើការយ៉ាងជិតស្និទ្ធជាមួយសមភាគីកម្ពុជាដើម្បីផ្តល់នូវបង្គុំនៃយោបល់បច្ចេកទេស រៀបចំសន្និសីទ ទស្សនកិច្ចសិក្សា និងការបណ្តុះបណ្តាលជាផ្លូវការក៏ដូចជាការបង្ហាត់បង្រៀន និងការណែនាំផ្ទាល់ផងដែរ។ ជំនាញដែលបានផ្ទេរតាមរយៈដំណើរការទាំងនេះអាចជាកិច្ចការងាយៗ ដូចជា ការរៀបចំកិច្ចប្រជុំ ឬកិច្ចការសាំញ៉ាំ ដូចជាការគ្រប់គ្រងថវិកាជាច្រើនលានដុល្លាសម្រាប់រយៈពេលច្រើនឆ្នាំ។

មូលនិធិនានាបានមកពីប្រភពចំបងៗចំនួនបី: ថវិកាស្នូលរបស់យូអិនឌីភី (ប្រមាណ ៨ លានដុល្លា អាមេរិក ក្នុងមួយឆ្នាំ) ធនធានដែលកៀងគរបានមកពីជំនួយទ្វេភាគី និពហុភាគីនៅក្នុងប្រទេស (២៥-៣០ លានដុល្លា ក្នុងមួយឆ្នាំ) និងធនធានដែលកៀងគរ បានពីមូលនិធិ ពិសេសដូចជាមូលនិធិបរិស្ថានពិភពលោកដែលជាភាពដៃគូពិសេសមួយ ក្នុងការផ្តល់មូលនិធិឱ្យកិច្ចផ្តួចផ្តើមគំនិតខ្នាតតូច សំដៅជួយដោះស្រាយបញ្ហាសាកលនានា ដូចជាការប្រែប្រួលអាកាសធាតុជាដើម និង មូលនិធិ MDG នៃប្រទេសអេស្ប៉ាញ។ លើសពីនេះ យូអិនឌីភី គ្រប់គ្រងមូលនិធិ ដែលបានផ្តល់មកឱ្យជាចំណែករបស់ភាគីកម្ពុជា សម្រាប់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC)។



រូបភាព: យូអិនឌីភី/អ៊ីសាបែល លេសេរ

*បុគ្គលិកយូអិនឌីភី ជួបជាមួយដៃគូនៅមូលដ្ឋាន ក្នុងខេត្តរតនៈគីរី ដើម្បី ពិភាក្សាអំពីការគាំទ្រដល់ផលិតផលជាប្រពៃណីរបស់ជនជាតិដើមភាគតិច។*

នៅឆ្នាំ ២០០៨ អង្គការយូអិនឌីភីនៅកម្ពុជាមានបុគ្គលិកចំនួន ៣៥៧នាក់ (បុគ្គលិកស្នូលប្រចាំកម្មវិធី និងបុគ្គលិកគម្រោង) និងបានជួលទីប្រឹក្សាចំនួន ១១៧ នាក់។ បុគ្គលិកស្នូលមានចំនួន ៩៦នាក់ (បុរស ៦៤ នាក់ និងស្ត្រី ៣២ នាក់)។ ដូចគ្នានេះដែរ អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ បានដើរតួជាទីប្រឹក្សាបច្ចេកទេស និងអ្នកជំនាញឯកទេសក្នុងការគាំទ្រដល់កម្មវិធីរបស់យូអិនឌីភី។ ជាអង្គការមួយនាំមុខដោយចំណេះដឹង យូអិនឌីភី មានការប្តេជ្ញាផ្តល់នូវការរៀនសូត្រជាបន្តបន្ទាប់ និងឱកាសដើម្បីអភិវឌ្ឍន៍មុខរបរ។ បុគ្គលិកមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធរៀនសូត្រគ្រប់គ្រងបែបអេឡិចត្រូនិក ដែលផ្តល់វគ្គរៀនសូត្រចំនួន ៣.០០០ សម្រាប់ប្រធានបទនានាជាភាសាមួយចំនួន។ លើសពីនេះ យូអិនឌីភី មានធ្វើវគ្គសិក្សាប្រចាំសប្តាហ៍ និងឧបត្ថម្ភដល់បុគ្គលិកជាច្រើនក្នុងការសិក្សាជាឯករាជ្យលើមុខវិជ្ជាដែលជាជម្រើសរបស់គេ។

ផ្នែកលទ្ធកម្មនៃយូអិនឌីភីនៅកម្ពុជា បានចុះកិច្ចសន្យាដែលមានទឹកប្រាក់សរុបចំនួន ៧,៥ លានដុល្លា នៅ ក្នុងឆ្នាំ២០០៨។ អ្នកជំនាញការ និងអ្នកឯកទេសពីកម្ពុជា និងពីបរទេស បានចូលរួមនៅក្នុងការផ្តល់សេវាកម្មតាមវិជ្ជាជីវៈ ដើម្បីពង្រឹងសមត្ថភាពជាតិនៅក្នុងការអនុវត្តកម្មវិធី ដែលមានទឹកប្រាក់ប្រមាណ ៤,៥ លានដុល្លា និងត្រូវជា ៦១ភាគរយ នៃការចំណាយលើលទ្ធកម្ម។ យូអិនឌីភីក៏បានសម្របសម្រួលសម្រាប់ការធ្វើលទ្ធកម្ម ក្នុងនាមទីភ្នាក់ងារជាច្រើននៃអង្គការសហប្រជាជាតិផងដែរដែលអនុញ្ញាតឱ្យមានការផ្តល់អាហារូបករណ៍ និងការចូលរួមនៅក្នុងសិក្ខាសាលាក្រៅប្រទេសនៃជនកម្ពុជាចំនួន២៧៤ នាក់។

ឆ្នាំ២០០៨គឺជាឆ្នាំដំបូងដែលការងារគ្រប់គ្រងប្រចាំថ្ងៃពេញមួយឆ្នាំរបស់ យូអិនឌីភី ស្ថិតក្រោមការទទួលខុសត្រូវនៃតំណែងនាយកប្រចាំប្រទេស ជំនួសការចាត់ចែងតាមរយៈអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅក្នុងប្រទេស ដែលអនុញ្ញាតឱ្យអ្នកសម្របសម្រួលក្នុងប្រទេសធ្វើជាតំណាងឱ្យទីភ្នាក់ងារនានានៃអង្គការសហប្រជាជាតិបានស្មើភាពគ្នា។

# អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ



*រូបភាព: យូអិនឌីភី*

*ការបោះឆ្នោតជ្រើសរើស តំណាងរាស្ត្រ បានបង្ហាញអំពីការថយចុះគួរឱ្យលើកទឹកចិត្តនូវភាពមិនប្រក្រតី និងអំពើហឹង្សាខាងនយោបាយ ធៀបនឹងការបោះឆ្នោតលើកមុនៗ ។*

## ភាពប្រឈម

រដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួនបានយល់ស្របគ្នាថា អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យមានសារៈសំខាន់ជាសារវន្តសម្រាប់**ការអភិវឌ្ឍ** និង**ការកាត់បន្ថយភាពក្រីក្រ** ។ អភិបាលកិច្ចបែបនេះ ពាក់ព័ន្ធនឹងកត្តាជាច្រើនដែលរួមទាំងនីតិរដ្ឋ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ គណនេយ្យភាពនៃអ្នកតំណាងដែលជាប់ឆ្នោត ការចូលរួមរបស់សហគមន៍នៅក្នុងការធ្វើសេចក្តីសម្រេច សិទ្ធិទទួលបានយុត្តិធម៌ និងការយកចិត្តទុកដាក់ចំពោះក្រុមជនដែលទទួលបានការយកចិត្តទុកដាក់តិចតួច ជាពិសេស អ្នកក្រ ស្ត្រី និងជនជាតិដើមភាគតិច ។

ប៉ុន្តែ កម្ពុជាមាន**របបប្រជាធិបតេយ្យក្មេងខ្ចី**មួយដែលនៅទទួលរងឥទ្ធិពលសង្គ្រាម និងអស្ថិរភាពនយោបាយអស់ជាច្រើនទសវត្សរ៍ ដែលបានបង្កការខូចខាតជាទម្ងន់ដល់ភាពចុះសម្រុងគ្នា និងទំនុកចិត្តក្នុងសង្គម ។ កម្ពុជានៅត្រូវការឱ្យមានការពង្រឹងស្ថាប័ន និងសមត្ថភាពខាងអភិបាលកិច្ចដែលអាចផ្តល់ការឆ្លើយតបកម្រិតខ្ពស់ ជាពិសេសទៅថ្នាក់មូលដ្ឋាន ។ តាមទម្លាប់អំណាចនយោបាយ និងសមត្ថកិច្ចខាងរដ្ឋបាលមានលក្ខណៈប្រមូលផ្តុំកម្រិតខ្ពស់ណាស់ ដោយប្រជាពលរដ្ឋភាគច្រើនមានឥទ្ធិពលត្រឹមតិចតួចតែប៉ុណ្ណោះមកលើរដ្ឋាភិបាល ។ វិសមភាព និងការមិនរាប់រកគ្របដណ្តប់នៅក្នុងប្រព័ន្ធយុត្តិធម៌ និងសង្គមជាទូទៅដោយអ្នកក្រ ស្ត្រី យុវជន និងជនពិការ និងជនជាតិដើមភាគតិច ស្ថិតក្នុងស្ថានភាពចាញ់ប្រៀបគេនៅក្នុងការអនុវត្តសិទ្ធិស្របច្បាប់ និងសិទ្ធិស៊ីវិលរបស់ខ្លួន ។ ស្ត្រីប្រឈមនឹងការលំបាកជាច្រើនខាងផ្នែកសុខភាព ភាពថ្លៃថ្នូរ និងសុខុមាលភាពរបស់ខ្លួន ដែលរួមទាំងតាមរយៈបញ្ហាដែលទាក់ទងនឹងគ្រួសារ ដូចជាការលែងលះ និងអំពើហឹង្សាក្នុងគ្រួសារ ។ នៅក្នុងដំណើរការអភិវឌ្ឍន៍ដែលជាញឹកញាប់ប្រព្រឹត្តទៅដោយឆាប់រហ័ស និងដែលកំពុងកើតមានឡើងនៅក្នុងវិស័យជាប្រពៃណីរបស់ខ្លួន ជនជាតិដើមភាគតិចមានការលំបាក ដើម្បីទទួលបានអ្នកតំណាងសម្រាប់ការពារផលប្រយោជន៍របស់ពួកគេណាស់ ។

## ការឆ្លើយតបរបស់យូអិនឌីភី

យូអិនឌីភី និងដៃគូរបស់ខ្លួនធ្វើការដើម្បីលើកកំពស់ការយល់ដឹងអំពី**សិទ្ធិ និងការទទួលខុសត្រូវតាមបែបប្រជាធិបតេយ្យ** និងដើម្បីជួយឱ្យប្រព័ន្ធប្រជាធិបតេយ្យ ចាក់ឫស ។ ទន្ទឹមនឹងការជួយអាជ្ញាធរជាតិរៀបចំការបោះឆ្នោតនៅក្នុងការចាត់ចែងបោះឆ្នោតតាមបច្ចេកទេសត្រឹមត្រូវ យូអិនឌីភី ធ្វើការដើម្បីកាត់បន្ថយអំពើហឹង្សាខាងនយោបាយ និងបង្កើតបរិយាកាសអព្យាក្រឹត្យសម្រាប់ការជជែកវែកញែក ។ អ្នកជាប់ឆ្នោតបានទទួលការលើកទឹកចិត្តឱ្យស្តាប់ និងឆ្លើយតបទៅនឹងម្ចាស់ឆ្នោតនៅតាមមណ្ឌលរបស់ខ្លួន ។

**ការផ្ទេរអំណាចទៅរដ្ឋាភិបាលថ្នាក់មូលដ្ឋាន** គឺជាផ្នែកសំខាន់មួយនៃកំណែទម្រង់នានាដែលបានធ្វើឡើងដើម្បីនាំយករដ្ឋាភិបាលឱ្យមកកាន់តែជិតប្រជាពលរដ្ឋ ។ការធ្វើបែបនេះរាប់បញ្ចូលការជួយបុគ្គលនានា ដើម្បីបង្កើនចំណេះដឹងនិងជំនាញរបស់ខ្លួន ការពង្រឹងស្ថាប័ន និងការជម្រុញឱ្យមានបណ្តាញនៅក្នុងចំណោមអង្គភាពនៃរដ្ឋាភិបាលមូលដ្ឋាន ដែលអនុញ្ញាតឱ្យពួកគេសំដែងសម្លេងរួមគ្នាមួយ ។ យន្តការថ្មីៗខាងផ្នែកច្បាប់ និងរដ្ឋបាលកំពុងត្រូវបាន

ពិចារណាបង្កើតដើម្បីឱ្យមន្ទីរ និងការិយាល័យនៅថ្នាក់ខេត្ត ក្រុង និងស្រុក ដែលចំណុះឱ្យក្រសួងនៅថ្នាក់ជាតិ អាចចាប់យកការទទួលខុសត្រូវលើការផ្តល់សេវាមូលដ្ឋានតាមរយៈ និងទៅឱ្យក្រុមប្រឹក្សានៅមូលដ្ឋានទាំងនោះ។ ការធ្វើបែបនេះនឹងបង្កើនបទពិសោធន៍ជាក់ស្តែងលើការផ្តល់សេវាកម្មទៅឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន និងគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ យូអិនឌីភី ជម្រុញប្រជាពលរដ្ឋឱ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការឆ្លើយតប និងគណនេយ្យភាពនៃអភិបាលកិច្ចឱ្យបានកាន់តែច្រើនឡើង។

**ការចូលរួមរបស់ស្ត្រី**នៅក្នុងជីវភាពស៊ីវិល គឺជាគន្លឹះនៅក្នុងការផ្តល់សិទ្ធិអំណាចដល់ពួកគេ ហើយយូអិនឌីភីធ្វើការនៅតាមលំដាប់ថ្នាក់ជាច្រើន ដើម្បីលើកកំពស់សមធម៌យេនឌ័រដោយពុះពារដើម្បីធានាថា ស្ត្រីមានសម្លេងកាន់តែច្រើនឡើង នៅក្នុងការធ្វើសេចក្តីសម្រេចនិងលទ្ធភាពកាន់តែប្រសើរជាងមុនក្នុងការទទួលបានធនធានផលិតកម្ម។ ស្ត្រី និងជនក្រីក្រក៏ជាក្រុមគោលដៅដ៏សំខាន់ផងដែរនៅក្នុងកិច្ចប្រឹងប្រែងដើម្បីធ្វើឱ្យក្រុមដែលទទួលបានការយកចិត្តទុកដាក់តិចតួចមានលទ្ធភាពកាន់តែច្រើនឡើងក្នុងការទទួលបានយុត្តិធម៌តាមរយៈការគាំទ្រឱ្យមានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ តាមតម្រូវការជាពិសេសរបស់ប្រជាពលរដ្ឋ ដែលជាជនជាតិដើមភាគតិចត្រូវបានបម្រើតាមរយៈសកម្មភាពនានា ដែលបានបង្កើតឡើងដើម្បីបង្កើនការទទួលស្គាល់អំពីគោលការណ៍ប្រពៃណីរបស់ពួកគេ និងផ្តល់ជាវេទិកានានាសម្រាប់ដោះស្រាយវិវាទដីធ្លី។

## សមិទ្ធផលសំខាន់ៗនៅក្នុងឆ្នាំ ២០០៨

- អំពើហឹង្សាខាងនយោបាយមានការថយចុះគួរឱ្យកត់សំគាល់នៅក្នុងអំឡុងពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដែលជាកំណែលម្អមួយដែលមានការទាក់ទិនជាដុំកំភួនទៅនឹងការងាររបស់ យូអិនឌីភីនៅក្នុងការអប់រំអ្នកពាក់ព័ន្ធនានា និងការផ្តល់ជាវេទិកាសម្រាប់ការជជែកវែកញែក។
- គណៈកម្មការជាតិរៀបចំការបោះឆ្នោតបានកែលម្អសមត្ថភាពរបស់ខ្លួនលើបច្ចេកទេសឱ្យសមស្របសម្រាប់ចាត់ចែងការបោះឆ្នោត។
- ការបណ្តុះបណ្តាលអំពីដំណើរការបោះឆ្នោត និងសិទ្ធិនិងការទទួលខុសត្រូវតាមបែបប្រជាធិបតេយ្យបានធ្វើឡើងសម្រាប់មន្ត្រីនៃគណៈកម្មការរៀបចំការបោះឆ្នោតភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ក្រោម។
- ក្រុមនានា ដែលតាមធម្មតាទទួលបានការយកចិត្តទុកដាក់តិចតួចរួមមានស្ត្រី យុវជន និងជនពិការត្រូវបានទទួលការលើកទឹកចិត្តឱ្យចូលប្រឡូកក្នុងកិច្ចការស៊ីវិល។
- វេទិកានៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរវាងភាគីនយោបាយ និងការពិនិត្យមើលបញ្ហាចម្រូងចម្រាស់ត្រូវបានពង្រីកតាមរយៈកម្មវិធីតាមទូរទស្សន៍ ដែលគាំទ្រដោយយូអិនឌីភី។
- ជិត ៩៥ ភាគរយ នៃអ្នកបោះឆ្នោតបានប្រើអត្តសញ្ញាណប័ណ្ណជាតិ សម្រាប់ការធ្វើអត្តសញ្ញាណកម្ម។
- សមាជិកនៃសភាជាតិថ្មី បានចូលរួមនៅក្នុងវេទិកាបង្ហាញជាលើកដំបូងបំផុតសម្រាប់សមាជិកសភា។



រូបភាព: យូអិនឌីភី/សារ៉ា ដេវ៊្រត

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានា ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័តហើយកិច្ចការនានាបានចាប់ផ្តើមទៅតាមកម្មវិធីជាតិសម្រាប់រយៈពេល ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- សមាគមក្រុមប្រឹក្សាឃុំ/សង្កាត់នៅថ្នាក់ខេត្តត្រូវបានបង្កើតឡើងនៅក្នុងខេត្តដែលនៅសល់ចំនួនប្រាំបី និងបានចូលរួមជាមួយសហព័ន្ធជាតិ នៃក្រុមប្រឹក្សាឃុំ/សង្កាត់។
- ទឹកប្រាក់ចំនួន ៧១ លានដុល្លា ត្រូវបានវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ និងគម្រោងសេវាកម្មដោយយូអិនឌីភី បានផ្តល់ការគាំទ្រជាយោបល់បច្ចេកទេស និងលើប្រតិបត្តិការ។
- ការយកចិត្តទុកដាក់ជាពិសេសត្រូវបានធ្វើលើការផ្តល់សិទ្ធិអំណាចឱ្យដល់ស្ត្រីនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីសិក្សានៅសាលាភូមិន្ទរដ្ឋបាល និងចំណាត់ការជាវិជ្ជមានសម្រាប់ស្ត្រីនៅក្នុងសេវាកម្មស៊ីវិល។
- យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានទទួលការគាំទ្រតាមរយៈការបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌នៅថ្នាក់ស្រុកចំនួន១៦កន្លែងជាបន្ថែមទៀត ហើយគណៈកម្មការថ្នាក់ឃុំសម្រាប់ដោះស្រាយវិវាទចំនួន ៣៦ ត្រូវបានបង្កើតជាបន្ថែម។
- ជនជាតិដើមភាគតិចនៅក្នុងភូមិចំនួន ១២ បានទទួលការបណ្តុះបណ្តាលអំពីសិទ្ធិរបស់ជនជាតិដើមភាគតិចច្បាប់ដែលពាក់ព័ន្ធ និងជំនាញនៅក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- ការចរចាតាមយន្តការតុសន្តិភាពបានធ្វើឱ្យចំណែកដី ក្នុងវិវាទនៅកន្លែងមួយចំនួនត្រូវបានប្រគល់ទៅឱ្យសហគមន៍ជនជាតិដើមភាគតិចវិញ។

## ការគាំទ្រដល់ការបោះឆ្នោតផ្តល់នូវការពង្រឹងវប្បធម៌ថ្មីតាមបែបប្រជាធិបតេយ្យ

យូអិនឌីភី ផ្តល់ការគាំទ្រសម្រាប់រយៈពេលវែងដល់ស្ថាប័នកិច្ចផ្តួចផ្តើមអប់រំប្រជាពលរដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដើម្បីបង្កើតបរិយាកាស ដែលប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី និងយុត្តិធម៌ពិតៗ។ ការបោះឆ្នោត

*ការអប់រំប្រជាពលរដ្ឋ ជួយលើកទឹកចិត្តដល់ក្រុមដែលធម្មតាទទួលបានការយកចិត្តទុកដាក់តិចតួចឱ្យចូលរួមនៅក្នុងដំណើរការនយោបាយ។*

*"វគ្គបណ្តុះបណ្តាលនេះល្អណាស់ដោយសារវាផ្តល់ចំណេះដឹងអំពីច្បាប់បោះឆ្នោត តួនាទី និងការទទួលខុសត្រូវនៃអ្នកសង្កេតការណ៍ និងជួយភ្នាក់ងារមកពីគណបក្សឱ្យធ្វើការ បានប្រសើរជាងមុន។ ការបណ្តុះបណ្តាលនេះផ្តល់ឱ្យខ្ញុំនូវចំណេះដឹងបន្ថែមដើម្បីចែករម្លែកជាមួយអ្នក ដទៃ"។ សិក្ខាកាមមួយរូបពីក្រុងភ្នំពេញ នៅក្នុងវគ្គបណ្តុះបណ្តាលអំពីដំណើរការ បោះឆ្នោត។*


រូបភាព: យូអិនឌីភី/អ៊ីសាបែល លេសេរ

*អត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនផ្តល់ការគាំទ្រដល់សិទ្ធិក្នុងការបោះឆ្នោត ដោយវាផ្តល់ជាមធ្យោបាយដែលកាន់តែទុកចិត្តបានសម្រាប់ការធ្វើអត្តសញ្ញាណកម្ម ។ ជិត ៩៥ភាគរយនៃអ្នកបោះឆ្នោត បានប្រើប្រាស់អត្តសញ្ញាណប័ណ្ណ របស់ខ្លួននៅក្នុងការបោះឆ្នោតឆ្នាំ ២០០៨ ។*

ជាតិនៅឆ្នាំ ២០០៨ ដើម្បីជ្រើសរើសតំណាងរាស្ត្រ បានផ្តល់នូវសូចនាករសំខាន់ៗអំពីប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលអំពីការចូលរួមរបស់យូអិនឌីភី ដោយបង្ហាញពីកម្រិតទាបនៃអំពើហឹង្សាដែលទាក់ទងនឹងការបោះឆ្នោតចំនួនតិចជាងមុនសៃន្លឹកឆ្នោតខូចចំនួនតិចជាងមុននៃបណ្តឹងតវ៉ាជំទាស់នឹងមន្ត្រីនៃអាជ្ញាធរមូលដ្ឋាន និងមន្ត្រីរៀបចំការបោះឆ្នោត និងការយល់ដឹងបានប្រសើរជាងមុនអំពីដំណើរការនយោបាយ និងដំណើរការបោះឆ្នោតនៅក្នុងចំណោមមន្ត្រី និងសារធារណជនជាទូទៅ ។

យូអិនឌីភី បានបង្កើតភាពជាដៃគូជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន និងអង្គការសង្គមស៊ីវិលដើម្បីផ្តល់ជំនួយបច្ចេកទេសដល់គណៈកម្មាធិការរៀបចំការបោះឆ្នោតនៅថ្នាក់ ជាតិ ខេត្ត និងឃុំ ។ ដៃគូនានាទាំងនេះក៏បានផ្តល់ការគាំទ្រលើការអប់រំដល់អ្នកបោះឆ្នោត វេទិកាអព្យាក្រឹត្យសម្រាប់ការពិភាក្សានយោបាយ ការបណ្តុះបណ្តាលមន្ត្រីរៀបចំការបោះឆ្នោត និងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ និងផលិតព័ត៌មានអំពីរបៀបបោះឆ្នោតបានត្រឹមត្រូវ និងដែលមានតុល្យភាពសម្រាប់ចាក់ផ្សាយតាមទូរទស្សន៍ ។ យូអិនឌីភី បានកៀងគរមូលនិធិសម្រាប់ការបោះឆ្នោត និងសម្រាប់អ្នកសង្កេតការណ៍អន្តរជាតិដែលបានទទួលការបណ្តុះបណ្តាលរួច ។ អង្គការសង្គមស៊ីវិលបានអនុវត្តសកម្មភាពអប់រំអំពីពលរដ្ឋដល់ភ្នាក់ងារគណបក្សនយោបាយមន្ត្រីសន្តិសុខ និងមេភូមិ ក៏ដូចជា អំពីក្រុមនានាដែលពីមុនមកបានទទួលសេវាកម្មតិចតួច ដូចជាស្ត្រី មេដឹកនាំយុវជន និងជនពិការ ។

ការបោះឆ្នោតបានបង្ហាញឱ្យឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីគ្រប់គ្រងការងាររដ្ឋបាលលើការងារបោះឆ្នោតបានត្រឹមត្រូវតាមគោលការណ៍បច្ចេកទេស ។ បើទោះជាបែបនេះហើយក្តីអ្នកសង្កេតការណ៍ក្នុងការបោះឆ្នោតនៅតែមានកង្វល់អំពីបញ្ហាឯករាជ្យភាពរបស់គណៈកម្មាធិការនេះក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោត ។ នៅក្នុងដំណាក់កាលមុនការបោះឆ្នោត យូអិនឌីភីបានផ្តល់ការគាំទ្រឱ្យមានវេទិកាចំនួនពីរដែលបានរៀបចំឡើងដើម្បីលើកកំពស់បរិយាកាសល្អសម្រាប់ការបោះឆ្នោត ។ ទីមួយ កិច្ចប្រជុំជាបន្តបន្ទាប់នៃមន្ត្រីជាន់ខ្ពស់បានប្រមូលផ្តុំតំណាងនានាមកពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមេដឹកនាំគណបក្សនយោបាយដើម្បីបង្ហាញពីការព្រួយបារម្ភរបស់ពួកគេ និងស្វែងរកដំណោះស្រាយនៅក្រោមបរិយាកាសអព្យាក្រឹត្យមួយ ។ ទីពីរដំណើរការទប់ស្កាត់ជម្លោះនៅក្នុងដំណើរការបោះឆ្នោតនៅកម្ពុជាដែលបានទទួលមូលនិធិពី យូអិនឌីភី និងដឹកនាំដោយវិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា បានចាត់ចែងឱ្យមានការប្រជុំជាបន្តបន្ទាប់នៅទូទាំងប្រទេសដែលអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធនានាសំដែងអំពីកង្វល់របស់ពួកគេ ។

យូអិនឌីភី បានធ្វើជាដៃគូជាមួយគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយអព្យាក្រឹត្យនិងមិនលំអៀងនៅកម្ពុជាដើម្បីរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៤០៥ លើក សម្រាប់អ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមបំផុតនៅក្នុងឃុំទាំងអស់ចំនួន ១.៦២១ ទូទាំងប្រទេស ។ សិក្ខាកាមសរុបចំនួន ២០.១០៩ នាក់ ដែលរួមទាំង មេភូមិ មន្ត្រីឃុំ ព្រះសង្ឃ នគរបាល តំណាងមកពីគណបក្សនយោបាយ និងសមាជិកក្រុមស្ត្រីបានពិភាក្សាអំពីតួនាទីរបស់ពួកគេនៅក្នុងការបោះឆ្នោត និងសារៈសំខាន់នៃអព្យាក្រឹត្យ ។ បើទោះជានៅតែមានការចោទប្រកាន់អំពីភាពមិនប្រក្រតីនៅក្នុងការចាត់ចែងបោះឆ្នោតក៏ដោយ របាយការណ៍អំពីចំនួនឧប្បត្តិហេតុ ដែលពាក់ព័ន្ធជាមួយមេភូមិបានថយចុះយ៉ាងច្រើន បើប្រៀបធៀបនឹងការបោះឆ្នោតមុនៗ ។

យូអិនឌីភី បានគាំទ្រឱ្យមានការបណ្តុះបណ្តាលដល់មន្ត្រីនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីដំណើរការត្រឹមត្រូវនៅក្នុងថ្ងៃបោះឆ្នោត និងបានជួយចាត់ចែង និងរៀបចំការបណ្តុះបណ្តាលគ្រូបង្ហាត់សម្រាប់បុគ្គលិកគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោត ។ យូអិនឌីភី បានផ្តល់មូលនិធិដល់គ្រូបង្ហាត់នៅថ្នាក់ស្រុកចំនួន ១៥៥នាក់ ដើម្បីជួយដល់បុគ្គលិកថ្នាក់ខេត្តទាំងនេះដែលបានផ្សព្វផ្សាយព័ត៌មានទៅស្ថានីយ៍បោះឆ្នោតតាមរយៈគណៈកម្មាធិការឃុំរៀបចំការបោះឆ្នោត ។ ក្រោមការគាំទ្រពី យូអិនឌីភី វិទ្យាស្ថានជាតិប្រជាធិបតេយ្យបានចាត់ចែងឱ្យមានការបណ្តុះបណ្តាលគ្រូបង្ហាត់ដល់ភ្នាក់ងារមកពីគណបក្សដែលប្រកួតប្រជែងទាំងអស់អំពីរបៀបធ្វើការតាមដានការងាររបស់មន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយគ្រូបង្ហាត់របស់យូអិនឌីភី មកពីប្រទេសទីម័រខាងកើត បានជួយគណបក្សនានានៅក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន ។ យូអិនឌីភីបានផ្តល់ការគាំទ្រជាសម្ភារៈ សម្រាប់ការបណ្តុះបណ្តាលតំណាងមកពីគណបក្សនានានៅថ្នាក់ខេត្ត ឃុំ និងតាមស្ថានីយ៍បោះឆ្នោតនៅទូទាំងប្រទេស ។

អង្គការជនពិការកម្ពុជាបានធ្វើការបង្កើនការយល់ដឹង និងការចូលរួមក្នុងចំណោមជនពិការ ។ គណៈកម្មាធិការបោះឆ្នោតដោយសេរី និងយុត្តិធម៌ បានធ្វើការជាមួយមេដឹកនាំយុវជនចំនួន ៣០០ នាក់ មកពីគណបក្សនយោបាយនានា ហើយអង្គការយុវជននៅក្នុងខេត្តចំនួនប្រាំ បានអនុវត្តកម្មវិធីផ្សព្វផ្សាយ ដែលរួមទាំងកម្មវិធីប្រចាំសប្តាហ៍តាមវិទ្យុផងដែរ ។ គណៈកម្មាធិការលើកកំពស់ស្ត្រីនៅក្នុងកិច្ចការនយោបាយមានគោលដៅបង្កើនចំនួនស្ត្រីជាមេដឹកនាំ និងការចូលរួមនៅក្នុងការបោះឆ្នោតដោយផ្តល់ការបណ្តុះបណ្តាល និងវេទិកានានា ជាពិសេសសម្រាប់ក្រុមសាសនា និងក្រុមជនជាតិដើមភាគតិចនៅក្នុងខេត្តចំនួនប្រាំពីរ ។

យូអិនឌីភី បានគាំទ្រគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីផលិតសម្ភារៈអប់រំអ្នកបោះឆ្នោតដែលរួមទាំងរូបភាពណែនាំ ចំនួន ១៣០.៤០០ផ្ទាំងបដា ចំនួន ៤.០៣៥ ផ្ទាំង ចម្រៀង និងខ្សែរឿងតាមវីដេអូ និងឈុតវីដេអូខ្លីៗ អំពីប្រធានបទនានាដែលរួមទាំងអំពី "ទិវាបោះឆ្នោតគ្មានអំពើហឹង្សា" "គ្មានអាវុធ" "ភាពសម្ងាត់នៃសន្លឹកឆ្នោត"។ សម្ភារៈដទៃទៀត រួមមានខ្សែវីដេអូសម្រាប់អប់រំអ្នកបោះឆ្នោត និងខ្សែវីដេអូសម្រាប់បណ្តុះបណ្តាលដល់បុគ្គលិកនៅតាមស្ថានីយ៍បោះឆ្នោត។ យូអិនឌីភីក៏បានចែកចាយសន្លឹកព័ត៌មានសម្រាប់អ្នកបោះឆ្នោតចំនួន ៦.៩៦៩.១០៣ សន្លឹកផងដែរ។

ទ.ទ.ក ដែលជាស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា និង យូអិនឌីភី បានរួមគ្នាផលិតកម្មវិធីចំនួនពីរនៅក្រោមផ្លាកសញ្ញា "សមធម៌"។ កម្មវិធីសមធម៌ប្រចាំសប្តាហ៍បានចាក់ផ្សាយចំនួន ៤៨ លើក នូវកម្មវិធីដែលមានរយៈពេលមួយម៉ោងអំពីព័ត៌មានកិច្ចការបច្ចុប្បន្នភាព និងដែលរាយការណ៍អំពីបញ្ហានយោបាយដែលកាន់តែក្លាយជាប្រការសំខាន់ និងដែលមានភាពចម្រូងចម្រាស់ដោយរួមទាំងអំពីសាលាក្តីខ្មែរក្រហម អំពើពុករលួយ និងការទន្ទ្រានយកដីធ្លីផងដែរ។ ព័ត៌មានសមធម៌បានចាក់ផ្សាយរយៈពេលកន្លះម៉ោងនូវកម្មវិធីព័ត៌មានអំពីការបោះឆ្នោតនៅរាត្រីពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ នៅក្នុងអំឡុងពេលនៃយុទ្ធនាការបោះឆ្នោតជាតិ និងត្រូវបានគេមើលឃើញថាជាការផ្សាយព័ត៌មានដែលមានលក្ខណៈយុត្តិធម៌ជាងគេ និងប្រកបដោយតុល្យភាពបំផុតនៅតាមទូរទស្សន៍កម្ពុជាអំពីការបោះឆ្នោត។ រយៈពេលចាក់ផ្សាយត្រូវបានបែងចែកឱ្យគណបក្សនយោបាយទៅតាមរូបមន្តនៃការចាក់ផ្សាយដោយផ្អែកលើចំនួនអាសនៈរបស់គណបក្សនយោបាយទាំងនោះ នៅក្នុងសភាអាណត្តិមុន និងចំនួនខេត្ត ដែលគណបក្សទាំងនោះបានដាក់បេក្ខជនឈរឈ្មោះ។ ដោយគោរពតាមគោលការណ៍របស់យូអិនឌីភី អំពីការចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ក្រុមអ្នកយកព័ត៌មានមកពីប្រទេសទីម័រខាងកើតបានមកធ្វើទស្សនកិច្ចសិក្សាអំពីកម្មវិធីសមធម៌ប្រចាំសប្តាហ៍នៅកម្ពុជា។

រដ្ឋាភិបាលបានធ្វើការប្តេជ្ញាផ្តល់ទឹកប្រាក់ចំនួន១០លានដុល្លារអាមេរិក ទៅក្នុងថវិកាសម្រាប់រៀបចំការបោះឆ្នោត។ តាមការស្នើសុំរបស់រដ្ឋាភិបាល យូអិនឌីភី បានបង្កើតភាពជាដៃគូជាមួយ AusAID, CIDA, DANIDA, ជប៉ុន និង SIDA ដើម្បីកៀរគរមូលនិធិចំនួន ៦.១១៣.៤៧៦ ដុល្លារអាមេរិកបន្ថែមទៀត។ យូអិនឌីភីបានជួលអ្នកសម្របសម្រួលមួយរូបដើម្បីសម្រួលដល់អ្នកសង្កេតការណ៍អន្តរជាតិនៅក្រោមកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ មានអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិចំនួន ៥៩២ នាក់ មកពីស្ថានទូត និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៩ ក៏ដូចជាអ្នកសង្កេតការណ៍ក្នុងស្រុកចំនួន ៣១.២៦២ នាក់ផងដែរ។ គណៈកម្មាធិការនេះ ក៏បានផ្តល់សិទ្ធិដល់ភ្នាក់ងារចំនួន ១៣១.៥៣៤ នាក់ មកពីគណៈបក្សនយោបាយនានា ដើម្បីសង្កេតការបោះឆ្នោតនេះផងដែរ។ ក្រោមការជួយឧបត្ថម្ភពី យូអិនឌីភី គណៈកម្មាធិការនេះបានសម្រេចគោលដៅរបស់ខ្លួនក្នុងការធ្វើឱ្យមានស្ត្រី ៣០ ភាគរយនៅក្នុងចំណោមបុគ្គលិកតាមស្ថានីយ៍បោះឆ្នោត និងស្ថានីយ៍រាប់សន្លឹកឆ្នោត ប៉ុន្តែអត្រានេះមានកម្រិតទាបជាងនេះនៅក្នុងគណៈកម្មាធិការខេត្ត និងឃុំ រៀបចំការបោះឆ្នោត។


រូបភាព: យូអិនឌីភី/ហួយ សុជាតិ

សមាជិកសភាពជួបជាមួយប្រជាពលរដ្ឋនៅក្នុងអំឡុងពេលធ្វើទស្សនកិច្ចនៅខេត្តព្រៃវែង។

យូអិនឌីភី បានផ្តល់មូលនិធិសម្រាប់ការធ្វើសវនកម្មមួយក្នុងខែឧសភាលើបញ្ជីអ្នកបោះឆ្នោតដែលបានបង្ហាញថា បើទោះជាមានកំណែលម្អខ្លះៗ ធៀបនឹងសវនកម្មលើកមុននៅក្នុងខែ សីហា ឆ្នាំ ២០០៧ ក៏ដោយឈ្មោះចំនួន ៩៥.០០០ ត្រូវបានលុបចោលដោយមិនត្រឹមត្រូវ។ នេះជាចំនួនដែលមានរហូតដល់ ៨.៦ ភាគរយនៃចំនួនសរុបដែលបានលុបចេញពីបញ្ជី។ បើទោះជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបង្ហាញថាវាជាការយឺតពេលដើម្បីធ្វើការកែសម្រួលក៏ដោយធៀបនឹងកាលវិភាគសម្រាប់ការបោះឆ្នោតសវនកម្មនេះបានផ្តល់ជាចំណុចយោងមួយសម្រាប់គ្រោងមានកំណែលម្អ។ អ្នកសង្កេតការណ៍ជាច្រើនបានរាយការណ៍អំពីករណីដែលអ្នកមានសិទ្ធិបោះឆ្នោតដែលបានអះអាងថាឈ្មោះរបស់ពួកគេពុំមាននៅក្នុងបញ្ជីបោះឆ្នោតឡើយសូម្បីតែពួកគេបានមកចុះឈ្មោះរួចមកហើយក៏ដោយ។ យូអិនឌីភី បានផ្តល់ប្រឹក្សាដល់គណៈកម្មាធិការនេះអំពីការបញ្ចូលបញ្ជីឈ្មោះនៅលើថាសស៊ីឌី។ នៅក្នុងដំណាក់កាលជិត ដល់ពេលបោះឆ្នោតសមាជិកគណៈកម្មាធិការនេះ និងនាយកដ្ឋាននានាបានបង្កើនលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតដោយគ្មានកម្រិតកំណត់។

យូអិនឌីភី បានផ្តល់យោបល់ទៅក្រសួងមហាផ្ទៃអំពីបញ្ហាអត្តសញ្ញាណប័ណ្ណជាតិ សម្រាប់ពលរដ្ឋគ្រប់រូបដែលមានអាយុចាប់ពី ១៥ឆ្នាំឡើង ដែលក៏អាចយកទៅប្រើប្រាស់ជាអត្តសញ្ញាណកម្មដែលមានសុពលភាពសម្រាប់ការបោះឆ្នោតផងដែរ។ មកទល់ចុងឆ្នាំ២០០៨ មានការចេញអត្តសញ្ញាណប័ណ្ណចំនួន៨.០៥៨.៣០៩ក្នុងចំណោមប័ណ្ណចំនួន ៨.៩៣៦.០៤៦ ដែលបានប៉ាន់ប្រមាណថាត្រូវការជាចាំបាច់។ ជិត ៩៥ភាគរយ នៃអ្នកបោះឆ្នោតបានប្រើប្រាស់អត្តសញ្ញាណប័ណ្ណរបស់ខ្លួន ដើម្បីធ្វើអត្តសញ្ញាណខ្លួនឯងនៅតាមស្ថានីយ៍បោះឆ្នោត។ យូអិនឌីភី បានផ្តល់យោបល់ដល់ក្រសួងនេះអំពីសក្តានុពលសម្រាប់ការប្រើប្រាស់ប្រព័ន្ធអត្តសញ្ញាណកម្មស្នាមផ្តិតម្រាមដៃដើម្បីធ្វើឱ្យកម្មវិធីផ្តល់អត្តសញ្ញាប័ណ្ណមានសុវត្ថិភាព និងធានាថាគ្មានអ្នកណាម្នាក់មានប័ណ្ណលើសពីមួយឡើយ។

"សិក្ខាសាលានេះផ្តល់ឱ្យយើងនូវឱកាសមួយដើម្បី មើលឃើញថា ការជួញដូរមនុស្សគឺជាអំពើគ្មានមនុស្សធម៌ និងជាការប្រព្រឹត្តមិនត្រឹមត្រូវ ដែលរំលោភលើសិទ្ធិមនុស្ស"
ជំទាវ ហូ ណូន ប្រធាននៅក្នុងសិក្ខាសាលារបស់សភាស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ផ្លូវភេទ។


រូបភាព: យូអិនឌីភី/ជុំ សុវណ្ណ

តំណាងនានានៃក្រុមប្រឹក្សាឃុំ-សង្កាត់ បោះឆ្នោតគាំទ្រការឡើងកាន់តំណែងនៃ សមាគមក្រុមប្រឹក្សាឃុំ-សង្កាត់នៅថ្នាក់ខេត្ត នៅក្នុងខេត្ត ស្ទឹងត្រែង ។

## អ្នកតាក់តែងច្បាប់សិក្សាអំពីបញ្ហាធំៗ ស្តាប់កង្វល់របស់ប្រជាពលរដ្ឋ

យូអិនឌីភី ជួយលើកកំពស់អភិបាលកិច្ចល្អដោយគាំទ្រសមាជិកសភា ក្នុងការអនុវត្តមុខនាទីរបស់ខ្លួនលើការតាក់តែងច្បាប់ត្រួតពិនិត្យ និងធ្វើជាតំណាង និងធ្វើការជាមួយបុគ្គលិកសភាដើម្បីជួយផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធិភាពដល់ម្ចាស់ឆ្នោតនិងមណ្ឌលបោះឆ្នោតរបស់ពួកគេ ។ ជំនួយរបស់ យូអិនឌីភី មានភាពស្របគ្នាជាមួយគោលដៅ ដែលបានចែងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពឆ្នាំ ២០០៦ របស់សភាសម្រាប់ការកសាងសមត្ថភាពសភាកម្ពុជា ។ ជំនួយដល់សមាជិកសភាទាំងនៅក្នុងសភាជាតិ និងព្រឹទ្ធសភាមានគោលដៅពង្រឹងស្ថាប័នប្រជាធិបតេយ្យដែលដើរតួក្នុងការត្រួតពិនិត្យ និងធ្វើតុល្យភាពអំណាចជាមួយផ្នែកនីតិប្រតិបត្តិ ។ សមាជិកសភាបានទទួលការលើកទឹកចិត្តឱ្យអនុវត្តមុខនាទីរបស់ខ្លួនតាមវិធីដែលអាចរួមចំណែកទៅក្នុងលទ្ធិប្រជាធិបតេយ្យតាមបែបផែនចូលរួម និងមានលក្ខណៈជាតំណាង ។

ការគាំទ្រដល់បុគ្គលិកនៃអគ្គលេខាធិការដ្ឋានសភាទាំងពីរនិងលេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេសគឺជាការពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការផ្តល់សេវាកម្មដែលមានប្រសិទ្ធិភាពទៅដល់សភាទាំងពីរនិងប្រជាពលរដ្ឋ ។ ដោយឡែក យូអិនឌីភី ផ្តល់យោបល់ទៅឱ្យលេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេសដើម្បីជួយលេខាធិការដ្ឋាននេះអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព និងសម្របសម្រួលជំនួយអភិវឌ្ឍន៍ពីដៃគូនានា ។

ភ្លាមៗនៅក្រោយការបោះឆ្នោត យូអិនឌីភី បានគាំទ្រឱ្យមានវេទិកាណែនាំបង្ហាញរយៈពេលពីរថ្ងៃដល់សភាអាណត្តិទីបួនសម្រាប់សមាជិកថ្មី និងសមាជិកដែលជាប់ឆ្នោតឡើងវិញដែលមានការចូលរួមពីសមាជិកសភាអគ្គលេខាធិការដ្ឋានអង្គការសង្គមស៊ីវិល និងស្ថានទូតបរទេសសរុបប្រមាណ២០០នាក់ ។ វេទិកានេះគឺជាឱកាសដំបូងសម្រាប់លេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេសក្នុងការបង្ហាញពីតួនាទីសម្របសម្រួលទ្រង់ទ្រាយធំរបស់ខ្លួន និងការនាំមកដោយប្រសិទ្ធិភាពនូវដៃគូអភិវឌ្ឍន៍ជាច្រើនឱ្យជុំគ្នាដើម្បីធ្វើសកម្មភាពរួមគ្នា ។

សមាជិកសភាក៏បានចូលរួមជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិលនៅក្នុងសិក្ខាសាលាជាបន្តបន្ទាប់ដែលពិភាក្សាអំពីបញ្ហានានា ដូចជាថវិកាជាតិ ការជួញដូរមនុស្ស និងទិវាសិទ្ធិមនុស្សផងដែរ ។ អ្នកចូលរួមមកពីអង្គការ UNICEF, ILO, UNOHCHR និង IOM ។ អង្គការ UNAIDS បានផ្តល់ជំនាញបច្ចេកទេសលើសកម្មភាពទាក់ទងការផ្សព្វផ្សាយអំពីមេរោគអេដស៍/ជម្ងឺអេដស៍ និងសភា ។ អង្គការ UNIFEM បានផ្តល់ថវិកាបដិភាគសម្រាប់រៀបចំសិក្ខាសាលាមួយអំពីអនុសញ្ញាស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ។

សមាជិកសភាបានចូលរួមនៅក្នុងវេទិកាថ្នាក់តំបន់ និងទស្សនកិច្ចតាមមូលដ្ឋាននៅក្នុងខេត្តចំនួន ១៤ ដោយផ្តោតលើបញ្ហានានាដែលរួមទាំងការជួញដូរមនុស្សការធ្វើចំណាកស្រុកប្រព័ន្ធតុលាការនៅមូលដ្ឋានសិទ្ធិមនុស្សអំពើហិង្សាក្នុងគ្រួសារនិងពលកម្មកុមារ ។ សកម្មភាពទាំងនេះបានបង្កើតឱកាសសម្រាប់ការជួបប្រាស្រ័យជាមួយម្ចាស់ឆ្នោតនៅមូលដ្ឋាន ដែលរួមទាំងក្រុមសង្គមស៊ីវិលនៅមូលដ្ឋាន និងក្រុមប្រឹក្សាឃុំផងដែរលេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេស បានផ្តល់បទបង្ហាញអំពីស្ថានភាពនៅកន្លែងចុះទស្សនកិច្ច និងចាត់ចែងឱ្យមានការជួបប្រជុំនៅមូលដ្ឋានផ្ទាល់ជាមួយអង្គការសង្គមស៊ីវិល ដែលធ្វើការលើបញ្ហាទាំងនេះ ។ បុគ្គលិកនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភាបានពង្រឹងជំនាញវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការបណ្តុះបណ្តាលលើការគ្រប់គ្រងការវិភាគច្បាប់ ការបង្កើតវេបសាយ បច្ចេកវិទ្យាព័ត៌មានជាមូលដ្ឋាន និងជវលេខជាភាសាខ្មែរ ។

ជំហានសំខាន់មួយនៅក្នុងឆ្នាំ២០០៨គឺការបង្កើតទំនាក់ទំនងយូរអង្វែងរវាងលេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេស និងដៃគូអភិវឌ្ឍន៍នានាដែលធ្វើការគាំទ្រដល់សភា ។ លេខាធិការដ្ឋាននេះបានចាត់ចែងឱ្យមានការប្រជុំសម្របសម្រួលប្រចាំខែដែលបង្កើតជាវេទិកាសម្រាប់ចែករំលែកព័ត៌មាន និងពិភាក្សាអំពីឱកាសសម្រាប់កិច្ចសហការ ។ សកម្មភាពរួមគ្នាត្រូវបានធ្វើឡើងតាមរយៈគម្រោងជំនួយអង្គនីតិបញ្ញត្តិកម្ពុជា-កាណាដាមជ្ឈមណ្ឌលអាល្លឺម៉ង់សម្រាប់ទេសន្តប្រវេសន៍អន្តរជាតិ និងមូលនិធិខុនរ៉ាត់អាដេណោអឺ ។

ក្រុមប្រឹក្សាមូលដ្ឋានពង្រីកតួនាទីរបស់ខ្លួននៅក្នុងការបម្រើសហគមន៍រដ្ឋាភិបាលមើលឃើញវិមជ្ឈការ និងវិសហមជ្ឈការថាជាលក្ខខណ្ឌចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ។ ការប្តេជ្ញារបស់រដ្ឋាភិបាលបានធ្វើឡើងជាក់ស្តែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលជាយុទ្ធសាស្ត្រមូលដ្ឋានគ្រឹះរបស់ខ្លួនសម្រាប់កាត់បន្ថយភាពក្រីក្រ ។ ក្រោមភាពជាដៃគូជាមួយ SIDA, DFID និងគណៈកម្មការសហគមន៍អឺរ៉ុប យូអិនឌីភី ធ្វើការជាមួយក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិគ្រប់គ្រងការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យ (NCDD) ដើម្បីគាំទ្រដល់ការប្តេជ្ញារបស់រដ្ឋាភិបាលតាមរយៈការផ្តល់យោបល់ខាងគោលនយោបាយ ការអភិវឌ្ឍជំនាញ និងចំណេះដឹងការគាំទ្រឱ្យមានស្ថាប័នតំណាងថ្មីៗ និងមូលនិធិវិនិយោគ ។

រចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជានៅក្នុងឆ្នាំ ២០០៨ មាន ២៤ ខេត្ត១៩៣ ខណ្ឌ ឬស្រុក និងតំបន់រដ្ឋបាលមូលដ្ឋានចំនួន ១៦២១ ដែលហៅថាសង្កាត់នៅក្នុងរាជធានី និងទីក្រុងនិងហៅថាឃុំនៅក្នុងទីជនបទដែលជាកន្លែងរស់នៅនៃជនកម្ពុជា៨០ភាគរយ ។ ក្នុងចំណោមរដ្ឋាភិបាលទាំងបីលំដាប់នៅថ្នាក់ក្រោមជាតិ មានតែក្រុម

ប្រឹក្សាឃុំ/សង្កាត់ដែលប្រជាពលរដ្ឋបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដែលធ្វើឱ្យរដ្ឋាភិបាលមូលដ្ឋានក្លាយជាចំណុចចាប់ផ្តើមយ៉ាងសំខាន់សម្រាប់អភិបាលកិច្ចប្រជាធិបតេយ្យ ។

តាមរយៈវិមជ្ឈការរដ្ឋាភិបាលផ្តល់ឱ្យក្រុមប្រឹក្សាខេត្ត ស្រុក និងឃុំ/សង្កាត់ នូវភាពជាម្ចាស់លើមុខនាទី សមត្ថកិច្ច និងធនធាន ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៅមូលដ្ឋាន។ ក្រុមប្រឹក្សានានាមានភារៈទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តាមរយៈវិសហមជ្ឈការក្រសួងនានារបស់រដ្ឋាភិបាល និងស្ថាប័នផ្សេងទៀតផ្ទេរមុខនាទី និងធនធានទៅឱ្យអង្គភាពនានានៅក្រោមចំណុះឬទៅក្រុមប្រឹក្សាដែលអនុវត្តគោលនយោបាយជំនួសមុខឱ្យក្រសួង ឬស្ថាប័នទាំងនោះ។

ព្រឹត្តិការណ៍សំខាន់មួយបានកើតមានឡើងនៅក្នុងឆ្នាំ ២០០៨នៅពេលដែលសភាជាតិបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុង ស្រុក ខណ្ឌ។ ច្បាប់នេះត្រូវបានរៀបចំជាសេចក្តីព្រាងក្រោមការជួយឧបត្ថម្ភពីយូអិនឌីភី។ ច្បាប់នេះផ្តល់ជាមាគ៌ាសម្រាប់ការបោះឆ្នោតដោយមិនផ្ទាល់ដើម្បីជ្រើសរើសក្រុមប្រឹក្សាខេត្តក្រុងស្រុកខណ្ឌនៅក្នុងឆ្នាំ ២០០៩ និងបានបង្កើត NCDD ដែលបានចាប់ផ្តើមបង្កើតគោលការណ៍ណែនាំលំអិតដែលនឹងជួយក្រុមប្រឹក្សាថ្មីៗទាំងនេះដើម្បីអនុវត្តច្បាប់នេះ។ ការងារនេះបានចាប់ផ្តើមដោយការអនុវត្តកម្មវិធីជាតិរយៈពេល ១០ ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយយូអិនឌីភី បានផ្តល់យោបល់ខាងគោលនយោបាយដល់ NCDD និងលេខាធិការដ្ឋាននៃគណៈកម្មការនេះក៏ដូចជាជំនួយខាងផ្នែកច្បាប់និងទំនាក់ទំនងនិងការគាំទ្រសម្រាប់បង្កើតជំនាញនិងចំណេះដឹងដែលពាក់ព័ន្ធផងដែរ។

នៅពេលដែលមិនទាន់មានការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ NCDD បានដាក់ចេញនូវចំណាត់ការបណ្តោះអាសន្នមួយដែលតាមរយៈនោះគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ ខេត្ត ដែលមានអភិបាលខេត្តជាប្រធាន បានជួយក្រុម ប្រឹក្សាឃុំ-សង្កាត់ ក្នុងការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធឱ្យប្រជាពលរដ្ឋមូលដ្ឋាន។ ការគាំទ្ររបស់យូអិនឌីភីសម្រាប់ចំណាត់ការទាំងនេះ ផ្តោតលើការបង្កើតគោលនយោបាយក្នុងរង្វង់រដ្ឋាភិបាលថ្នាក់ កណ្តាល និងលើការបង្កើតគោលនយោបាយដំណើរការ និងជំនាញនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ដែលអាចជួយរដ្ឋាភិបាលនៅលំដាប់ថ្នាក់ទាំងនេះ ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់បានប្រសើរជាងមុន។

ការវិនិយោគដែលមានតម្លៃសរុប ៧១ លានដុល្លា ដែលបានពីម្ចាស់ជំនួយចំនួន ១៦ ត្រូវបានអនុវត្តតាមរយៈគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត និងគណៈកម្មការប្រតិបត្តិ និងអង្គភាពបច្ចេកទេសដោយមានយូអិនឌីភី ជាអ្នកផ្តល់យោបល់ និងជាអ្នកគាំទ្រ។ មូលនិធិនេះត្រូវបានចំណាយលើសកម្មភាពជាច្រើនដែលរួមទាំងជំនួយបច្ចេកទេសប្រតិបត្តិការការសិក្សាស្រាវជ្រាវ និងគម្រោងសេវាកម្ម។ ក្នុងចំណោមទឹកប្រាក់សរុប មានតែទឹកប្រាក់ត្រឹមច្រើនជាង ២៧ លានដុល្លា ដែលបានវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទកិច្ចផ្តួចផ្តើមចិញ្ចឹមជីវិត និងសេវាកម្មសង្គម។ ការវិនិយោគនេះបានធ្វើឡើងតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់តាមរូបភាពដែលបានលើកកំពស់គណនេយ្យភាពនៃក្រុមប្រឹក្សាទាំង


រូបភាព: យូអិនឌីភី/អ៊ីសាបែល លេសេរ

ការគ្រប់គ្រងការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធ អាចជួយដល់សមាជិកក្រុម ប្រឹក្សាឃុំ ក្នុងការកសាងជំនាញ និងចំណេះដឹង ។

នេះក៏ដូចជាការចូលរួមរបស់សហគមន៍នៅក្នុងការជ្រើសរើសគម្រោងផងដែរ។

ទឹកប្រាក់ចំនួន ២៧ លានដុល្លា ត្រូវបានផ្តល់តាមរយៈមូលនិធិដាច់គ្នាចំនួនបី។ ទីមួយមូលនិធិឃុំ-សង្កាត់ដែលប្រមូលផ្តុំមូលនិធិមកពីរដ្ឋាភិបាល ធនាគារពិភពលោក SIDA, DFID និងយូអិនឌីភី ដែលមានទឹកប្រាក់ចំនួន ២៣ លានដុល្លា ក្នុងចំណោមទឹកប្រាក់ទាំងអស់។ ក្រុមប្រឹក្សា ឃុំ-សង្កាត់ បានចុះហត្ថលេខាលើកិច្ចសន្យាថ្មីៗចំនួន ១.៥៤០ សម្រាប់គម្រោង ដែលបានគាំទ្រតាមរយៈមូលនិធិនេះ។ ទីពីរ កិច្ចផ្តួចផ្តើមនៅថ្នាក់ស្រុក និងមូលនិធិវិនិយោគថ្នាក់ខេត្ត ដែលគាំទ្រដោយ SIDA, DFID DANIDA និងយូអិនឌីភី បានផ្តល់ទឹកប្រាក់ចំនួន ២ លានដុល្លា សម្រាប់ការវិនិយោគនានា។ គម្រោងនានាមានចាប់ពីគម្រោងផ្លូវថ្នល់សាលារៀន និងអណ្តូងទឹក រហូតដល់គម្រោងសាងសង់ ផ្គត់ផ្គង់ទឹក ប្រឡាយដោះទឹក និងបង្គន់អនាម័យ។ ផ្នែកមួយនៃមូលនិធិទាំងនេះត្រូវបានប្រើប្រាស់ដើម្បីគាំទ្រគម្រោងនានា ដែលផ្តោតលើកំណែលម្អធនធានធម្មជាតិ និងសម្រាប់ការបណ្តុះបណ្តាល។ ការងារជាច្រើនត្រូវបានអនុវត្ត ដើម្បីគាំទ្រដល់កិច្ចការនៃរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ និងដើម្បីធ្វើឱ្យប្រសើរឡើងនូវបញ្ហានានា ដែលកើតចេញពីកំណើនថ្លៃទំនិញ ការដេញថ្លៃមិនបានល្អ និងការឃុបឃិតក្នុងចំណោមអ្នកម៉ៅការ។

ទីបីមូលនិធិសម្រាប់កិច្ចសហប្រតិបត្តិការអន្តរឃុំសម្រាប់គម្រោងដែលផ្តល់ជាប្រយោជន៍ដល់អ្នកក្រដែលគាំទ្រដោយគណៈកម្មការសហគមន៍អឺរ៉ុប និងយូអិនឌីភី ដែលបានផ្តល់ទឹកប្រាក់ចំនួន២លានដុល្លាផងដែរ។ គម្រោងនានាដែលគាំទ្រដោយមូលនិធិនេះត្រូវបានគ្រោងឡើងសម្រាប់ផ្តល់ជាប្រយោជន៍ដល់ឃុំច្រើនជាងមួយ។ គម្រោងភាគច្រើនជាគម្រោងសាងសង់ ឬស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ប្រឡាយទឹក អណ្តូងទឹក និងសាលាបឋមសិក្សា។ សេវាកម្មដែលនៅសល់ក្រៅពីនេះ ដូចជាការសិក្សាអក្ខរកម្ម និងការបណ្តុះបណ្តាលវិជ្ជាជីវៈលើជំនាញនានាដែលរួមទាំងការចិញ្ចឹមសត្វ ការកែច្នៃចំណីអាហារ និងការកែច្នៃសូត្រ។ ទន្ទឹមនឹងការលើកទឹកចិត្តឱ្យមានការអភិវឌ្ឍសហគមន៍ជាទូទៅគម្រោងទាំងនេះមានសក្តានុពលយ៉ាងច្រើនក្នុងការកាត់

"ទាក់ទងនឹងតំណែង របស់ស្ត្រីជាអភិបាលរង ខេត្តនិងស្រុក នាយករដ្ឋមន្ត្រីក៏បានយកចិត្តទុកដាក់ចំពោះតួលេខទាបនៃចំនួនស្ត្រីនៅក្នុងតំណែងនៅថ្នាក់ខេត្ត និង ក្រុង នេះផងដែរ"

មួយក្នុងចំណោមអនុសាសន៍ចំនួន ១៤ ដែលបាន លើកឡើងនៅក្នុងសមាជប្រចាំឆ្នាំនៃក្រុមប្រឹក្សាជាតិកម្ពុជា សម្រាប់ស្ត្រី ។



*រូបភាព: យូអិនឌីភី/អ៊ីសាបែល លេសេរ*

*ផ្លូវថ្នល់ ប្រឡាយលូដោះ ទឹក សាលារៀន បង្គន់អនាម័យថ្មីៗ ជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រយុទ្ធនឹងភាពក្រីក្រ និងជួយបង្កើតភាពចុះសម្រុងនៅក្នុងសង្គម។*

បន្ថយភាពក្រីក្រ។ នៅឆ្នាំ ២០០៨ មូលនិធិនេះបានពង្រីកវិសាលភាពគ្របដណ្តប់របស់ខ្លួនពីខេត្តចំនួន ១០ រហូតដល់ខេត្តចំនួន ១២ ហើយក្រសួងមហាផ្ទៃបានកែសម្រួលគោលការណ៍ណែនាំដើម្បីអនុញ្ញាតឱ្យអនុវត្តគម្រោងបែបនេះអាចអនុវត្តឆ្លងព្រំប្រទល់ស្រុកបានផងដែរ។ គម្រោងថ្មីចំនួន៦៥ត្រូវបានជ្រើសរើសហើយ ការសិក្សាលទ្ធភាពលទ្ធកម្មការចុះកិច្ចសន្យា និងការអនុវត្តត្រូវបានចាប់ផ្តើម។ គម្រោងហេដ្ឋារចនាសម្ព័ន្ធបានអនុវត្តនៅក្នុងបរិស្ថានដែលមានភាពក្រួតប្រជែងយ៉ាងខ្លាំង ដោយសារអត្រាអតិផរណាបានកើនឡើងយ៉ាងខ្ពស់រហូតដល់២៥ភាគរយសម្រាប់សម្ភារៈសាងសង់។ គម្រោងមួយចំនួនត្រូវបានក្រុមហ៊ុនម៉ៅការបោះបង់ចោលដែលតម្រូវឱ្យធ្វើការវាយតម្លៃ និងការធ្វើលទ្ធកម្មជាថ្មីឡើងវិញ។ នៅក្រោមកិច្ចសហការជាមួយ UNICEF អង្គការយូអិនឌីភីបានជួយបង្កើតគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារនៅក្នុងខេត្តចំនួន១៨ដោយផ្តោតលើការអភិវឌ្ឍសង្គម និងការតស៊ូមតិ និងកិច្ចការពារនៅក្នុងសហគមន៍មូលដ្ឋាន។ គណៈកម្មាធិការទាំងនេះបានចូលរួមនៅក្នុងការជ្រើសរើសគម្រោងថ្មីៗ និងបានដើរតួជាសមាជិកសម្រាប់តំណែងគណៈកម្មាធិការគ្រប់គ្រងគម្រោង។

តាមរយៈភាពជាដៃគូជាមួយធនាគារពិភពលោកប្រព័ន្ធតាមដានថ្មីមួយត្រូវបានបង្កើតឡើង និងអនុម័តដើម្បីពង្រឹងគោលនយោបាយលើបញ្ហាចំបងចំនួនបី គឺការទទួលបានដីធ្លីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច។

ដើម្បីលើកកំពស់យោបល់សមូហភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន យូអិនឌីភី បានផ្តល់ការគាំទ្រដល់ការបង្កើតសម្ព័ន្ធជាតិក្រុមប្រឹក្សឃុំ-សង្កាត់។ នៅឆ្នាំ ២០០៨ ក្រុមប្រឹក្សាចំនួន ៣៧៤ ផ្សេងទៀតបានចូលរួមជាមួយសម្ព័ន្ធភាពនេះ។ ទន្ទឹមនឹងនោះ សម្ព័ន្ធភាពនេះក៏បានជួយសមាជិករបស់ខ្លួនដើម្បីបង្កើតសមាគមក្រុមប្រឹក្សានៅថ្នាក់ខេត្ត។ នៅឆ្នាំ ២០០៨ សមាគមចំនួន ៨ ផ្សេងទៀតត្រូវបានបង្កើតឡើងដែលធ្វើឱ្យចំនួនសរុបកើនឡើងដល់ ២៤ គឺមួយ ខេត្ត មានមួយ។ នៅក្នុងសមាគមថ្នាក់ខេត្តចំនួន ១០ មានស្ត្រីកាន់តំណែងជាប្រធាន ឬអនុប្រធាន។ ក្រោមកិច្ចសហការជាមួយព្រឹទ្ធសភា និងក្រសួងមហាផ្ទៃ សម្ព័ន្ធភាពនេះបានចាត់ចែងឱ្យមានវេទិកាថ្នាក់តំបន់ចំនួនបី និងវេទិកាថ្នាក់ស្រុកចំនួន ១១ ដែលផ្តល់ឱកាសសម្រាប់ តំណាងនានានៅមូលដ្ឋាន ដើម្បីលើកឡើងនូវកង្វល់របស់ពួកគេចំពោះមុខអ្នកកសាងគោលនយោបាយមកពីសភា និងក្រសួងនានា។ ប្រធានសម្ព័ន្ធភាពនេះ និងប្រតិភូពីក្រសួងមហាផ្ទៃ បានចូលរួមនៅក្នុងសន្និសីទអន្តរជាតិស្តីពីអាជ្ញាធររដ្ឋាភិបាលមូលដ្ឋាន ដែលបានធ្វើឡើង នៅប្រទេសថៃ កូរ៉េ និងហ្វីលីពីន។ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះសម្រាប់សិក្ខាសាលាថ្នាក់តំបន់អាស៊ីអាគ្នេយ៍ ដើម្បីចែករំលែកជាមួយអាជ្ញាធររដ្ឋាភិបាលមូលដ្ឋានមកពីប្រទេសឥណ្ឌូនេស៊ី នេប៉ាល់ និងហូឡង់ បទពិសោធន៍ និងការអនុវត្ត។

យូអិនឌីភី បានជួយរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលចំនួនច្រើនជាង ៣០ ស្តីពីយន្តការរដ្ឋាភិបាលនៅថ្នាក់ខេត្ត និងស្រុក ដែលបានធ្វើឡើងសម្រាប់សិក្ខាកាមចំនួនច្រើនជាង ៥០.០០០ នាក់។ ចំណេះដឹង និងជំនាញដែលផ្តល់នៅក្នុងវគ្គបណ្តុះបណ្តាលទាំងនោះរួមមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការកសាងផែនការហិរញ្ញវត្ថុ ការលើកថវិកា និងការគ្រប់គ្រងគម្រោង។ ការបណ្តុះបណ្តាលអំពីយន្តការរដ្ឋាភិបាលមូលដ្ឋានបានធ្វើឡើងសម្រាប់សិក្ខាកាមចំនួន ៦.២៩៩ នាក់ ក្នុងនោះ ១.១៣៣ នាក់ជាស្ត្រី។ សិក្ខាកាមនៅក្នុងវគ្គនេះមានសមាជិកក្រុមប្រឹក្សា ឃុំ-សង្កាត់ សមាគមក្រុមប្រឹក្សាឃុំ-សង្កាត់នៅថ្នាក់ខេត្តនិងសម្ព័ន្ធភាពជាតិនៃក្រុមប្រឹក្សា ឃុំ-សង្កាត់ អាជ្ញាធរស្រុក និងគណៈកម្មការគ្រប់គ្រងគម្រោងសហប្រតិបត្តិការអន្តរឃុំ។ សម្ព័ន្ធភាពជាតិបានបណ្តុះបណ្តាលសិក្ខាកាមចំនួន ២.៤៤៦ នាក់ ក្នុងនោះស្ត្រីមានចំនួន ៥១៦ នាក់មកពីលេខាធិការដ្ឋាននៃសម្ព័ន្ធភាពនេះ សមាគមនៅថ្នាក់ខេត្ត និងក្រុមប្រឹក្សាឃុំ។ ទន្ទឹមនឹងនេះសមាជិកនៅថ្នាក់ខេត្ត អាជ្ញាធរស្រុក បុគ្គលិកបច្ចេកទេសនៅថ្នាក់ស្រុក និងសមាជិកគណៈកម្មាធិការគ្រប់គ្រងគម្រោងសហប្រតិបត្តិការអន្តរឃុំ សរុបចំនួន ២.៣១៨ នាក់ បានទទួលការបណ្តុះបណ្តាល ឬចូលរួមនៅក្នុងវគ្គបំពាក់បំប៉នអំពីការគ្រប់គ្រងគម្រោង។

## កំណែទម្រង់គោលនយោបាយនឹងធ្វើឱ្យជីវភាពរបស់ស្ត្រីប្រសើរជាងមុន

ស្ត្រីនៅកម្ពុជា បានប្រឈមនឹងការលំបាកជាច្រើនដែលទាក់ទងនឹងសុខមាលភាព និងភាពថ្លៃថ្នូររបស់ខ្លួន។ វិសមភាពរវាងស្ត្រីនិងបុរស ត្រូវបានគេមើលឃើញថាទាក់ទងនឹងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាសំខាន់ៗខាងផ្នែកសុខភាព និងការអប់រំ ជាពិសេសស្ត្រីនៅទីជនបទ។ ប្រការនេះនាំឱ្យមានអត្រាខ្ពស់នៃមរណៈភាពមាតា និងកម្រិតទាបនៃអត្រាអក្ខរភាពក្នុងចំណោមស្ត្រីអាយុពេញវ័យ។ ដូចគ្នានេះដែរ វិសមភាពខាងយេនឌ័រមាននៅក្នុងទីផ្សារពលកម្ម តំណែងនយោបាយនិងតំណែងធ្វើសេចក្តីសម្រេចនៅកម្ពុជាផងដែរ។ ភាពក្រីក្រមានកម្រិតខ្ពស់ក្នុងចំណោមស្ត្រីធៀបនឹងបុរសនៅក្នុងគ្រប់ក្រុមទាំងអស់ដែលធ្វើសកម្មភាពសេដ្ឋកិច្ច។

យូអិនឌីភី បានធ្វើការក្រោមភាពជាដៃគូជាមួយក្រសួងកិច្ចការនារីដើម្បីគាំទ្រដល់ការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រដែលគិតគូរអំពីវិសមភាពរវាងបុរសនិងស្ត្រី។ យូអិនឌីភី បានធ្វើការជាមួយក្រសួងនេះលើការប្រាស្រ័យឆ្លើយឆ្លង និងការតស៊ូមតិ និង

ពង្រឹងសិទ្ធិអំណាចខាងសេដ្ឋកិច្ចរបស់ស្ត្រី និងតួនាទីរបស់ពួកគេនៅក្នុងការធ្វើសេចក្តីសម្រេចជាសាធារណៈនៅគ្រប់លំដាប់ថ្នាក់។ យូអិនឌីភី ក៏គាំទ្រដល់ក្រសួងនេះលើការសម្របសម្រួលជំនួយ និងប្រសិទ្ធិភាពជំនួយផងដែរ និងជាអ្នកសម្របសម្រួលរួមគ្នាសម្រាប់ក្រុមការងារបច្ចេកទេសយេនឌ័រ។

នៅឆ្នាំ ២០០៨ ក្រសួងកិច្ចការនារីបានក្លាយជាផ្នែកមួយនៃគណៈកម្មាធិការនេះសម្រាប់ពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនៅពាក់កណ្តាលអាណត្តិ (២០០៦-២០១០) ដែលជាផែនការកាត់បន្ថយភាពក្រីក្រជាមូលដ្ឋានរបស់ខ្លួន និងបានធ្វើការដើម្បីពង្រឹងសមត្ថភាពសម្រាប់ការវិភាគបែបយល់ដឹងយេនឌ័រ ការតាមដាន និងធ្វើសេចក្តីរាយការណ៍អំពីផែនការនេះ។ ជាលទ្ធផលពីការតស៊ូមតិរបស់ខ្លួនការគិតគូរអំពីសមភាពខាងយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្រុមការងារបញ្ជ្រាបយេនឌ័រតាមវិស័យត្រូវបានបង្កើតឡើងនៅក្នុងក្រសួងពាក់ព័ន្ធ និងគ្រឹះស្ថាននានា ហើយក្រសួងនេះបានគាំទ្រដល់ការរៀបចំផែនការសកម្មភាពបញ្ជ្រាបយេនឌ័រចំនួន ១១។ នៅថ្នាក់ក្រោមជាតិនៃរដ្ឋាភិបាលកង្វល់អំពីយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពបញ្ជ្រាបតាមរយៈបណ្តាញការងារភាពជាដៃគូ ការបណ្តុះបណ្តាល និងការគាំទ្រដល់ស្ថាប័ននានាដូចជាគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារដែលយូអិនឌីភីបានគាំទ្រក្រោមភាពជាដៃគូជាមួយ UNICEF ។

ការងារខាងយេនឌ័រ និងអភិបាលកិច្ចបានធ្វើឱ្យរដ្ឋលេខាធិការនៃលេខាធិការដ្ឋានមុខងារសាធារណៈចេញគោលការណ៍ណែនាំដែលតម្រូវឱ្យរាល់ការជ្រើសរើសមន្ត្រីស៊ីវិលថ្មីៗនៅក្នុងក្រសួងនានាមានពី ២០-៥០ ភាគរយជាស្ត្រី។ គោលការណ៍ណែនាំនេះត្រូវបានផ្សព្វផ្សាយ និងពិភាក្សាជាមួយអ្នកចូលរួមជាច្រើននៅក្នុងខេត្តចំនួន ១៤។ សាលាភូមិន្ទរដ្ឋបាលបានសម្រេចដាក់បញ្ចូលសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅក្នុងកម្មវិធីសិក្សារបស់ខ្លួន។

ក្រសួងកិច្ចការនារីបានធ្វើការជាមួយវិទ្យាស្ថានជាតិស្ថិតិដើម្បីដាក់បញ្ចូលការយល់ដឹងអំពីបញ្ហារបស់ស្ត្រីទៅក្នុងការអង្កេតសង្គមសេដ្ឋកិច្ចរបស់កម្ពុជាសម្រាប់ឆ្នាំ២០០៩ និងដើម្បីបណ្តុះបណ្តាលបុគ្គលិក និងអ្នកបញ្ចូលទិន្នន័យអំពីការវិភាគ និងការយល់ដឹងអំពីសក្តានុពលនៃភាពលំអៀងខាងយេនឌ័រ។ យូអិនឌីភី បានដើរតួនាទីនាំមុខនៅក្នុងការគាំទ្រដល់ក្រសួងនៅក្នុងការរៀបចំ*ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជាឆ្នាំ ២០០៨: ចំណែកស្មើភាពសម្រាប់នារី* ដែលជាចំណែកមួយនៃការស្រាវជ្រាវផ្អែកលើភស្តុតាងដោយមានអនុសាសន៍លំអិតខាងផ្នែកគោលនយោបាយសម្រាប់គ្រប់វិស័យទាំងអស់។ ការវាយតម្លៃនេះ ត្រូវបានផ្សព្វផ្សាយទូលំទូលាយនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ យូអិនឌីភី បានចូលរួមនៅក្នុងការកែសម្រួលឯកសារនារីរតនៈជំហានទី២ ដែលជាផែនការយុទ្ធសាស្ត្រប្រាំឆ្នាំលើកទី២របស់ក្រសួងនេះដើម្បីកែលម្អស្ថានភាពស្ត្រីកម្ពុជា និងបានផ្តល់យោបល់គាំទ្រសម្រាប់រៀបចំជាឯកសារនារីរតនៈ ជំហានទី៣។

យូអិនឌីភី គាំទ្រដល់កិច្ចប្រឹងប្រែងដើម្បីអភិវឌ្ឍន៍ជំនាញសម្រាប់ស្ត្រីជាមន្ត្រីស៊ីវិល និងជាបេក្ខជនបោះឆ្នោតលើការដឹកនាំ និងការគ្រប់គ្រង។ នៅឆ្នាំ ២០០៨ យូអិនឌីភី បានផ្តល់សេវាកម្មយោបល់បច្ចេកទេសការណែនាំផ្ទាល់វគ្គបណ្តុះបណ្តាល និងការហ្វឹកហ្វឺននៅកន្លែងធ្វើការផ្ទាល់ និងបានធ្វើឱ្យស្ត្រីជាមន្ត្រីក្នុងតំណែងសំខាន់ៗ និងជាអ្នកធ្វើសេចក្តីសម្រេចបានចូលរួមនៅក្នុងសិក្ខាសាលា និងសន្និសីទអន្តរជាតិ និងថ្នាក់តំបន់។ សមាគមនារីជាមន្ត្រីស៊ីវិលត្រូវបានបង្កើតឡើងដោយមានតួនាទីជាវេទិកាផ្លូវការមួយដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពួកគេ។



*រូបភាព: WCS / អេលេន័រ ប្រ៊ីកសិ៍*

*ភាពក្រីក្រមានកម្រិតខ្ពស់នៅក្នុងចំណោមស្ត្រីកម្ពុជាធៀបនឹងបុរស នៅក្នុងគ្រប់ក្រុមប្រកបសកម្មភាពសេដ្ឋកិច្ចនានា។*

*"ចាប់ពីពេលនេះតទៅ លេខាធិការដ្ឋានមុខងារសាធារណៈនឹងកំណត់ ជាកូតាសមស្របសម្រាប់បេក្ខជនជាស្ត្រី និងបុរស ដែលដាក់ពាក្យប្រឡង យកតំណែងនៅក្នុងក្រសួង និងគ្រឹះស្ថាននានា"។*

*ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងសន្និបាតប្រចាំឆ្នាំមួយនៃក្រុមប្រឹក្សាជាតិកម្ពុជាសម្រាប់ស្ត្រី។*

ដោយមានការគាំទ្រពីយូអិនឌីភី ក្រសួងកិច្ចការនារីបានចាប់ផ្តើមធ្វើការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅខេត្តកំពង់ស្ពឺដើម្បីលើកកំពស់សិទ្ធិអំណាចរបស់ស្ត្រីខាងផ្នែកសេដ្ឋកិច្ចដោយអនុវត្តសាកល្បងនូវគំរូនៃការបណ្តុះបណ្តាលជំនាញ និងសេវាកម្មអភិវឌ្ឍន៍អាជីកម្ម ដែលអាចធានានិរន្តរភាពខាងស្ថាប័ន និងខាងហិរញ្ញវត្ថុសម្រាប់ស្ត្រីជាសហគ្រិន។ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិកំពុងផ្តល់ជំនួយគាំទ្រដល់គម្រោងនេះ។ ការស្រាវជ្រាវអំពីទីផ្សារ និងការវិភាគអំពីច្រវ៉ាក់នៃតម្លៃត្រូវបានអនុវត្តចប់សព្វគ្រប់រួចហើយ។

## ក្រុមជនដែលទទួលបានការយកចិត្តទុកដាក់តិចតួច មានលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបានសេវាកម្មយុត្តិធម៌

យូអិនឌីភី កំពុងធ្វើការដើម្បីជួយប្រព័ន្ធយុត្តិធម៌របស់កម្ពុជាឱ្យកាន់តែមានប្រសិទ្ធិភាពមានការឆ្លើយតប និងអាចឱ្យក្រុមជនដែលទទួលបានការយកចិត្តទុកដាក់តិចតួចកម្ពុជាភាគច្រើនបានទទួលសេវាកម្មលើផ្នែកនេះជាពិសេសជនក្រីក្រស្ត្រី និងជនជាតិដើមភាគតិច។ ជំនួយនេះបានគាំទ្រដល់យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនៃកម្ពុជាដែលរាប់បញ្ចូលកិច្ចប្រឹងប្រែងនានាដើម្បីដាក់បញ្ចូលប្រព័ន្ធយុត្តិធម៌ផ្លូវការ និងមិនផ្លូវការ និងដើម្បីពង្រឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។សកម្មភាពទាំងនេះគឺជាការឆ្លើយតបទៅនឹងការសិក្សាទូលំទូលាយមួយដែលមានចំណងជើងថាលំនាំផ្លូវទៅរកយុត្តិធម៌សម្រាប់អ្នកក្រីក្រ ស្ត្រី និង



រូបភាព: យូអិនឌីភី/អេមុី ប្រោន

*កិច្ចសន្ទនាសហគមន៍ ផ្តល់ជាវេទិកាសម្រាប់ដោះស្រាយបញ្ហាយេនឌ័រ ដូចជាអំពើហឹង្សាក្នុងគ្រួសារ ។*

ជនជាតិដើមភាគតិចដែលបានរៀបចំដោយយូអិនឌីភី នៅក្នុងឆ្នាំ ២០០៥ តាមសំណើរបស់រដ្ឋាភិបាល ។ ការសិក្សានោះរកឃើញថា ក្រុមទាំងបីនេះមានលទ្ធភាពទាបបំផុត ក្នុងការទទួលបានសេវាយុត្តិធម៌ ។

យូអិនឌីភី ធ្វើការក្រោមភាពជាដៃគូជាមួយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ។ ក្រសួងកិច្ចការនារីក៏បានផ្តល់ការគាំទ្រយ៉ាងខ្លាំងក្លា និងការសម្របសម្រួលនៅក្នុងស្រុកទាំងនេះផងដែរ ។ ការងារនេះបានទទួលមូលនិធិពីទីភ្នាក់ងារនៃប្រទេសអេស្ប៉ាញសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងយូអិនឌីភី និងបានអនុវត្តនៅក្រោមភាពជាដៃគូជាមួយគម្រោងជំនួយផ្នែកច្បាប់នៃប្រទេសកម្ពុជា និងមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ។

យូអិនឌីភី គាំទ្ររដ្ឋាភិបាលតាមវិធីបីបែប ៖ ១) ការផ្តល់សេវាកម្មសម្រាប់ដោះស្រាយវិវាទតាមវិធីក្រៅប្រព័ន្ធតុលាការតាមរយៈកិច្ចផ្តួចផ្តើមថ្មីៗនៅមូលដ្ឋានដែលត្រូវគេស្គាល់ថាជាគណៈកម្មការដោះស្រាយវិវាទនៅថ្នាក់ឃុំ និងមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុក ២) ការពង្រឹងសិទ្ធិអំណាចដល់សហគមន៍ដើម្បីធ្វើសកម្មភាព និងសេចក្តីសម្រេចពីក្នុងចំណោមសហគមន៍តាមរយៈដំណើរការមួយដែលហៅថាកិច្ចសន្ទនាសហគមន៍ និង ៣) បង្កើនការយល់ដឹង និងការទទួលយកនូវគោលការណ៍តាមប្រពៃណីរបស់ជនជាតិដើមភាគតិច និងការដោះស្រាយការលំបាកដែលពួកគេប្រឈម ។

នៅឆ្នាំ ២០០៨ គណៈកម្មការថ្មីៗចំនួន៣៦ត្រូវបានបង្កើតឡើងដែលធ្វើឱ្យចំនួនគណៈកម្មការសរុបឡើងដល់ ៥៦ និងមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុកថ្មីៗចំនួន ១៦ ត្រូវបានបង្កើតឡើងដែលធ្វើឱ្យចំនួនសរុបនៃមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុកកើនឡើងដល់ ២០ ។ ស្ថាប័នថ្មីៗទាំងនេះត្រូវបានបង្កើតឡើងដើម្បីបំពេញគម្លាតរវាងយន្តការដែលមានស្រាប់សម្រាប់ដោះស្រាយវិវាទ និងប្រព័ន្ធយុត្តិធម៌ផ្លូវការ ។ ភាគីនៅក្នុងវិវាទអាចជ្រើសរកការសម្រុះសម្រួលដោយគណៈកម្មការនេះដែលមានសមាសភាពជាប្រធានឃុំដែលធ្វើការជាអ្នកស្ម័គ្រចិត្ត ឬមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុកដែលមានមន្ត្រីចំនួនពីររូបធ្វើការ និងដែលផ្តល់សេវាកម្មសម្រុះសម្រួលដោយឥតគិតថ្លៃ និងផ្តល់ព័ត៌មាននិងការណែនាំខាងផ្នែកច្បាប់ផងដែរ ។

ករណីដែលស្ថិតនៅក្រៅសមត្ថកិច្ចនៃមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុកត្រូវបានបញ្ជូនទៅប្រព័ន្ធយុត្តិធម៌ផ្លូវការ ។ សមាជិកគណៈកម្មការនេះ និងមន្ត្រីនៅមណ្ឌលសេវាកម្មយុត្តិធម៌បានបន្តផ្តល់ការបណ្តុះបណ្តាលអំពីជំនាញសម្រាប់ដោះស្រាយវិវាទតាមវិធីក្រៅប្រព័ន្ធតុលាការសិទ្ធិជាមូលដ្ឋាន និងទស្សនទានសំខាន់ៗអំពីច្បាប់ជាពិសេស អ្វីដែលទាក់ទងនឹងអំពើហឹង្សាក្នុងគ្រួសារ និងការលែងលះគ្នា ។

ករណីធំៗដែលស្ត្រីបានប្តឹងមានការទាក់ទងជាមួយអាពាហ៍ពិពាហ៍ បណ្តឹងបរិហារកេរ្តិ៍ ការបែងចែកមរតក វិវាទដីធ្លី និងបំណុល ។ នៅឆ្នាំ ២០០៨ មានវិវាទចំនួន ១១៩ ករណី ដែលបានដាក់ជូនទៅគណកម្មការនេះដែលរួមទាំង ៥៧២ ករណីដែលជាប់ទាក់ទងនឹងទំនាស់ដីធ្លី និង១០៨ ករណីលែងលះ ។ បញ្ហាដទៃទៀតទាក់ទងនឹងបញ្ហានានាដូចជាការបែងចែកមរតកនិងការរំលោភលើកិច្ចសន្យា ។ ក្នុងចំណោម ១១៩២ ករណី មាន ៥០៩ ករណីត្រូវបានសម្រុះសម្រួលដោយជោគជ័យ ៧៧ ករណីត្រូវបានសម្រុះសម្រួលប៉ុន្តែមិនបានសម្រេច និង ៣៤ ករណីត្រូវបានបញ្ជូនទៅស្ថាប័នដទៃទៀត ។ នៅក្នុងអំឡុងពេលដូចគ្នានេះ វិវាទចំនួន ៥៩៧ ករណីត្រូវបានដាក់ជូនទៅមណ្ឌលសេវាកម្មយុត្តិធម៌នៅថ្នាក់ ស្រុក ក្នុងនោះ ៣៩៦ ករណីជាប់ទាក់ទងនឹងទំនាស់ដីធ្លី និង១៥ករណីលែងលះ ។ ក្នុងចំណោម ៥៩៧ ករណី មាន ៨៥ ករណី ដែលបានសម្រុះសម្រួលដោយជោគជ័យ ៣២ ករណីដោះស្រាយមិនបានសម្រេច និង ២៣ ករណីត្រូវបានបញ្ជូនទៅស្ថាប័នដទៃទៀត ។

ក៏ដូចជាការគាំទ្រដល់សកម្មភាពដោះស្រាយវិវាទតាមវិធីក្រៅប្រព័ន្ធតុលាការដែរ យូអិនឌីភី បានគាំទ្រដល់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាដែលជាអង្គការមិនមែនរដ្ឋាភិបាលជាតិធ្វើការលើជំនួយផ្នែកច្បាប់នៅក្នុងការផ្តល់នូវការធ្វើជាតំណាងឱ្យស្ត្រីនៅចំពោះមុខច្បាប់នៅក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការផងដែរ ។ នៅឆ្នាំ ២០០៨ស្ត្រីបានទទួលមេធាវីធ្វើជាតំណាងមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជានៅក្នុង៨៨ករណីក្នុងខេត្តចំនួនបី ។ រហូតដល់ចុងឆ្នាំនេះ ២៤ ករណីក្នុងចំណោមករណីទាំងនេះត្រូវបានបិទបញ្ជីហើយ ៦៤ ករណីកំពុងបន្ត ។

កិច្ចសន្ទនាសហគមន៍ ជាវេទិកាដែលរៀបចំឡើងប្រចាំខែដែលក្នុងនោះអ្នកភូមិពិភាក្សាអំពីបញ្ហាទាក់ទងនឹងគ្រួសារ និងទំនាក់ទំនងខាងយេនឌ័រ ជាពិសេសដោះស្រាយបញ្ហាអំពើហឹង្សាក្នុងគ្រួសារ ។ ការពិភាក្សានានាស្ថិតក្រោមការដឹកនាំដោយអ្នកសម្របសម្រួលក្នុងភូមិដែលបានទទួលការបណ្តុះបណ្តាលអំពីវិធីសាស្ត្រនៃការពង្រឹងសមត្ថភាពសហគមន៍ដែលជាកញ្ចប់ឧបករណ៍រួមផ្សំដោយការធ្វើផែនទីភូមិការបង្ហាញខ្សែរឿងនិងការវិភាគបញ្ហាតាមរយៈដ្យាក្រាម ។

ប្រមាណ២០ភាគរយនៃស្ត្រីកម្ពុជារងគ្រោះដោយសារអំពើហឹង្សាក្នុងគ្រួសារ ប៉ុន្តែជាយូរមកហើយប្រការនេះត្រូវបានចាត់ទុកថាជាកិច្ចការផ្ទៃក្នុងសម្រាប់គ្រួសារហើយសម្រាប់មនុស្សជាច្រើនវានៅតែជាប្រធានបទដែលប៉ះមិនបាន ។ កិច្ចសន្ទនាសហគមន៍គឺជាចំណុចចាប់ផ្តើមដ៏សំខាន់មួយសម្រាប់ធ្វើឱ្យមានការចូលរួមនៅថ្នាក់មូលដ្ឋានដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរមួយនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះនៅឆ្នាំ២០០៨កិច្ចសន្ទនាសហគមន៍ប្រចាំខែបានធ្វើឡើងនៅក្នុង៧៧ភូមិក្នុងខេត្តចំនួនបីនិងដឹកនាំដោយអ្នកសម្របសម្រួលក្នុភូមិនិងមានការចូលរួម

ពីសមាជិកចំនួន ២៨៧ នាក់ នៃក្រុមគាំទ្រនេះ។ ចំនួនពាក់កណ្តាល នៃអ្នកសម្របសម្រួលក្នុងភូមិ និងសមាជិកក្រុមគាំទ្រ គឺជាស្ត្រី។

ដើម្បីលើកកំពស់សិទ្ធិទទួលបានយុត្តិធមិ សម្រាប់ជនជាតិដើមភាគតិចកម្ពុជាយូអិនឌីភីគាំទ្រឱ្យមានការបណ្តុះបណ្តាល សម្រាប់អ្នកភូមិជាជនជាតិដើមភាគតិចអំពីសិទ្ធិមនុស្ស និងការយល់ដឹងអំពីច្បាប់ព្រមទាំងផ្តល់លទ្ធភាព ដើម្បីចូលរួមនៅក្នុងវេទិកានានា ដើម្បីពិភាក្សាអំពីបញ្ហាដែលជាកង្វល់របស់ពួកគេ។ សកម្មភាពទាំងនេះ ផ្តោតលើភូមិជនជាតិដើមភាគតិចចំនួន ១២ ក្នុងនោះភូមិចំនួន ៨ ស្ថិតនៅក្នុងខេត្តរតនៈគិរី និង ៤ ក្នុងខេត្តមណ្ឌលគិរី។ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ជាអ្នកផ្តល់ការបណ្តុះបណ្តាលនេះ ដោយមានការគាំទ្របច្ចេកទេសពីយូអិនឌីភី និងរដ្ឋាភិបាល។

នៅឆ្នាំ ២០០៨ អ្នកភូមិប្រមាណ ១៨០ នាក់ ដែលរួមទាំងប្រធានភូមិ ចាស់ព្រឹទ្ធាចារ្យ និងក្រុមស្ត្រី បានទទួលការបណ្តុះបណ្តាលអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងច្បាប់នានា ដែលរួមទាំងជំពូកសំខាន់ៗដែលទាក់ទងនឹងច្បាប់ភូមិបាល និងច្បាប់ស្តីពីព្រៃឈើនៃប្រទេសកម្ពុជាផងដែរ។ ដូចគ្នានេះដែរ អាជ្ញាធរប្រពៃណីចំនួន ២៤ បានទទួលការបណ្តុះបណ្តាលអំពីជំនាញនៅក្នុងការដោះស្រាយវិវាទតាមវិធីក្រៅប្រព័ន្ធតុលាការដើម្បីពង្រឹងតួនាទីរបស់ពួកគេនៅក្នុងការសម្រុះសម្រួលវិវាទក្នុងគ្រួសារការចរចាជាមួយអ្នកមកពីខាងក្រៅ និងការអនុវត្តដំណើរការតាមនីតិវិធីរបស់តុលាការ។

ក្រោមភាពជាដៃគូជាមួយមជ្ឈមណ្ឌលអប់រំច្បាប់ សម្រាប់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន បានផ្តល់ជាវេទិកាសម្រាប់ជនជាតិដើមភាគតិច ដើម្បីជួបជាមួយមន្ត្រីនៅថ្នាក់ខេត្ត នគរបាល តំណាងមកពីតុលាការ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីពិភាក្សាអំពីបញ្ហានានា ដែលមានសារៈសំខាន់ចំពោះជនជាតិដើមភាគតិច ដូចជាវិវាទដីធ្លី។ ចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៨ តុសន្តិភាព បានធ្វើឱ្យមានការប្រគល់ដីធំជាង ១០០០ ហិកតា ទៅឱ្យសហគមន៍ជនជាតិដើមភាគតិចវិញ។ ដីទាំងនោះរាប់បញ្ចូល ដីកសិកម្ម ព្រៃអ្នកតា និងទីលានកប់សព ដែលមានសារៈសំខាន់សម្រាប់អត្តសញ្ញាណសមូហភាពនៃជនជាតិដើមភាគតិច។ សូម្បីតែបែបនេះក៏ដោយ ចំនួនករណីដែលបានសម្រុះសម្រួល តំណាងឱ្យត្រឹមតែមួយចំណែកតូចនៃដីធ្លីដែលកំពុងមានវិវាទតែប៉ុណ្ណោះ។ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ក៏បានផ្តល់ឱ្យផងដែរនូវអ្នកច្បាប់ ដើម្បីធ្វើជាតំណាងឱ្យប្រជាពលរដ្ឋជាជនជាតិ ប្រសិនបើពួកគេជាប់ពាក់ព័ន្ធនៅក្នុងប្រព័ន្ធយុត្តិធមិផ្លូវការសម្រាប់ករណីនៃទំនាស់ដីធ្លី ដែលពាក់ព័ន្ធជាមួយក្រុមហ៊ុនឯកជន ឬបុគ្គលនានា។ នៅឆ្នាំ ២០០៨ មានការផ្តល់មេធាវីនៅក្នុង ៦ ករណី។

ដើម្បីលើកទឹកចិត្តឱ្យមានការយល់ដឹង និងការទទួលយកនៅថ្នាក់ជាតិអំពីសារៈសំខាន់នៃគោលការណ៍ប្រពៃណីរបស់ជនជាតិដើមភាគតិច ភូមិចំនួន ៦ បានចូលរួមនៅក្នុងការស្រាវជ្រាវដែលបានកត់ត្រាអំពីទម្លាប់អនុវត្តគោលការណ៍ អត្តសញ្ញាណ ដីធ្លី និងសិទ្ធិរបស់ពួកគេ ដែលមានជាយូរមកហើយ។ លទ្ធផលពីការស្រាវជ្រាវនេះត្រូវបានបោះពុម្ពផ្សាយហើយមនុស្សសំខាន់ៗចំនួនជិត ៥០០ នាក់ ដែលរាប់បញ្ចូលសមាជិកព្រឹទ្ធសភា ចៅក្រមនិស្សិតផ្នែកច្បាប់ និងមន្ត្រីខេត្ត ក៏បានចូលស្តាប់បទបង្ហាញនានាអំពីប្រព័ន្ធនៃការចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិចក្បួនទំនៀមទំលាប់ និងប្រព័ន្ធដោះស្រាយទំនាស់តាមបែបប្រពៃណី។


*រូបភាព: យូអិនឌីភី/យិន សុភាព*

*ដីធ្លីនៅឃុំកោះពាក ដែលរួមមាន ដីចំការ និងទីលានកប់សព របស់ជនជាតិគ្រឹង*

## តុសន្តិភាព ជួយសម្រុះសម្រួលវិវាទដីធ្លី

*អ្នកភូមិមានការភ្ញាក់ផ្អើលភាន់ភាំង និងមានការព្រួយបារម្ភខ្លាំងៗ។ ពួកគេជឿថាពួកគេបានផ្តល់ទៅឱ្យឈ្មួញនៅក្នុងមូលដ្ឋាននូវដីសម្បទានទំហំ ១០ហិកតា ដែលជាចំណែកដីរបស់ពួកគេ ប៉ុន្តែទំហំដែលបានរានឆ្ការទំនងជាធំជាងនេះខ្លាំងណាស់។ ទីមួយ ពួកគេបានបញ្ឈប់ត្រាក់ទ័រ បន្ទាប់មកពួកគេបានអំពាវនាវដល់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងមូលដ្ឋានឱ្យជួយ។ រហូតដល់ពេលមួយបញ្ហានេះបានចូលមកដល់តុសន្តិភាពដែលជាវេទិកាមួយសម្រាប់សម្រុះសម្រួលវិវាទដីធ្លីដែលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋជាជនជាតិដើមភាគតិចកម្ពុជា។*

*នៅក្នុងឆ្នាំ ២០០៨ មានការពិភាក្សាតុសន្តិភាពចំនួន ៨ លើក ដែលនាំឱ្យមានការបង្វែរដីទំហំច្រើនជាង ១.០០០ ហិកតា ទៅឱ្យម្ចាស់ដើមវិញ។ វិវាទនេះផ្តោតជាសំខាន់លើចំណែកដីដែលត្រួតត្រាដោយជនជាតិគ្រឹងនៅក្នុងភូមិចំនួនពីរនៅក្នុងស្រុក វើនសៃ ខេត្តរតនៈគិរី។ តុសន្តិភាពមានអភិបាលខេត្តរតនៈគិរី ជាប្រធានដោយមានអ្នកសម្រុះសម្រួលមកពីមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍នៃកម្ពុជា និងយូអិនឌីភី ជាជំនួយការ។*

*ឈ្មួញបានពោលនៅក្នុងតុសន្តិភាពថាគាត់ជឿថាគាត់បានទទួលដីទំហំ ៥០០ ហិកតាពីចំណែកដីរបស់អ្នកភូមិ ដើម្បីដាំកៅស៊ូ និងដំឡូង។ ដំបូងគាត់បានទាក់ទងទៅអភិបាលស្រុកវើនសៃ ដែលបានទាក់ទងបន្តទៅប្រធានឃុំ ដែលទាក់ទងបន្តទៀតទៅប្រធានភូមិ និងចាស់ៗនៅក្នុងភូមិ។ ក្នុងនាមជាអន្តរការីអភិបាលស្រុកបានប្រគល់ប្រាក់ចំនួន៣.០០០ដុល្លា ទៅឱ្យចាស់ៗនៅក្នុងភូមិដែលឈ្មួញយល់ថាជាការបង់ថ្លៃសម្រាប់ចំណែកដីនោះ។*

*ចាស់ៗនៅក្នុងភូមិបានពោលថាពួកគាត់បានឯកភាពដោយផ្ទាល់មាត់ដើម្បីប្រគល់ដីទំហំ ១០ហិកតា និងបានផ្តិតមេដៃនៅលើក្រដាសមួយសន្លឹកដែលគ្មានសរសេរអ្វីសោះ តែនៅពេលក្រោយមកបានក្លាយជាកិច្ចសន្យាលក់ដីទំហំ ៥០០ហិកតា។ ពួកគាត់ជឿថា ឈ្មួញបានគ្រោងសាងសង់រោងចក្រមួយសម្រាប់កែច្នៃដំឡូង ដែលពួកគាត់អាចដាំនៅលើចំណែកដីរបស់ពួកគាត់សម្រាប់លក់ឱ្យឈ្មួញនោះ។ ពួកគាត់បានពោលថា គាត់មិនយល់អំពីគោលបំណងនៃការបង់ប្រាក់ ៣.០០០ដុល្លានោះឡើយ ដូច្នេះពួកគាត់បានត្រឹមតែទទួលប្រាក់នោះតែប៉ុណ្ណោះ។ ឈ្មួញបានពោលថា ខ្លួនបានវិនិយោគ ១០.០០០ ដុល្លា ដើម្បីបង្កើតការងារ។ ប៉ុន្តែអ្នកភូមិមិនចង់ធ្វើការនោះទេ ហើយគាត់ក៏មិនចង់ឈឺក្បាលដែរដូច្នេះគាត់គ្រាន់តែចង់បានប្រាក់ ៣.០០០ ដុល្លាមកវិញតែប៉ុណ្ណោះ។*

*ក្រោយពីបានឮការពិភាក្សានៅតុសន្តិភាព អភិបាលខេត្តបានសម្រេចថា អ្នកភូមិគួរតែប្រគល់ប្រាក់ ៣.០០០ ដុល្លា ទៅឱ្យម្ចាស់ដើមវិញ ហើយការរានឆ្ការត្រូវតែបញ្ឈប់។ អ្នកភូមិបានទទួលសិទ្ធិត្រួតត្រាលើដីរបស់ខ្លួនវិញ ដែលរួមទាំង ទីលានកប់សព និងដី ចំការផងដែរ។*

# ការកាត់បន្ថយភាពក្រីក្រ



*រូបភាព: WCS/អេលេន័រ ប្រិកស៏*

*សាមសិបភាគរយនៃប្រជាពលរដ្ឋកម្ពុជារស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ។ ជនក្រីក្រនៅជនបទងាយរងគ្រោះ ជាងគេពីអសន្តិសុខ ស្បៀង និងការងារធ្វើ។*

## ភាពប្រឈម

កម្ពុជាសម្រេចបាននូវកំណើនគួរឱ្យចាប់អារម្មណ៍នៅក្នុងទសវត្សរ៍កន្លងទៅប៉ុន្តែការរីកចម្រើននេះនៅពុំទាន់បានចែករំលែកស្មើគ្នានៅឡើយទេ។ **វិសមភាពសង្គម**កំពុងកើនឡើងហើយ ៣០ ភាគរយនៃប្រជាពលរដ្ឋនៅតែកំពុងរស់ក្រោមខ្សែបន្ទាត់នៃភាពក្រីក្រនៅឡើយ។ ក្រុមជនដែលទទួលបានការយកចិត្តទុកដាក់តិចតួចជាពិសេសជនក្រីក្រនៅជនបទ ស្ត្រី និងជនជាតិដើមភាគតិចងាយរងគ្រោះដោយសារអសន្តិសុខស្បៀង និងការងារធ្វើហើយរងគ្រោះពីវិសមភាពក្នុងការទទួលបានការអប់រំ និងសេវាកម្មសុខភាពផងដែរ។ ការអភិវឌ្ឍនៅជនបទត្រូវរារាំងដោយវត្ថុមានគ្រាប់មីនបង្កប់ក្នុងដី និងគ្រឿងផ្ទុះដទៃទៀតដែលជាសំណល់តាំងពីសម័យសង្គ្រាមដែលមាននៅលើផ្ទៃដីជិត ៧០០គ.ម$^{២}$។

កម្ពុជាក៏មានសក្តានុពលខាងអាជីវកម្ម ដែលនៅពុំទាន់បានទាញយកផលនៅឡើយផងដែរ ប៉ុន្តែផលិតករជាច្រើនត្រូវបានកាត់ចេញពីទីផ្សារដោយសារតែផ្លូវនៅជនបទមានស្ថានភាពមិនល្អ ការដឹកជញ្ជូនត្រូវចំណាយខ្ពស់ ការប្រាស្រ័យទាក់ទងមិនល្អ កង្វះដើមទុនសម្រាប់ការចាប់ផ្តើមអាជីវកម្ម និងការមិនអើពើចំពោះជម្រើសរបស់អតិថិជន និងថ្លៃនៅលើទីផ្សារ។ សូម្បីតែអ្នកដែលមានផលិតផលដែលអាចផ្តល់ផលចំណេញ និងអ្នកទិញមានឆន្ទៈហើយក៏ដោយពួកគេទាំងនោះច្រើនតែមិនអាចពង្រីកមូលដ្ឋានផលិតកម្មរបស់ពួកគេ ឬទទួលតម្លៃដែលគួរទទួលបានតាមរយៈការកែច្នៃជាបន្ថែមបានឡើយ។

កម្ពុជា គឺជាប្រទេសដែលពឹងផ្អែកយ៉ាងខ្លាំងលើជំនួយក្នុងចំណោមប្រទេសនានាលើពិភពលោកដោយ ៤០ ភាគរយនៃថវិការបស់រដ្ឋាភិបាលបានមកពីម្ចាស់ជំនួយ។ ការសម្របសម្រួលការតម្រង់គោលដៅ និងការតាមដានលើជំនួយនេះគឺជាប្រការចាំបាច់ដើម្បីធ្វើឱ្យវាផ្តល់ផលក្នុងកម្រិតអតិបរមា។ ដូចគ្នានេះដែររដ្ឋាភិបាលកំពុងស្វែងរកការឆ្លើយតបខាងគោលនយោបាយទូលំទូលាយជាងមុនដើម្បីដោះស្រាយការប្រឈមថ្មីៗដែលរួមទាំងការប្រឈមនានាដែលបង្កដោយការធ្វើសមាហរណកម្មទៅក្នុសេដ្ឋកិច្ចពិភពលោក និងលទ្ធភាពក្នុងការទទួលបានផលចំណេញយ៉ាងច្រើនប៉ុន្តែជាបណ្តោះអាសន្នពីឧស្សាហកម្មប្រេងកាត និងឧស្ម័ននៅក្នុងស្រុកផងដែរ។

## ការឆ្លើយតបរបស់យូអិនឌីភី

ដោយមានឆន្ទៈ ដើម្បីសម្រេចឱ្យបាននូវគោលដៅរួមនៃការអភិវឌ្ឍសហស្សវត្សរ៍ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាលនៅរវាងឆ្នាំ ២០០០ និង ២០១៥ យូអិនឌីភីបានគាំទ្ររដ្ឋាភិបាល និងវិស័យឯកជននៅក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីគិតគូរអំពីការឆ្លើយតបខាងគោលនយោបាយថ្មីៗ កសាងមូលធនសង្គម និងបង្កើនជម្រើសសម្រាប់ការចិញ្ចឹមជីវិត។

យូអិនឌីភី គាំទ្ររដ្ឋាភិបាលដើម្បីធ្វើឱ្យគោលនយោបាយពាណិជ្ជកម្មរបស់រដ្ឋាភិបាលក្លាយជាការអនុវត្តជាក់ស្តែង។ តាមរយៈការលើកកំពស់កិច្ចផ្តួចផ្តើម និងបណ្តាញអាជីវកម្មនៅ

មូលដ្ឋាន អង្គការនេះជួយផលិតករខ្នាតតូចឱ្យធ្វើការជាមួយគ្នា ដើម្បីកែលម្អផលិតផលរបស់ខ្លួននិងស្វែងរកទីផ្សារ ។ក៏ដូចជាគាំទ្រដល់ការបោសសំអាតគ្រាប់មីនផងដែរ អង្គការនេះជួយធានាថា ដីធ្លីដែលបានសំអាតពីគ្រាប់មីន ត្រូវបានបែងចែកដល់ប្រជាពលរដ្ឋដែលត្រូវការដីធ្លីបំផុត ។

យូអិនឌីភី ជួយរដ្ឋាភិបាលក្នុងការអភិវឌ្ឍសមត្ថភាពដើម្បីសម្របសម្រួល និងគ្រប់គ្រងជំនួយពីបរទេស និងធ្វើការឆ្លើយតបចំពោះឱកាសថ្មីៗខាងសេដ្ឋកិច្ច ។ អង្គការនេះបង្កើតជាជម្រើសគោលនយោបាយ ដែលអាចឱ្យរដ្ឋាភិបាលទាញយកផលចំណេញបានច្រើនបំផុតពីឱកាសខាងសេដ្ឋកិច្ច ដែលរួមទាំងសមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោក និងឧស្សាហកម្មនីស្សារណកម្មថ្មីៗ ។

ជាក់ស្តែង យូអិនឌីភី មានភាពរឹងមាំក្នុងការវិភាគចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់កិច្ចការនេះ និងធ្វើអត្តសញ្ញាណរបៀបដែលប្រជាពលរដ្ឋ និងអង្គការនានាអាចបង្កើនជំនាញរបស់ខ្លួន ។ ជំនាញធ្វើរបស់ យូអិនឌីភី នៅក្នុងផ្នែកនេះបានបង្ហាញថាមានសារៈសំខាន់ក្នុងពេលដែលទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត ធ្វើការផ្លាស់ប្តូរទៅរករិធាននៃការអភិវឌ្ឍដែលផ្អែកលើកម្មវិធី ។

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០០៨

- ក្រសួងពាណិជ្ជកម្មបានទទួលការគាំទ្រនៅក្នុងការកំណត់គោលបំណងនិងរៀបចំផែនការតាមដានអភិក្រមថ្មី គ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ដែលហៅថា អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ។
- ក្រសួងពាណិជ្ជកម្មបានធ្វើការវិភាគអំពីខ្សែច្រវ៉ាក់តម្លៃ ដើម្បីធ្វើអត្តសញ្ញាណផលិតផល ដែលមានសក្តានុពលខ្ពស់សម្រាប់ការធ្វើពាណិជ្ជកម្ម ។ សមាគមផលិតករត្រូវបានបង្កើតឡើង ដើម្បីជួយសមាជិកនានា ក្នុងការទទួលបានហិរញ្ញវត្ថុការបណ្តុះបណ្តាលព័ត៌មានអំពីទីផ្សារ និងអតិថិជន ។
- ផ្នែកគ្រប់គ្រងជំនួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កម្ពុជា បានរៀបចំរបាយការណលើកទី២ របស់កម្ពុជា ស្តីពីប្រសិទ្ធិភាពជំនួយ និងបានរៀបចំផែនការលំអិតមួយសម្រាប់អភិវឌ្ឍន៍ចំណេះដឹង និងជំនាញ ។
- សន្និសីទអន្តរជាតិមួយ ស្តីពីសក្តានុពលឧស្សាហកម្មប្រេងកាតនិងឧស្ម័ន ដើម្បីកាត់បន្ថយភាពក្រីក្របានសម្រួលឱ្យមានការចែករំលែកព័ត៌មាន និងកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍នានា ។
- ផ្ទៃដីទំហំ ៦,៧៨ គ.ម$^{២}$ ដែលស្ថិតក្រោមឥទ្ធិពលនៃគ្រាប់មីននិងគ្រឿងផ្ទុះនានាដែលនៅសល់ពីសម័យសង្គ្រាម ត្រូវបានបោសសំអាត ។
- មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជាបានកំចាត់ និងបំផ្លាញគ្រាប់ប្រឆាំងមនុស្សចំនួន ៨.៩២៥គ្រាប់ មីនប្រឆាំងរថក្រោះចំនួន ២២០គ្រាប់ និងយុទ្ធភណ្ឌមិនទាន់ផ្ទុះចំនួន ៣៤.១៣៧គ្រាប់ តាមរយៈការគាំទ្រពីយូអិនឌីភី ។
- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនរងគ្រោះដោយសារមីន បានរៀបចំស្តង់ដារបន្ថែមទៀត និងបានបង្កើនការតាមដានរបស់ខ្លួនលើប្រតិបត្តិការ ដែលអនុវត្តដោយប្រតិបត្តិករបោសសំអាតគ្រាប់មីនដែលមានអាជ្ញាប័ណ្ណ ។



រូបភាព: យូអិនឌីភី/សែរុស ខ័រនុត

## ការនាំចេញនឹងបង្កើនប្រាក់ចំណូល បង្កើតការងារសម្រាប់ប្រជាជនកម្ពុជា

ពាណិជ្ជកម្មអន្តរជាតិផ្តល់ឱកាសសម្រាប់កម្ពុជាដើម្បីធ្វើការអភិវឌ្ឍតាមទម្រង់ដែលនឹងបង្កើនផលចំណូលបង្កើនភាពសំបូរបែបនៃសេដ្ឋកិច្ច និងការងារធ្វើ ។ ជាក់ស្តែងការនាំចេញបានផ្តល់ផលចំណូល ៨០ ភាគរយនៃផលទុនក្នុងស្រុកសរុបរបស់កម្ពុជា និងបង្ហាញពីសេចក្តីសង្ឃឹមអំពីកំណើនបន្ថែមទៀតសម្រាប់អនាគត ។ យូអិនឌីភី គាំទ្រដល់កិច្ចប្រឹងប្រែងរបស់កម្ពុជាដើម្បីទាញយកផលប្រយោជន៍ឱ្យបានច្រើនបំផុតពីសមាជិកភាពរបស់ខ្លួននៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក និងក្នុងការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក ។

កម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួនមានការប្តេជ្ញាអនុវត្តអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មដែលស្គាល់ថា Trade SWAP ដែលមានគោលដៅធ្វើសុខុដុមនីយកម្មនូវរាល់កិច្ចប្រឹងប្រែងរបស់ម្ចាស់ជំនួយនានា និងបង្កើនប្រសិទ្ធិភាពនៃជំនួយទាំងនោះ ។ ចំណុចស្នូលនៃអភិក្រមនោះគឺការវិភាគនៅឆ្នាំ២០០៧សម្រាប់ការរៀបចំយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មដែលបានរៀបចំឡើងដោយក្រសួងពាណិជ្ជកម្មនិងគាំទ្រពីយូអិនឌីភី ។ យុទ្ធសាស្ត្រនេះធ្វើអត្តសញ្ញាណផលិតផល និងសេវាកម្មជាអាទិភាពចំនួន១៩ដែលមានសក្តានុពលសម្រាប់ការនាំចេញដែលរួមទាំងសម្លៀកបំពាក់ស្បែកជើងអង្ករ កៅស៊ូ ត្រី ផលិតផលឈើ និងទេសចរណ៍ ។ យុទ្ធសាស្ត្រនេះធ្វើអត្តសញ្ញាណទីផ្សារនាំចេញនៅអាស៊ី មជ្ឈិមបូព៌ា ប្រទេសនានានៃអតីតសហភាពសូវៀត និងអាហ្វ្រិកផងដែរ ។

*សរសៃសូត្រ ត្រូវបានធ្វើអត្តសញ្ញាណនៅក្នុងយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់កម្ពុជាថា ជាផលិតផលដែលមានអាទិភាព និងកំពុងអភិវឌ្ឍន៍សម្រាប់ការនាំចេញ*

*"ផលិតកររបស់យើង ត្រូវតែរៀនបង្កើនផលិតភាព និងកាត់បន្ថយថ្លៃផលិតក្នុងមួយឯកត្តាផលិតផលនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយចាប់យកបច្ចេកវិទ្យាថ្មីៗ និងប្រើប្រាស់កម្មករដែលបានទទួលការបណ្តុះបណ្តាលឱ្យកាន់តែមានប្រសិទ្ធិភាពជាងមុន" ។*

*ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម*



រូបភាព: ក្រសួងពាណិជ្ជកម្ម/លីម សុភ័ក្រ

*អ្នកភូមិមានការលំបាកក្នុងការទទួលបានតម្លៃខ្ពស់ពីការវិនិយោគពេលវេលារបស់ពួកគេនៅក្នុងការផលិតប្រហុក*

## គ្រឿងផ្សំចាស់ ផ្តល់ជាគន្លឹះសម្រាប់អាជីវកម្មបែបថ្មី

*ប្រហុកដែលជាផលិតផលត្រីផ្អាប់គឺជារសជាតិសំខាន់នៅក្នុងម្ហូបរបស់ខ្មែរ ។ វាជាផលិតផលចំបងសម្រាប់ជនកម្ពុជាដូចជាស្រាសម្រាប់ជនជាតិបារាំង ទឹកស៊ីអ៊ីវសម្រាប់ ជនជាតិចិន ប្រេងអូលីវសម្រាប់ជនជាតិអ៊ីតាលី និងទឹកប៉េងប៉ោះសម្រាប់ជនជាតិអាមេរិកដូច្នោះដែរ ។ អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយដែលគ្រួសារនានានៅក្នុងឃុំកំពង់ឃ្លាំងនៅលើបឹងទន្លេសាបផលិតប្រហុកលេខមួយដែលមានសប្បុស និងគ្មានឆ្អឹង ។ ពួកគេហូតឆ្អឹងចេញពីត្រីកំភ្លាញល្អិតៗ ប្រឡាក់សាច់ត្រីជាមួយអំបិលផ្អាប់ទុក រយៈពេលបីខែរួចជ្រុំវាដូចជាផ្លែទំពាំងបាយជូរនៅក្នុងការផលិតជាស្រាដូច្នោះដែរ ។*

*ប៉ុន្តែ ផលិតផលនេះបានថយចុះ ។ មានតែប្រមាណ ២០ គ្រួសារក្នុងចំណោមជិត ២.០០០ គ្រួសារនៅក្នុងឃុំក្រីក្រមួយជិតក្រុងសៀមរាបដែលនៅបន្តផលិតប្រហុកបែបនេះ ។ គ្រួសារជាច្រើនបានយល់ឃើញថាវាងាយស្រួលនិងផ្តល់ផលចំណេញច្រើនជាង ប្រសិនបើពួកគេលក់ត្រីក្នុងបរិមាណច្រើនទៅឱ្យឈ្មួញលក់ដុំ ដែលលក់ជាបន្តទៅតាមព្រំដែនប្រទេសថៃ ។ សូម្បីតែពួកគេចំណាយពេលវេលា និងការប្រឹងប្រែងដើម្បីធ្វើប្រហុកក៏ដោយ គឺឈ្មួញកណ្តាលដែលជាអ្នកទទួលបានភាគច្រើននៃផលចំណេញនេះ ។*

*គម្រោង TRADE នៃក្រសួងពាណិជកម្មក្រោមការគាំទ្រពីយូអិនឌីភីមានគោលដៅប្រែក្រឡាស់ស្ថានភាពនេះ ។ នៅឆ្នាំ២០០៨ អ្នកភូមិបានចាប់ផ្តើមដំណើរការបង្កើតសមាគមអ្នកផលិតប្រហុកនៅកំពង់ឃ្លាំងដែលនឹងជួយសមាជិកដើម្បីកែលម្អស្តង់ដារ អនាម័យលទ្ធភាពទទួលបានហិរញ្ញប្បទានខ្នាតតូចគិតគូរអំពីយុទ្ធសាស្ត្រទីផ្សារ និងចាត់ចែងបង្កើតការវេចខ្ចប់ និងការដាក់ស្លាកសញ្ញា ។*

*ប្រហុកនេះនឹងត្រូវផ្សព្វផ្សាយនៅក្រោមកម្មវិធី "ភូមិមួយ ផលិតផលមួយ" ព្រមទាំងនឹងបានទទួលផ្លាកសញ្ញាមួយនៅក្រោមប្រព័ន្ធសន្ទស្សន៍ភូមិសាស្ត្រថ្មីដែលនឹងធានាភាពត្រឹមត្រូវនៃប្រភពដើម ។*

*លោក ទុយ ញាម អាយុ ៥៩ ឆ្នាំ ដែលជាប្រធានឃុំបានពោលថាសមាគមនេះនឹងផ្តល់ជាបណ្តាញសុវត្ថិភាព និងបង្កើតជាគំនិតរួមគ្នាមួយនៅក្នុងសហគមន៍នេសាទត្រីនៅក្នុងស្រុកនេះ ។ "អ្នកនេសាទ និងអ្នកផលិតប្រហុកនឹងអាចទទួលផលចំណេញកាន់តែច្រើនពីផលត្រីរបស់ខ្លួន ។ ប្រាក់ចំណូលកាន់តែខ្ពស់នឹងជួយកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ពួកគេ" ។*

*ឯកឧត្តម ម៉ៅ ថូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដែលបានដឹកនាំគម្រោងTRADE មានប្រសាសន៍ថាក្រសួងចង់បង្កើតទំនាក់ទំនងជាមួយសហគមនជនបទដើម្បីបង្កើតសមាគមកសិ-ពាណិជ្ជកម្មឱ្យបានកាន់តែច្រើនឡើង ។ "សមាគមនានានឹងលើកកំពស់ផលិតផលនៅក្នុងមូលដ្ឋាន និងបង្កើនបរិមាណផលិតផលដើម្បីឱ្យអ្នកភូមិក្រីក្រអាចទទួលបានប្រាក់ចំណូលកាន់តែច្រើនឡើង" ។*

ដោយមានយុទ្ធសាស្ត្រនេះជាគោល យូអិនឌីភី បានធ្វើការជាមួយក្រសួងពាណិជ្ជកម្ម ដើម្បីអភិវឌ្ឍន៍សមត្ថភាពរបស់កម្ពុជាក្នុងការផ្គត់ផ្គង់ផលិតផល និងសេវាកម្មសម្រាប់ការនាំចេញ និងដើម្បីអភិវឌ្ឍន៍ចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់គ្រប់គ្រងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ។ គោលបំណង និងផែនការ តាមដានសម្រាប់អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មត្រូវបានរៀបចំរួចជាស្រេចហើយក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធដទៃទៀត បានពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ពួកគេនៅបីលំដាប់: ស្ថាប័ន ប្រព័ន្ធ និងបុគ្គល ។ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បានទទួលការណែនាំ និងការហ្វឹកហ្វឺន ដើម្បីជួយឱ្យនាយកដ្ឋាននេះបំពេញមុខនាទីរបស់ខ្លួនក្នុងនាមជាលេខាធិការដ្ឋានសម្រាប់អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម និងជាអ្នកសម្របសម្រួលជំនួយសម្រាប់ពាណិជ្ជកម្ម ។

ការវាយតម្លៃមួយ នៅក្នុងនាយកដ្ឋានចំនួនបួននៃក្រសួងពាណិជ្ជកម្ម បានស្តែងចេញជាផែនការច្នៃប្រឌិតមួយសម្រាប់អភិវឌ្ឍន៍ជំនាញ និងចំណេះដឹងដែលអាចចម្លងយកទៅអនុវត្តនៅក្នុងក្រសួងដទៃទៀត ដែលសកម្មនៅក្នុងគម្រោងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ។ ការសិក្សានេះ ក៏បានបង្កើតជាទិន្នន័យគោលដែលនឹងត្រូវយកទៅប្រើប្រាស់ផងដែរ ដើម្បីតាមដានការអនុវត្តផែនការនេះ ។ ការងារនេះបានទាក់ទាញការយកចិត្តទុកដាក់ជាអន្តរជាតិដោយប្រទេសនេប៉ាល់ និងឡាវបានបញ្ជូនប្រតិភូជាផ្លូវការមករៀនសូត្រពីបទពិសោធន៍របស់កម្ពុជាក្នុងការអភិវឌ្ឍពាណិជ្ជកម្ម ។ យូអិនឌីភី បានរៀបរៀងឯកសារគោលនយោបាយក្រោមចំណងជើងថា "ធ្វើឱ្យការសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មមានដំណើរការ" ។

ផ្អែកលើបញ្ជីមុខផលិតផល ១៩ មុខ ដែលមានអាទិភាពជាយុទ្ធសាស្ត្រសម្រាប់ពាណិជ្ជកម្ម យូអិនឌីភី បានគាំទ្រឱ្យមានការពិគ្រោះយោបល់ជាបន្តបន្ទាប់នៅក្នុងទីជនបទចំនួនបីកន្លែង ដែលបានធ្វើអត្តសញ្ញាណផលិតផលសំខាន់ៗ ដែលត្រូវទទួលបានការគាំទ្រ ។ ការវាយតម្លៃខ្សែច្រវ៉ាក់នៃតម្លៃ ត្រូវបានចាត់ចែងឡើងសម្រាប់ ដំឡូង សណ្តែកសៀង ពោត និងប្រហុក ហើយសមាគមផលិតករក្នុងស្រុក ក៏ត្រូវបានធ្វើអត្តសញ្ញាណសម្រាប់ទទួលការគាំទ្រទៅអនាគតផងដែរ ។ យូអិនឌីភី បានជួយបង្កើតឱ្យមានការសន្ទនានៅថ្នាក់ខេត្ត រវាងវិស័យសាធារណៈ និងឯកជន ដើម្បីបង្កើនការយល់ដឹងអំពីបញ្ហានានាដែលកំពុងប្រឈមចំពោះមុខតំណាងនានានៃវិស័យផលិតផលក្នុងស្រុក និងសមាគមអាជីវករ និងដើម្បីធ្វើអត្តសញ្ញាណអំពីថា តើមន្ទីរនានានៅថ្នាក់ខេត្តអាចឆ្លើយតបបែបណាទៅនឹងតម្រូវការចាំបាច់ទាំងនេះ ។ អ្នកផលិតស្រូវ និងអ្នកកិនស្រូវមកពីខេត្តចំនួនប្រាំមួយបានចូលរួមជាមួយបេសកកម្មរបស់ក្រសួងពាណិជ្ជកម្មទៅប្រទេសសេនេហ្គាល់ ដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្មចំបងមួយនៅភូមិភាគខាងលិច និងភាគកណ្តាលនៃទ្វីបអាហ្វ្រិក ។ ជាលទ្ធផល ប្រទេសសេនេហ្គាល់បានសំដែងចំណាប់អារម្មណ៍នៅក្នុងការនាំចូលអង្ករ ៣.០០០ តោន ពីប្រទេសកម្ពុជា ។

# ទូរស័ព្ទចល័តភ្ជាប់ទំនាក់ទំនងរវាងផលិតករនៅជនបទ ជាមួយទីផ្សារថ្មីៗ

នៅក្នុងទីជនបទនៃប្រទេសកម្ពុជា ផ្លូវថ្នល់ដែលមានសភាពទ្រុឌទ្រោម និងកង្វះហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការប្រាស្រ័យឆ្លើយឆ្លង បានធ្វើឱ្យកសិករមានការលំបាកក្នុងការលក់ផលិតផលរបស់ខ្លួនឱ្យបានថ្លៃខ្ពស់។ ការឆ្លើយតបមួយចំពោះប្រការនេះ គឺកិច្ចផ្តួចផ្តើមទូរស័ព្ទចល័តតាមភូមិ ដែលជាបណ្តាញមួយប្រកបដោយភាពច្នៃប្រឌិត និងបានទទួលការគាំទ្រពីយូអិនឌីភីក្រោមភាពជាដៃគូជាមួយ GTZ ដែលបានពង្រីកបណ្តាញទូរស័ព្ទចល័តរហូតដល់ទីជនបទដែលបើពុំនោះ អ្នកជនបទទាំងនោះនឹងមិនបានទទួលការគាំទ្របែបនេះឡើយ។ នៅឆ្នាំ ២០០៨ ការគ្រប់គ្រងកិច្ចផ្តួចផ្តើមទូរស័ព្ទនៅតាមភូមិបានប្តូរទៅឱ្យក្រុមហ៊ុនឯកជនថ្មីមួយ។ នៅក្រោមទំនាក់ទំនងរបស់ពួកគេសហគ្រិនជនបទចំនួនប្រមាណ ១២០០ បានទិញសេវាប្រើប្រាស់បណ្តាញ និងទូរស័ព្ទចល័ត ដើម្បីផ្តល់លទ្ធភាពប្រសើរជាងមុនក្នុងការប្រាស្រ័យឆ្លើយឆ្លងសម្រាប់សមាជិកសហគមន៍។ សហគ្រាសទូរស័ព្ទនេះ ផ្តល់នូវប្រភពថ្មីនៃប្រាក់ចំណូលសម្រាប់ប្រតិបត្តិករទាំងនោះ ដែលភាគច្រើនបាន និងកំពុងប្រតិបត្តិការអាជីវកម្មខ្នាតតូចរួចទៅហើយ ដូចជាតូបលក់រាយនូវផ្លែឈើ និងបន្លែ។ ប្រមាណ៩០ភាគរយនៃប្រតិបត្តិករទាំងនោះគឺជាស្ត្រីហើយអ្នកទាំងនោះភាគច្រើនប្រើប្រាស់ផលចំណេញទាំងនេះដើម្បីកែលម្អអាជីវកម្មរបស់ខ្លួន ឬបញ្ជូនកូនទៅសាលារៀន។

ប្រតិបត្តិករទូរស័ព្ទនៅក្នុងភូមិ ក៏បានចូលរួមទទួលឱកាសស្របគ្នានេះផងដែរ ពោល គឺតូបផ្តល់ព័ត៌មានសន្លឹកពណ៌លឿង ដែលអាចឱ្យប្រតិបត្តិករទូរស័ព្ទ អាចតភ្ជាប់ទៅអតិថិជន ជាមួយអ្នកផ្តល់ទំនិញ និងសេវាកម្មនៅមូលដ្ឋាន និងដើម្បីស្វែងរកព័ត៌មានថ្មីៗសម្រាប់ចុះក្នុងបញ្ជី ស្តីពីអាជីវកម្មនៅលើសៀវភៅទូរស័ព្ទទំព័រលឿង។ យូអិនឌីភី បានគាំទ្រឱ្យមានការបង្កើត "I-booths" និងបានសម្រួលឱ្យមានចំណងទាក់ទងផងដែរ រវាងទំព័រលឿង និងគម្រោងព័ត៌មានអំពីទីផ្សារកសិកម្ម ដែលគាំទ្រដោយមូលនិធិពីប្រទេសកាណាដា និងដែលផ្តល់ព័ត៌មានប្រចាំថ្ងៃ អំពីថ្លៃផ្លែឈើ និងបន្លែ តាមរយៈសេវាកម្មជាសារខ្លីៗ (SMS)។ ដូច្នេះ ប្រតិបត្តិករអាចផ្តល់សេវាដ៏មានប្រយោជន៍តាមរយៈការបង្កើនលំហូរព័ត៌មានអំពីទីផ្សារផងដែរ។

យូអិនឌីភី ក៏បានគាំទ្រឱ្យមានការរៀបចំដោយជោគជ័យផងដែរនូវសន្និសីទជាតិមួយ ស្តីពីការទទួលខុសត្រូវរបស់សាជីវកម្មលើផ្នែកសង្គមកិច្ច ដែលមានរបាយការណ៍ក្រោមចំណងជើងថា ***ការបង្កើតតម្លៃសម្រាប់ទាំងអស់គ្នា : យុទ្ធសាស្ត្រសម្រាប់ធ្វើអាជីវកម្មជាមួយអ្នកក្រ***ត្រូវបានប្រកាសផ្សាយផងដែរ។ របាយការណ៍នេះដែលបានរៀបចំឡើងដោយកិច្ចផ្តួចផ្តើមរបស់យូអិនឌីភី អំពីការបង្កើតទីផ្សារសម្រាប់ទាំងអស់គ្នា បានរំលេចនូវករណីសិក្សាចំនួន ៥០ ដែលបង្ហាញពីជោគជ័យនៃការស្វែងរកផលចំណូល និងឥទ្ធិពលខាងផ្នែកសង្គមពីសំណាក់ក្រុមហ៊ុននៅមូលដ្ឋាន និងអន្តរជាតិ ទាំងខ្នាតតូច និងមធ្យម ក៏ដូចជាសាជីវកម្មពហុជាតិផងដែរ។

ការស្រាវជ្រាវផ្តល់ឱ្យរដ្ឋាភិបាលនូវជម្រើសគោលនយោបាយច្រើនជាងមុន ដើម្បីគាំទ្រដល់យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ យូអិនឌីភី បានចាត់ចែងឱ្យមានការស្រាវជ្រាវ




*ផលចំណូលដែលបានពីប្រេងកាតមានសក្តានុពលក្នុងការកាត់បន្ថយភាពក្រីក្របានជាច្រើន*

និងវិភាគអំពីគោលនយោបាយចុងក្រោយមួយសម្រាប់វិស័យនានាដែលមានសារៈសំខាន់ជាគន្លឹះនៅក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ការស្រាវជ្រាវនេះលើកឡើងអំពីអាទិភាពជាតិ ដោយផ្តល់ចំណេះដឹងថ្មីៗ ក៏ដូចជា វេទិកាសម្រាប់ប្រែក្លាយគោលគំនិតនានាទៅជាសកម្មភាពផងដែរ។ មួយក្នុងចំណោមអាទិភាពនានាបែបនេះ គឺលទ្ធភាពក្នុងការរុករកប្រេងកាត និងឧស្ម័ន ដែលផ្តល់នូវការរំពឹងទុកជាផលចំណូល ដើម្បីជួយកម្ពុជាក្នុងការដោះស្រាយបញ្ហានៃភាពក្រីក្រ។

នៅឆ្នាំ ២០០៨ សន្និសីទអន្តរជាតិជាន់ខ្ពស់មួយឈ្មោះថា **បង្កើនការកាត់បន្ថយភាពក្រីក្រតាមរយៈផលចំណូលពីប្រេងកាត និងឧស្ម័ន : បទពិសោធន៍ប្រៀបធៀបពីប្រទេសនានា** បានផ្តោតលើចំណេះដឹងខាងបច្ចេកទេស និងសេដ្ឋកិច្ចឥទ្ធិពលខាងសង្គម និងបរិស្ថានសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍បណ្តាលពីការរុករកប្រេងកាត។ វេទិកានេះ ត្រូវបានរៀបចំឡើងដោយយូអិនឌីភី ក្រោមភាពជាដៃគូជាមួយអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ទីភ្នាក់ងារនៃប្រទេសន័រវេសសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អគ្គនាយកដ្ឋានប្រេងកាតនៃប្រទេសន័រវេស និងមូលនិធិ Petrad នៃរដ្ឋាភិបាលប្រទេសន័រវេស។ ការវិភាគ និងការពិភាក្សាបានបង្ហាញអំពីការពាក់ព័ន្ធជាពិសេសជាមួយអ្នកកសាងគោលនយោបាយពីប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ជាមួយធនធានធម្មជាតិ ដែលរួមទាំងតំណាងនានាមកពីប្រទេសទីម័រខាងកើត ម៉ុងហ្គោលី និងប្រទេសសាវតូម៉េ និងព្រីនស៊ីពេផងដែរ។

មន្ត្រីមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ CNPA និង SNEC បានចូលរួមនៅក្នុងទស្សនកិច្ចសិក្សា ដែលផ្តល់មូលនិធិដោយទីភ្នាក់ងារនៃប្រទេសន័រវេស សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

*"វាមិនគ្រាន់តែជាការបណ្តុះបណ្តាលប៉ុណ្ណោះទេ ប៉ុន្តែ វាគឺជាការចែករំលែកបទពិសោធន៍ និងកសាងទំនាក់ទំនងគ្នា"។*

*លោក នុត មុន្នីរ័ត្ន មន្ត្រីផ្នែកគោលនយោបាយនៃក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កម្ពុជា ដែលបានពោលនៅក្នុងសន្និសីទ នាខែមីនា ស្តីពីប្រេងកាត និងឧស្ម័ន។*



រូបភាព: យូអិនឌីភី/អ៊ីសាបែល លេសេរ

*អ្នកតម្បាញនៅខេត្តរតនៈគិរី អាចបម្លែងវត្ថុសិប្បកម្មរបស់ខ្លួនឱ្យទៅជាឧស្សាហកម្មមួយ ដែលផ្គត់ផ្គង់ដល់អ្នកទេសចរអន្តរជាតិ*

## សិល្បៈប្រកបដោយការច្នៃប្រឌិត គឺជាក្តីសង្ឃឹមសម្រាប់ការនាំចេញ

*សិល្បៈបុរាណ ធ្លាប់រីកលូតលាស់នៅទូទាំងប្រទេសកម្ពុជា ប៉ុន្តែត្រូវបានបំផ្លាញស្ទើរតែទាំងស្រុងដោយខ្មែរក្រហមនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០។ សព្វថ្ងៃនេះ វត្ថុសិល្បៈជាច្រើន និងសិល្បៈសំដែងកំពុងស្ថិតក្នុងរបត់ដែលឈានទៅបាត់បង់។ បើទោះជាវិស័យទេសចរណ៍ផ្តល់នូវទីផ្សារដែលមានលទ្ធភាពទទួលយកហើយក៏ដោយ សិប្បករមើលឃើញថា ពួកគេនៅតែប្រឈមនឹងការលំបាកនៅឡើយក្នុងការទ្រទ្រង់ខ្លួនឯង ដោយពឹងផ្អែកតែលើការងាររបស់ខ្លួននៅក្នុងឧស្សាហកម្មមួយ ដែលភាគច្រើនលើសលប់កាន់កាប់ដោយជនបរទេស និងភ្នាក់ងារទេសចរអន្តរជាតិ។*

*កិច្ចប្រឹងប្រែងថ្មីមួយ ដើម្បីចងភ្ជាប់វិស័យទេសចរណ៍ជាមួយឧស្សាហកម្មច្នៃប្រឌិតរបស់កម្ពុជា ត្រូវបានប្រកាសចាប់ផ្តើមនៅក្នុងឆ្នាំ២០០៨។ កម្មវិធីនេះ គឺជាកិច្ចសហប្រតិបត្តិការដែលដឹកនាំដោយក្រសួងចំនួនបួនគឺ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ពាណិជ្ជកម្ម កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រោមភាពជាដៃគូជាមួយអង្គការ UNESCO, ILO, FAO និងយូអិនឌីភី។ ដោយផ្តោតលើខេត្តចំនួនបួន គឺ រតនៈគិរី មណ្ឌលគិរី កំពង់ធំ និងព្រះវិហារ កម្មវិធីនេះមានគោលដៅធ្វើឱ្យមានសកម្មភាពរស់រវើកឡើងវិញនូវសម្បត្តិវប្បធម៌របស់កម្ពុជា លើកកំពស់កំណើនសេដ្ឋកិច្ច បង្កើតការងារធ្វើ និងកាត់បន្ថយភាពក្រីក្រ។*

*កម្មវិធីនេះមានសក្តានុពលជាពិសេស ដើម្បីពង្រឹងអត្តសញ្ញាណវប្បធម៌នៃជនជាតិដើមភាគតិចកម្ពុជា និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី ដែលជាមនុស្សភាគច្រើននៅក្នុងកម្លាំងពលកម្មខាងផ្នែកវប្បធម៌របស់កម្ពុជា។ ឧស្សាហកម្មទាំងនេះ ភាគច្រើនមានលក្ខណៈជាសិប្បកម្មតាមគ្រួសារជាប្រពៃណី និងមានផលចំណូលទាបសម្រាប់ផលិតករ និងផលចំណេញខ្ពស់សម្រាប់ឈ្មួញកណ្តាល និងពាណិជ្ជករ។ ដូច្នេះជំហានគន្លឹះ គឺត្រូវលើកកំពស់ខ្សែច្រវ៉ាក់នៃតម្លៃ ដើម្បីធានាថាផលិតករទទួលបានភាគចំណែកជាផលចំណេញក្នុងអត្រាសមស្រប។*

*ក្រោមភាពជាដៃគូជាមួយក្រសួងពាណិជ្ជកម្ម យូអិនឌីភី នឹងសម្របសម្រួលឱ្យមានការពិភាក្សារវាងវិស័យសាធារណៈ និងឯកជននៅថ្នាក់ខេត្ត ដើម្បីធ្វើឱ្យរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន អាចយល់ដឹងបាន និងឆ្លើយតបបានកាន់តែប្រសើរទៅនឹងបញ្ហាដែលវិស័យឯកជនកំពុងប្រឈម។អង្គការនេះក៏នឹងប្រើប្រាស់ការវិភាគខ្សែច្រវ៉ាក់នៃតម្លៃផងដែរ ដើម្បីជ្រើសរើសយកផលិតផល និងសេវាកម្មនានា ដែលមានសក្តានុពលសម្រាប់ពាណិជ្ជកម្ម។ ផលិតផល និងសេវាកម្មទាំងនេះ ក្លាយជាការយកចិត្តទុកដាក់នៃកិច្ចប្រឹងប្រែង ដើម្បីអនុវត្តច្បាប់ពាណិជ្ជកម្ម និងនីតិវិធីនាំចេញ តាមទម្រង់ដែលមានស៊ីសង្វាក់គ្នា។*

ដែលបានផ្តោតលើបញ្ហានៃការកសាងសមត្ថភាពសម្រាប់មូលនិធិប្រេងកាត និងរួមបញ្ចូលការពិភាក្សាអំពីកិច្ចផ្តួចផ្តើមតម្លាភាពឧស្សហកម្មនីស្សារណកម្មផងដែរ។ កិច្ចផ្តួចផ្តើមដើម្បីឱ្យមានការពិភាក្សាអំពីគោលនយោបាយនៅសកលវិទ្យាល័យ Columbia បានផ្តល់ការអនុញ្ញាតឱ្យ យូអិនឌីភី ធ្វើការប្រែសម្រួលជាភាសាខ្មែរ និងបោះពុម្ពផ្សាយសៀវភៅដែលមានចំណងជើងថា "ការធានាឱ្យមានការជូនពរពីធនធាន" ដែលនិពន្ធដោយជ័យលាភីរង្វាន់ណូបែលបណ្ឌិត Joseph E. Stiglitz ។

យូអិនឌីភី បានអនុវត្តភាពជាដៃគូជាមួយ SNEC ដើម្បី រៀបចំរបាយការណ៍មួយឈ្មោះ***ភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជា : ការជម្រុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ***ដែលជាការវិភាគមួយអំពីការលំបាកដែលប្រទេសកម្ពុជាកំពុងប្រឈមនៅក្នុងកាលៈទេសៈនៃវិបត្តិហិរញ្ញវត្ថុពិភពលោក។ ការស្រាវជ្រាវនេះបានផ្អែកលើសិក្ខាសាលាពិគ្រោះយោបល់មួយជាមួយក្រសួងចំនួនប្រាំបួន និងដៃគូអភិវឌ្ឍន៍ និងតំណាងនានាមកពីវិស័យឯកជនចំនួនច្រើនជាង ៤០។ ក្រោមការគាំទ្រពីយូអិនឌីភី SNEC បានរៀបចំការស្រាវជ្រាវអំពីទីផ្សារពលកម្ម និងភាពគ្មានការងាររបស់យុវជន។ ក្រសួងផែនការបានដឹកនាំការពិភាក្សានៅថ្នាក់ខេត្ត ស្រុក និងឃុំលើរបាយការណ៍អភិវឌ្ឍន៍មនុស្សរបស់កម្ពុជាឆ្នាំ ២០០៧ : ការពង្រីកជម្រើសសម្រាប់អ្នកជនបទដែលត្រូវបានបោះពុម្ពផ្សាយក្រោមការគាំទ្រពី យូអិនឌីភី។

## ការសម្របសម្រួលបង្កើនប្រសិទ្ធិភាពជំនួយ

កម្ពុជាពឹងផ្អែកជាខ្លាំងលើជំនួយអភិវឌ្ឍន៍មកពីខាងក្រៅប្រទេស ដោយមួយភាគធំនៃថវិកាអភិវឌ្ឍន៍របស់ខ្លួនបានមកពីម្ចាស់ជំនួយ។ ជំនួយក៏មានលក្ខណៈរាយប៉ាយយ៉ាងខ្លាំងផងដែរ ដោយមានការសម្របសម្រួលតិចតួចក្នុងចំណោមម្ចាស់ជំនួយ ធៀបនឹងប្រទេសផ្សេងទៀតដែលមានការពឹងផ្អែកលើជំនួយ។ យូអិនឌីភី អនុវត្តភាពជាដៃគូជាមួយប្រទេសអូស្ត្រាលី កាណាដា DFID និងនូវ៉ែលហ្សេឡង់ ដើម្បីគាំទ្រក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កម្ពុជា នៅក្រោមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាអង្គភាពមួយរបស់រដ្ឋាភិបាល សម្រាប់សម្របសម្រួល និងកៀងគរជំនួយអភិវឌ្ឍន៍។ ក្រុមប្រឹក្សានេះធ្វើការជាមួយក្រសួងពាក់ព័ន្ធ និងទីភ្នាក់ងារនានា រួមទាំងដៃគូអភិវឌ្ឍន៍ ដែលរួមទាំងម្ចាស់ជំនួយទ្វេភាគី ទីភ្នាក់ងារផ្តល់ជំនួយពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាលនានា។

ក្រុមប្រឹក្សានេះ បានបង្ហាញរបាយការណ៍ឆ្នាំ ២០០៨ អំពីប្រសិទ្ធភាពជំនួយសម្រាប់កម្ពុជា នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការដឹកនាំការពិភាក្សាអំពីគោលនយោបាយ ស្តីពីប្រសិទ្ធិភាពជំនួយ។ ក្រុមប្រឹក្សានេះ ដើរតួជាអ្នកចាត់ចែងរៀបចំការផ្លាស់ប្តូរបទពិសោធន៍អំពីការគ្រប់គ្រងជំនួយ ដែលក្នុងនោះ ទម្លាប់ល្អៗដែលទើបលេចឡើងនៅកម្ពុជា ត្រូវបានចែករំលែកជាមួយសហសេវិកមកពីប្រទេសវៀតណាម ឡាវ ឥណ្ឌូនេស៊ី និងប៉ាពូញូហ្គីនេ។ ក្រុមប្រឹក្សានេះក៏បានចែករំលែកផងដែរ នូវលទ្ធផលការងាររបស់កម្ពុជាជាមួយឡាវ និងវៀតណាម អំពីកិច្ចផ្តួចផ្តើមរួមគ្នាលើគណនេយ្យភាពរវាងគ្នាទៅវិញទៅមកនៅក្នុងវេទិកាជាន់ខ្ពស់លើកទីបី ស្តីពីប្រសិទ្ធភាពជំនួយដែលបានប្រព្រឹត្តទៅនៅទីក្រុងអាក្រា តាមរយៈគណៈកម្មការ

ជំនួយអភិវឌ្ឍន៍របស់ OECD ដែលតាមដានការរីកចម្រើនដែលទាក់ទងនឹងការអនុវត្តសេចក្ដីថ្លែងការណ៍ក្រុងប៉ារីស នៅឆ្នាំ ២០០៥ ស្ដីពីប្រសិទ្ធិភាពជំនួយ ។

## ដីដែលបានដោះមីនរួច ត្រូវបានប្រគល់ទៅឱ្យប្រជាពលរដ្ឋដែលជាអ្នកត្រូវការវាជាចាំបាច់

ក្រោយរយៈពេលជិតបីទស្សវត្សរ៍នៃទំនាស់ផ្ទៃក្នុង កម្ពុជានៅតែរងគ្រោះធ្ងន់ធ្ងរដោយសារគ្រាប់មីនបង្កប់ក្នុងដី និងគ្រឿងផ្ទុះដែលនៅសល់ពីសម័យសង្គ្រាម ។ ដោយសារមរតកប្រកបដោយគ្រោះថ្នាក់នេះ មានន័យថា គេមិនអាចដាំដំណាំ សាងសង់ផ្លូវ និងអណ្ដូងទឹកបានឡើយនៅលើផ្ទៃដីជិត ៧០០គ.ម$^{២}$ នៅជនបទ ហើយកុមារមិនអាចទៅសាលារៀនបានឡើយ ។ ដើម្បីដោះស្រាយភាពប្រឈមយ៉ាងច្រើននៃការអភិវឌ្ឍដែលបង្កដោយវត្តមានគ្រាប់មីនបែបនេះ កម្ពុជាបានអនុម័តយកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិសេសទី ៩ ដើម្បីបោសសំអាតដីដែលមានគ្រាប់មីន កាត់បន្ថយអត្រារងរបួសឱ្យដល់សូន្យ និងកែលម្អជំនួយដល់អ្នកនៅមានជីវិតពីគ្រោះថ្នាក់នេះ ។ យូអិនឌីភី គាំទ្រសកម្មភាពគ្រាប់មីនតាមរយៈការដោះមីន ការអភិវឌ្ឍស្តង់ដារសកម្មភាពមីន និងការតាមដានរាល់ប្រតិបត្តិការដោះមីននៅកម្ពុជា ។ អង្គការនេះគ្រប់គ្រងសកម្មភាពនានា តាមរយៈមូលនិធិដែលផ្ដល់ដោយប្រទេសអូស្ត្រាលី កាណាដា អេស្ប៉ាញ មូលនិធិ Adopt-a-Minefield និងយូអិនឌីភី ។

មជ្ឈមណ្ឌលសកម្មភាពមីននៃកម្ពុជា បានបោសសំអាតគ្រាប់មីនលើផ្ទៃដីទំហំ ៦,៧៨ គ.ម២ តាមរយៈមូលនិធិពីយូអិនឌីភី នៅក្នុងឆ្នាំ ២០០៨ ដោយបានកំចាត់ និងបំផ្លាញគ្រាប់មីនប្រឆាំងមនុស្សចំនួន ៨.៩៣៥ គ្រាប់មីនប្រឆាំងរថក្រោះចំនួន ២២០ គ្រាប់ និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ៣៤.១៣៧បំណែក ។ ប្រមាណ ៦០ ភាគរយ នៃចំណែកដីនោះដែលបានសំអាតពីគ្រាប់មីនត្រូវបានប្រើប្រាស់សម្រាប់ធ្វើកសិកម្មឬតាំងទីលំនៅ ២០ ភាគរយ សម្រាប់ជាផ្លូវថ្នល់ក្នុងសហគមន៍ និង ២០ ភាគរយ សម្រាប់សាងសង់សាលារៀន ប្រព័ន្ធស្រោចស្រពវត្តអារាម និងការប្រើប្រាស់ផ្សេងៗទៀត ។

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនរងគ្រោះដោយសារមីន ដែលជាអង្គភាពត្រួតពិនិត្យសកម្មភាពមីនជាផ្លូវការ បានរៀបចំស្តង់ដារសកម្មភាពមីននៅកម្ពុជាបន្ថែមទៀត និងបានបង្កើតទ្វេឡើង រហូតដល់ចំនួនបួននូវក្រុមអ្នកពិនិត្យគុណភាព ដែលធ្វើការតាមដានលើរាល់សុវត្ថិភាព និងប្រសិទ្ធិភាពការងាររបស់ប្រតិបត្តិករសំអាតគ្រាប់មីន ។ ជាសរុប ក្រុមទាំងនេះបានពិនិត្យសកម្មភាពកំចាត់គ្រាប់មីនចំនួន ៩១៤ លើក ដែលជាកំណើន ៦០០ ភាគរយ ធៀបនឹងឆ្នាំ ២០០៧ ។

គោលការណ៍ណែនាំសម្រាប់កសាងផែនការបោសសំអាតគ្រាប់មីន ត្រូវបានកែសម្រួលដើម្បីធានាថាទាំងស្ត្រី និងបុរស ពីសហគមន៍ដែលរងគ្រោះដោយសារគ្រាប់មីន បានទទួលការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការ ដែលមានគោលដៅធានាថា ដីធ្លីដែលមានអាទិភាពខ្ពស់បំផុត គឺជាគោលដៅដែលត្រូវសំអាតពីគ្រាប់មីនមុនគេ ហើយប្រធានភូមិបានទទួលការបណ្ដុះបណ្ដាលអំពីការផ្លាស់ប្ដូរទាំងនេះ ។ កម្ពុជាក៏បានចូលរួមនៅក្នុង


រូបភាព: យូអិនឌីភី/ណេថាន់ ហ៊័រតុន

សិក្ខាសាលាអន្តរជាតិអំពីយេនឌ័រផងដែរនៅក្នុងប្រទេសអ៊ីតាលី ដើម្បីបន្តអនុវត្តសកម្មភាពនៃសន្និសីទក្រុងណៃរ៉ូប៊ីនៅឆ្នាំ ២០០៧ អំពីយេនឌ័រ និងសកម្មភាពមីន ។

កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការក្រុងអូស្លូ ដើម្បីហាមឃាត់គ្រាប់បែកចង្កោម ប៉ុន្តែកំពុងធ្វើការសិក្សាអំពីផលវិបាកនៃការចុះហត្ថលេខា ។ អនុសញ្ញាស្ដីពីគ្រាប់បែកចង្កោមហាមឃាត់រាល់ការប្រើប្រាស់ រក្សាទុកក្នុងឃ្លាំង ផលិត និងដឹកជញ្ជូនគ្រាប់បែកចង្កោម ។ កាតព្វកិច្ចនៅក្នុងអនុសញ្ញានេះ ពាក់ព័ន្ធជាមួយការជួយជនរងគ្រោះ ការបោសសំអាតតំបន់ដែលរងគ្រោះ និងការបំផ្លាញអាវុធបែបនេះនៅក្នុងឃ្លាំង ។

នៅកម្រិតពិភពលោកយូអិនឌីភី បានសម្រួលឱ្យកម្ពុជាបានចូលរួមនៅក្នុងរាល់កិច្ចប្រជុំអន្តរជាតិនៅទូទាំងដំណើរការនេះ ។ ដើម្បីផ្សព្វផ្សាយនៅកម្ពុជាអំពីខ្លឹមសារនៃសន្ធិសញ្ញាអន្តរជាតិនេះ ក្នុងការហាមឃាត់គ្រាប់បែកចង្កោមសកម្មភាពបង្កើនការយល់ដឹងត្រូវបានធ្វើឡើងនៅក្នុងខេត្តនានា ដែលរងគ្រោះដោយសារគ្រាប់មីន និងគ្រឿងផ្ទុះដែលនៅសេសសល់ពីសម័យសង្គ្រាម ក៏ដូចជានៅក្នុងរាជធានីភ្នំពេញផងដែរ ។

ទស្សនកិច្ចតាមរថយន្តបឹស ដើម្បីផ្សព្វផ្សាយអំពីការហាមឃាត់គ្រាប់បែកចង្កោម ត្រូវបានធ្វើឡើងនៅក្នុងសហគមន៍ និងទីក្រុងដែលរងគ្រោះ ។ រថយន្តបឹសបានធ្វើដំណើរទៅសហគមន៍នានាដែលរងគ្រោះដោយគ្រាប់បែកចង្កោម ក៏ដូចជាមជ្ឈមណ្ឌលស្ដារនីតិសម្បទា និងវត្តអារាមនានានៅក្នុងខេត្តក្រចេះ និងកំពង់ចាម ជាខេត្តចំនួនពីរដែលរងគ្រោះធ្ងន់ធ្ងរជាងគេ នឹងបន្តដំណើរនៅជុំវិញក្រុងភ្នំពេញផងដែរ ។ អ្នកដំណើរតាមរថយន្តបឹស បានបង្កើនការយល់ដឹងអំពីកិច្ចប្រឹងប្រែងដែលកំពុងអនុវត្តដើម្បីហាមឃាត់អាវុធមហាប្រល័យគ្មានរើសមុខនេះ ដោយបានប្រមូលហត្ថលេខាគាំទ្រសន្ធិសញ្ញាប្រជាពលរដ្ឋ ដើម្បីហាមឃាត់គ្រាប់បែកចង្កោមទាំងនេះ និងរៀនសូត្រដោយផ្ទាល់ អំពីគ្រោះថ្នាក់ដែលមិនអាចទទួលយកបាន ដែលបង្កដោយអាវុធបែបនេះមកលើជនស៊ីវិល ។

*ព្រះសង្ឃមួយអង្គ ពន្យល់អំពីសន្ធិសញ្ញាហាមឃាត់គ្រាប់បែកចង្កោម ក្នុងពេលធ្វើដំណើរតាមរថយន្តបឹស ទៅវត្តភ្នំ នៅក្រុងភ្នំពេញ ។*

*"មនុស្សគ្រប់គ្នា គួរតែឈប់ប្រើប្រាស់និងចែកចាយគ្រាប់បែកចង្កោម ព្រោះថា វានៅតែបង្កការឈឺចាប់ដល់ប្រជាជននៅក្នុងភូមិខ្ញុំ ជិត ៤០ ឆ្នាំមកហើយ ក្រោយពេលមានការទម្លាក់គ្រាប់បែកបែបនេះនៅទីនេះ" ។*

អ្នកស្រី មឿន សាន អាយុ ៥៣ ឆ្នាំ ជាអ្នកភូមិមួយនៅក្នុងខេត្តក្រចេះ ដែលកូនគាត់បានរងរបួសដោយគ្រាប់បែកចង្កោម ។

# បរិស្ថាន និងថាមពល


រូបភាព: WCS / អេលីសា កេល្លីមែន

*ការអភិរក្សនៅតំបន់ខ្ពង់រាបភាគខាងជើង កំពុងជួយថែរក្សាសត្វព្រៃ និងកែលម្អការចិញ្ចឹមជីវិត។*

## ភាពប្រឈម

កម្ពុជាសំបូរដោយបរិស្ថានធម្មជាតិ។ តំបន់ទំនាបកណ្តាលមានទឹកដែលបានមកពីប្រព័ន្ធនៃដែនទឹកសាប ទន្លេមេគង្គ និងទន្លេសាប និងខ្ពង់រាបខាងជើង និងជួរភ្នំទាបៗនៅភាគខាងកើត និងពាយព្យ ដែលផ្សំដោយតំបន់ទេសភាពដែលបានទទួលការថែរក្សានៅល្អជាងគេជាបង្គួរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។ កម្ពុជាក៏មានប្រពៃណីគួរជាទីមោទនៈផងដែរ នៃកិច្ចការពារតំបន់ទេសភាពរបស់ខ្លួន។ ផ្ទៃដីទំហំជិតមួយភាគបួននៃផ្ទៃប្រទេស ត្រូវបានកំណត់ជាតំបន់អភិរក្ស ហើយតំបន់បឹងទន្លេសាប ត្រូវបានកំណត់ជាឋបនីយជីវមណ្ឌល ដោយអង្គការយូណេស្កូនៅក្នុងឆ្នាំ ២០០៧។

ប៉ុន្តែ មរតកនេះកំពុងស្ថិតក្រោមសម្ពាធពីកត្តាមួយចំនួន។ ជនកម្ពុជាប្រមាណ៨០ភាគរយ រស់នៅក្នុងទីជនបទដោយពឹងផ្អែកលើការដាំដំណាំទ្រង់ទ្រាយតូច និងការស្វែងរកអាហារពីបឹង និងពីព្រៃឈើសម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន។ ប៉ុន្តែ រយៈពេលជាច្រើនសតវត្សរ៍នៃការធ្វើស្រែបានធ្វើឱ្យដីខ្សោះជីជាតិហើយការហូរច្រោះបានធ្វើឱ្យដីរេចរឹល។ ដោយប្រឈមជាមួយបញ្ហាអសន្តិសុខស្បៀងអ្នកក្រនៅជនបទពឹងផ្អែកកាន់តែខ្លាំងឡើងលើធនធានដែលជាទ្រព្យរួម ដោយធ្វើឱ្យសមត្ថភាពផលិតរបស់ធនធានទាំងនោះថមថយ ដោយសារការប្រើប្រាស់ហួសកម្រិត និងបង្កជាការគំរាមកំហែងមកលើជីវៈចម្រុះនៅក្នុងតំបន់ទាំងនោះ។ ទន្ទឹមនឹងនេះគេមានកង្វល់ជាច្រើនដែលថា ព្រៃឈើ និងធនធានជលផលខ្លះៗកំពុងស្ថិតក្រោមការប្រើប្រាស់ ដើម្បីទាញយកផលចំណេញយ៉ាងឆាប់រហ័សនៅក្នុងដំណើរការ ដែលធ្វើឱ្យខូចប្រព័ន្ធអេកូឡូស៊ី និងធ្វើឱ្យជនក្រីក្រកាន់តែងាយរងគ្រោះ។

ក្នុងស្ថានភាពបែបនេះ ការប្រែប្រួលអាកាសធាតុកំពុងគំរាមកំហែង ដោយធ្វើឱ្យមានផលវិបាករយៈពេលយូរអង្វែងមកលើកិច្ចប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងភាពក្រីក្រ។ កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះជាងគេនៅអាស៊ីអាគ្នេយ៍ ដោយអាចរងផលប៉ះពាល់មកលើកសិកម្ម តំបន់ឆ្នេរ ធនធានទឹក និងសុខភាព។

កម្ពុជាក៏មានការប្តេជ្ញា ដើម្បីការពារស្រទាប់អូហ្សូន ដោយបញ្ឈប់ការប្រើប្រាស់ឧស្ម័ន ដែលបំផ្លាញស្រទាប់អូហ្សូន និងស្វែងរកដំណោះស្រាយនៅក្នុងមូលដ្ឋានទល់នឹងបញ្ហានានា ដែលមានឥទ្ធិពលមកលើពិភពលោកទាំងមូល ដូចជា ការខ្សោះជីជាតិដី និងរបោស្ថានកម្ម។

## ការឆ្លើយតបរបស់យូអិនឌីភី

យូអិនឌីភី ទទួលស្គាល់ថា ការកាត់បន្ថយភាពក្រីក្រការអភិវឌ្ឍសេដ្ឋកិច្ច ការប្រើប្រាស់ដីដោយនិរន្តរភាព និងការអភិរក្សជីវៈចម្រុះមានភាពទាក់ទងគ្នាយ៉ាងស្មុគស្មាញ។ អង្គការនេះធ្វើសកម្មភាពយ៉ាងខ្លាំងក្លានៅលំដាប់ថ្នាក់ជាច្រើន ដែលរួមទាំងធ្វើការជាមួយរដ្ឋាភិបាល ដើម្បីដាក់បញ្ចូលការអភិវឌ្ឍដោយចីរភាព

ទៅក្នុងគោលនយោបាយនានារបស់ជាតិ ស្តីពីការគ្រប់គ្រងដីធ្លី និងការប្រែប្រួលអាកាសធាតុ។ យូអិនឌីភី ក៏គាំទ្រដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលផងដែរ ដើម្បីអភិរក្ស "តំបន់សំខាន់ៗ" នៃជីវៈចម្រុះ ដូចជា តំបន់បឹងទន្លេសាប និងខ្ពង់រាបខាងជើង និងជួយសហគមន៍នានា ធ្វើការដោះស្រាយបញ្ហាទឹក ថាមពល និងផលិតភាព នៃកសិដ្ឋាន តាមរយៈការគ្រប់គ្រងកម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក។

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០០៨

- ពង្រឹងការគ្រប់គ្រងទីតាំងអភិរក្សជីវៈចម្រុះ ដែលធ្វើឱ្យមានកំណើនចំនួនសត្វនៅក្នុងប្រភេទដែលជិតផុតពូជបំផុត
- ការកសាងផែនការតាមបែបផែននៃការចូលរួមត្រូវបានសម្រេចនៅក្នុងសហគមន៍ចំនួនបួននៅតំបន់ខ្ពង់រាបខាងជើង
- ផែនការអភិវឌ្ឍន៍ឃុំ បានដាក់បញ្ចូលការគ្រប់គ្រងចម្រុះនូវជីវៈចម្រុះ និងជម្រើសជំនួសនៃការចិញ្ចឹមជីវិត ដែលរួមទាំងការបណ្តុះបណ្តាលអំពីការគ្រប់គ្រងអេកូទេសចរណ៍ និងការដាំបន្លែលើសួនបណ្តែតទឹក
- មន្ត្រីល្បាតច្រើនជាង ៤០០ នាក់ មន្ត្រីរដ្ឋាភិបាល និងសមាជិកសហគមន៍ បានទទួលការបណ្តុះបណ្តាលលើជំនាញជាច្រើន ដែលរួមទាំងការធ្វើផែនទី ការពង្រឹង ការអនុវត្តច្បាប់ និងបច្ចេកទេសអង្កេតសត្វព្រៃ
- ទីតាំងគ្រប់គ្រងធនធានធម្មជាតិ ដោយផ្អែកលើសហគមន៍ចំនួន ៦៣កន្លែង ដែលពាក់ព័ន្ធជាមួយសមាជិកសហគមន៍ចំនួន ៦៦.០០០នាក់ នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅមូលដ្ឋាន
- ក្រុមសហគមន៍សន្សំប្រាក់ចំនួន ៣០៥សហគមន៍ ដែលមានសមាជិកចំនួនច្រើនជាង ៦០០០នាក់ ត្រូវបានបង្កើតឡើង និងពង្រឹង ដើម្បីធ្វើសកម្មភាពអាជីវកម្មខ្នាតតូច និងរបរចិញ្ចឹមជីវិត
- បានចាប់ផ្តើមការងារលើការបញ្ចូលប្រព័ន្ធគ្រប់គ្រងដីធ្លីដោយនិរន្តរភាព ទៅក្នុងគោលនយោបាយជាតិ
- ការិយាល័យប្រែប្រួលអាកាសធាតុ បានបង្ហើយការធ្វើសារពើ-ភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងប៉ាន់ប្រមាណអំពីភាពងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ
- ការប្រើប្រាស់ឧស្ម័នដែលបំផ្លាញស្រទាប់អូហ្សូន ត្រូវបានកាត់បន្ថយអស់ ២.៩៥ តោន

## ការពាក់ព័ន្ធរបស់សហគមន៍ បានជួយនៅក្នុងកិច្ចការពារប្រភេទសត្វ និងរុក្ខជាតិនានា និងកាត់បន្ថយភាពក្រីក្រ

តំបន់ខ្ពង់រាបភាគខាងជើងនៃប្រទេសកម្ពុជា គឺជាតំបន់ដែលមាននៅសល់ចំណែកធំជាងគេនៃតំបន់ទេសភាព ដែលរងការរំខានតិចតួចជាងគេ និងដែលមានសារៈសំខាន់ជាពិសេសលើពិភពលោកខាងការអភិរក្សជីវៈចម្រុះ។ តំបន់នេះដែលសំបូរដោយព្រៃល្បោះ វាលស្មៅ និងតំបន់ដីសើមតាមរដូវ តំបន់ខ្ពង់រាបនេះ គឺជាជម្រកសម្រាប់ថនិកសត្វធំៗ ដែលរងការគំរាមកំហែង ដែលរួមទាំងសត្វដំរីអាស៊ី សត្វខ្លាធំ ខ្លារខិន រមាំង សត្វគោរមាំង សត្វគោព្រៃ និងសត្វស្លាបដែលជិតផុតពូជនៅលើពិភពលោក ដែលរួមទាំងត្រយ៉ងសំកំកស សត្វក្រៀល និងសត្វត្មាតចំនួនបីប្រភេទ។ ចំពោះប្រភេទសត្វច្រើនជាង៤០ ប្រភេទ នៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ទីនេះ គឺជាជម្រកចុងក្រោយ ឬជាជម្រកសម្រាប់ពពួកសត្វសំខាន់ៗ ដែលមានចំនួនច្រើនអាចបន្តត្រកូលបាន។


រូបភាព: WCS / អេលីសា កេល្លីមែន

សត្វត្រដក់តូច ស្វែងរកជម្រកសុខសាន្តនៅក្នុងតំបន់ខ្ពង់រាបភាគខាងជើង នៃប្រទេសកម្ពុជា។

*សព្វថ្ងៃនេះ ខ្ញុំយល់ថា យើងទាំងអស់គ្នាត្រូវតែប្រឹងប្រែងជួយការពារធនធានធម្មជាតិ ហើយខ្ញុំនឹងព្យាយាមនាំយកសារនេះត្រឡប់មកផ្សព្វផ្សាយដល់ប្រជាពលរដ្ឋរបស់ខ្ញុំ និងធ្វើឱ្យពួកគេផ្លាស់ប្តូរឥរិយាបថពីការយល់ថា ធនធានធម្មជាតិមិនមានកម្រិតកំណត់នោះ។*

លោក ឌឹប អុន ដែលទទួលបានពានរង្វាន់អេក្វាទ័រ សម្រាប់អេកូទេសរណ៍ ក្នុងនាមសហគមន៍ត្មាតពើយ នៅក្នុងខេត្តព្រះវិហារ។

បើទោះជាមានការតាំងទីលំនៅដាច់ឆ្ងាយពីគ្នាក៏ដោយ តំបន់ខ្ពងរាបភាគខាងជើង កំពុងស្ថិតក្រោមសម្ពាធពីការពង្រីកដីសម្រាប់ធ្វើកសិកម្មទ្រង់ទ្រាយធំជាលក្ខណៈពាណិជ្ជកម្ម និងទ្រង់ទ្រាយតូចសម្រាប់ការចិញ្ចឹមគ្រួសារផងដែរ ការកាប់ឈើល្មើសច្បាប់ ការប្រមូលពងសត្វ និងកូនសត្វស្លាប ដែលប្រភេទពូជដែលរងការគំរាមកំហែង ការរំលោភយកដីធ្លីពីសំណាក់អ្នកមានអំណាច ការសាងសង់ផ្លូវថ្នល់ថ្មីៗ និងការបរបាញ់សត្វព្រៃដោយអ្នកប្រមាញ់អាជីព និងអ្នកឆ្លៀតឱកាសដើម្បីបរបាញ់ ដូចជាការដាក់អន្ទាក់យកសត្វស្វាក្តាមសម្រាប់ការធ្វើពាណិជ្ជកម្មលាយឡំជាមួយសត្វបង្កាត់ក្នុងកសិដ្ឋាន។

កិច្ចប្រឹងប្រែងរបស់យូអិនឌីភី មានគោលដៅកាត់បន្ថយសម្ពាធទាំងនេះ និងកាត់បន្ថយភាពក្រីក្រនៅជនបទដោយធ្វើការអភិរក្សព្រៃឈើ និងជលផល ការធានាថា ដីធ្លីត្រូវបានប្រើប្រាស់ដោយនិរន្តរភាព និងការផ្តល់ឱ្យសហគមន៍មូលដ្ឋាននូវការធានាសិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិ។ ភាពជាដៃគូរបស់អង្គការយូអិនឌីភី និងមូលនិធិបរិស្ថានពិភពលោកជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងសមាគមអភិរក្សសត្វព្រៃ បាននាំមកនូវភាពបំពេញគ្នាបានប្រសើរជាងមុនជាមួយកិច្ចផ្តួចផ្តើមដោយម្ចាស់ជំនួយផ្សេងទៀត ដូចជា DFID, DANIDA និងធនាគារពិភពលោក។ កិច្ចការនេះគ្របដណ្តប់លើផ្ទៃដីធំជាង ៤០០.០០០ ហិកតា នៃព្រៃល្បោះ ដែលរួមទាំងដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព្យ និងតំបន់ព្រៃការពារនៅក្នុងខេត្តព្រះវិហារ។ ដៃគូនានាធ្វើការនៅកម្រិតតំបន់ទេសភាព ដើម្បីដាក់បញ្ចូលតម្លៃនៃជីវៈចម្រុះទៅក្នុងការកសាងផែនការប្រើប្រាស់ដីធ្លី ដែលមានការទទួលស្គាល់ថាមានប្រសិទ្ធិភាពសម្រាប់អភិរក្សសត្វធំៗជាច្រើនប្រភេទ និងព្រៃនៅលើវិសាលភាពធំធេងជាងវិធីនៃការគ្រប់គ្រងតែលើទីតាំងតូចៗដាច់ដោយឡែកពីគ្នា។



*រូបភាព: យូអិនឌីភី/អ៊ីសាបែល លេសេរ*

*ការចិញ្ចឹមត្រីក្នុងបែរ អាចឱ្យគ្រួសារនានា ដែលរស់នៅលើបឹងទន្លេសាប ជៀសវាងការនេសាទពីដឹងច្រើនហួសកម្រិត*

សមាជិកសហគមន៍ដែលចូលរួមតាមរយៈប្រព័ន្ធលើកទឹកចិត្ត និងកិច្ចព្រមព្រៀងជាមួយអ្នកភូមិលើព្រៃការពារ ដែលអភិរក្សសត្វព្រៃ និងគ្រប់គ្រងតំបន់ការពារធម្មជាតិ។ ក្នុងស្ថានភាពដែលការកសាងផែនការប្រើប្រាស់ដីធ្លី ត្រូវបានបញ្ចប់ហើយនោះ ហើយព្រំប្រទល់តំបន់សហគមន៍ ត្រូវបានកំណត់ប្រាក់ចំណូលនៅមូលដ្ឋានបានកើនឡើង ហើយបញ្ហាទន្ទ្រានយកដីក៏បានដោះស្រាយផងដែរ។ នៅក្នុងឆ្នាំ ២០០៨ ដីទំហំ ៦.៧១០ហិកតា ត្រូវបានកំណត់ព្រំប្រទល់សម្រាប់ប្រើប្រាស់ដោយសហគមន៍ត្មាតពើយ និងដងផ្លាត។

អេកូទេសចរណ៍ កំពុងតែផ្តល់ជារបរចិញ្ចឹមជីវិតជំនួសដ៏មានតម្លៃ និងមាននិរន្តរភាពសម្រាប់គ្រួសារជាច្រើន។ នៅឆ្នាំ ២០០៨ កិច្ចផ្តួចផ្តើមអេកូទេសចរណ៍សត្វត្រយ៉ងនៅភូមិត្មាតពើយ ក្នុងដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព្យ បានទទួលរង្វាន់អេក្វាទ័រដ៏ល្បីល្បាញមួយ បន្ទាប់ពីបានទទួលរង្វាន់អេកូទេសចរណ៍ប្រកបដោយការទទួលខុសត្រូវលើសត្វព្រៃ នៅអាស៊ីក្នុងឆ្នាំ ២០០៧។ ជម្រំតង់សម្រាប់សង្កេតសត្វព្រៃ ត្រូវបានបញ្ជូនទៅភូមិដងផាត សម្រាប់រដូវនេះ នៅក្នុងតំបន់ព្រៃការពារខេត្តព្រះវិហារ ដែលភ្ញៀវទេសចរអាចសង្កេតសត្វត្មាត ដែលមានដោយកម្រដែលមកទទួលចំណីនៅ "ភោជនីយដ្ឋានសត្វត្មាត"។

**ប្រព័ន្ធការពារសំបុកសត្វស្លាប** បាននាំឱ្យមានកំណើនចំនួនសំបុកនៃប្រភេទសត្វស្លាប ដែលរងការគំរាមកំហែងជាសកលពីចំនួន ១៦៦ នៅក្នុងឆ្នាំ ២០០៤ រហូតដល់ចំនួន ៣៦៥ សំបុកនៅក្នុងឆ្នាំ ២០០៨។ អ្នកភូមិដែលធ្លាប់ប្រមូលពងសត្វសម្រាប់លក់តាមរយៈឈ្មួញកណ្តាល ដែលធ្វើពាណិជ្ជកម្មទៅទីផ្សារនៅតាមព្រំដែនជាមួយប្រទេសថៃ និងឡាវ បានទទួលរង្វាន់ជាថ្នូរនឹងការរកឃើញសំបុកសត្វស្លាបនៃប្រភេទ ដែលរងការគំរាមកំហែង និងត្រូវបានជួលឱ្យធ្វើការតាមដាន និងការពារសត្វស្លាបទាំងនេះ រហូតដល់វាអាចហើរបានដោយខ្លួនឯង។ ក្នុងខណៈដែលប្រព័ន្ធនេះ ត្រូវចំណាយតិចតួចធៀបនឹងជម្រើសផ្សេងនៃការអភិរក្ស ដែលត្រូវចំណាយជាមធ្យមប្រមាណ ១១០ ដុល្លា សម្រាប់សំបុកនីមួយៗ បរិមាណ ដែលបានបង់ទៅសមាជិកម្នាក់ៗនៅក្នុងសហគមន៍អាចមានច្រើនជាង ៤០០ដុល្លា ក្នុងមួយឆ្នាំ ដែលជាចំនួនច្រើននៅក្នុងកន្លែងមួយដែលប្រាក់ចំណូលជាមធ្យមប្រចាំ គ្រួសារមានត្រឹមប្រមាណ ៣៥០ដុល្លា ក្នុងមួយឆ្នាំ។ កិច្ចការនេះបានបន្តនៅក្នុងប្រព័ន្ធផលិតស្រូវ ដែលមិនបង្កគ្រោះថ្នាក់ចំពោះសត្វព្រៃដែលនឹងបង់ថ្លៃសម្រាប់ការទិញស្រូវពីកសិករ ដែលគោរពតាមផែនការប្រើប្រាស់ដីធ្លី ដែលបានឯកភាពគ្នាជាមុនរួចហើយ។ ទឹកប្រាក់នេះទទួលបានតាមរយៈការលក់អង្ករទៅឱ្យសណ្ឋាគារ និងភ្ញៀវទេសចរនៅក្នុងក្រុងសៀមរាប និងនៅកន្លែងផ្សេងទៀតក្នុងប្រទេសកម្ពុជា។

នៅឆ្នាំ ២០០៨ មានការបណ្តុះបណ្តាលសម្រាប់មនុស្សចំនួន ២៨០ នាក់ ដែលរួមមានស្ត្រី ៧០ នាក់ មន្ត្រីរដ្ឋាភិបាលចំនួន ៤៨ នាក់ និងសមាជិក NGOs អង្គការសង្គមស៊ីវិល និងអង្គការសហគមន៍ចំនួន ២១៨ នាក់។ វគ្គនេះរាប់បញ្ចូលការផ្តល់សេវាកម្មទេសចរណ៍ ការកសាងផែនការនៅថ្នាក់ឃុំ ការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុ និងបច្ចេកទេសកសិកម្ម ក៏ដូចជាការតាមដានលើការអនុវត្តច្បាប់ និង**បច្ចេកទេសអង្កេតសត្វព្រៃ**ផងដែរ។ មន្ត្រីរដ្ឋាភិបាលទាំង ៤៨ នាក់ រួមមាន ៣៩នាក់ ជាមន្ត្រីល្បាត បានទទួលការបណ្តុះបណ្តាលអំពីប្រព័ន្ធព័ត៌មានគ្រប់គ្រង (MIST) ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ការអភិវឌ្ឍសហគមន៍ និងការល្បាត។

## របរចិញ្ចឹមជីវិតថ្មីៗ ជួយថែរក្សាជីវៈចម្រុះនៅក្នុងផ្លូវទឹកសំខាន់ៗ

**បឹងទន្លេសាប** នៅក្នុងភូមិភាគកណ្តាលនៃប្រទេសកម្ពុជា គឺជាអាងទឹកសាបធំជាងគេនៅអាស៊ីអាគ្នេយ៍ ដែលមានទឹកជាអចិន្ត្រៃយ៍។ តំបន់នេះត្រូវបានកំណត់ជាវបនីយជីវមណ្ឌលនៃអង្គការយូនេស្កូ នៅក្នុងឆ្នាំ ១៩៩៧ ដែលនេះជាជម្រកពង និងភ្ញាស់កូនតាមរដូវ និងរកចំណីរបស់ត្រី និងសត្វស្លាបធំៗ និងក៏ជាជម្រកចុងក្រោយសម្រាប់ប្រភេទសត្វមួយចំនួន ដែលរងការគំរាម-កំហែងជាសកលផងដែរ។ បឹងទន្លេសាប ក៏ជាជម្រកសម្រាប់មនុស្សប្រមាណ ៣ លាននាក់ផងដែរ ដែលអ្នកទាំងនោះជាច្រើនទទួលយ៉ាងហោចណាស់ មួយផ្នែកនៃអាហារសម្រាប់ការចិញ្ចឹមគ្រួសារ និងប្រាក់ចំណូលរបស់ពួកគេមកពីធនធាននៅក្នុងបឹងមួយនេះ។ ប្រមាណពាក់កណ្តាលនៃផលនេសាទនៅប្រទេសកម្ពុជា បានមកពីសហគមន៍នេសាទនិងការនេសានៅក្នុង ឡូតិ៍នៅក្នុងបឹងទន្លេសាប។ ប៉ុន្តែ ការធ្វើអាជីវកម្មហួសកម្រិតលើធនធានព្រៃឈើ ត្រី និងសត្វព្រៃ ការទន្ទ្រានចូល ការរានឆ្ការព្រៃយកដី និងការទន្ទ្រានដោយប្រភេទសត្វ និងរុក្ខជាតិចម្លែកមកពីខាងក្រៅ កំពុងតែបង្កការគំរាមកំហែងមកលើប្រព័ន្ធអេកូឡូស៊ីប្លែកពីគេមួយនេះ។

យូអិនឌីភី កំពុងធ្វើការក្រោមភាពជាដៃគូជាមួយគណៈ-កម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា មូលនិធិបរិស្ថានពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ និងយូអិនឌីភី។ ការងារនេះផ្តោតលើតំបន់ស្នូលចំនួនបី ដែលសំបូរដោយជីវៈចម្រុះ និងត្រូវបានប្រកាសជាផ្លូវការថាជាតំបន់ការពារធម្មជាតិ ពោលគឺ ព្រែកទ័ល ស្ទឹងសែន និងបឹងទន្លេឆ្មារ។

នៅឆ្នាំ២០០៨ ៩០ភាគរយនៃការដាំបង្គោលកំណត់ព្រំប្រទល់ត្រូវបានអនុវត្តរួចជាស្រេចផែនការគ្រប់គ្រងសម្រាប់តំបន់អភិរក្សទាំងបីត្រូវបានរៀបចំឡើងហើយមជ្ឈមណ្ឌលគ្រប់គ្រងចំនួនប្រាំត្រូវបានកសាងឡើង។ ដូចគ្នានេះដែរមន្ត្រីល្បាតចំនួន១៦២នាក់នាយកគ្រប់គ្រង និងមន្ត្រីតាមមូលដ្ឋានក៏បានទទួលការបណ្តុះបណ្តាលអំពីការធ្វើផែនទីប្រព័ន្ធទីតាំងភូមិសាស្ត្រភាសាអង់គ្លេស និងជំនាញកម្រងទិន្នន័យ និងការគ្រប់គ្រង

ផងដែរ។ មន្ត្រីល្បាត និងមន្ត្រីការពារប្រមាណ ៥២ នាក់ បានទទួលការគាំទ្រ និងការបណ្តុះបណ្តាលអំពីបទប្បញ្ញត្តិ និងការអនុវត្តច្បាប់នៅក្នុងតំបន់ស្នូល។ ការតាមដានសត្វព្រៃបានរាប់បញ្ចូលការវាយតម្លៃអំពីនិគមន៍សត្វស្លាបទឹកការចាប់សត្វពស់ទឹក និងការស្រង់ចំនួនប្រចាំឆ្នាំនូវសត្វក្រៀលដែលងាយរងគ្រោះ។

មានប្រជាពលរដ្ឋក្រីក្រប្រមាណ ២.១០០ គ្រួសារ ដែលកំពុងរស់នៅក្នុងតំបន់ស្នូលដែលអ្នកទាំងនោះច្រើនជាង ៦០ ភាគរយ គឺជាស្ត្រីដែលទទួលផលដោយផ្ទាល់ពីការគាំទ្រដល់ជម្រើសជំនួសនៃរបរចិញ្ចឹមជីវិតដែលរួមទាំងការដាំបន្លែសរីរាង្គនៅក្នុងច្បារបណ្តែតទឹកការផលិតផ្សិត ការបង្កាត់ និងចិញ្ចឹមត្រីនៅក្នុងបែរ។ អ្នកសន្សំប្រាក់ចំនួន ២២ ក្រុម ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ៥៤៧ នាក់ ក្នុងនោះ ៥១៥ នាក់ជាស្ត្រី បានជួយប្រមាណ ៨៦ភាគរយ នៃគ្រួសារដែលកំពុងរស់នៅលើ និងជិតបឹងនេះ ដើម្បីពួកគាត់អាចទិញចង្ក្រានប្រសិទ្ធភាព និងធុងចម្រោះទឹកសេរ៉ាមិក។ ឧបករណ៍ងាយៗទាំងនេះបានជួយគ្រួសារទាំងនេះ ក្នុងការកាត់បន្ថយការពឹងផ្អែករបស់ពួកគេលើការកាប់អុសមកពីព្រៃ និងកាត់បន្ថយហានិភ័យនៃការឆ្លងជម្ងឺរាគបណ្តាលពីការផឹកទឹកពីបឹងដោយផ្ទាល់។

ប្រជាជនជិត ១០.000 នាក់ ដែលរស់នៅក្នុងបរិមណ្ឌលនេះ បានទទួលកម្មវិធីផ្សព្វផ្សាយសហគមន៍លើប្រធានបទស្តីពីទឹក និងថាមពល។ លើសពីនេះ ឯកសារកម្មវិធីសិក្សា ដូចជាឯកសារណែនាំសម្រាប់គ្រូ និងឯកសារណែនាំសកម្មភាព អំពីការយល់ដឹងពីបរិស្ថាន ដោយផ្តោតលើសិស្សសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅជុំវិញបឹងទន្លេសាប ត្រូវបានរៀបចំរួចរាល់និងបានប្រកាសដាក់ឱ្យប្រើប្រាស់ការគាំទ្របានបន្តដល់មជ្ឈមណ្ឌលអប់រំបរិស្ថានហើយផ្លាកសញ្ញាថ្មីៗនៅតាមច្រកផ្លូវចូលត្រូវបានតម្លើងដើម្បីឱ្យភ្ញៀវបានដឹងថាពួកគេកំពុងចូលទៅក្នុងបរិមណ្ឌលនេះហើយ។

## ចក្ខុវិស័យថ្មីសម្រាប់ការគ្រប់គ្រងដីធ្លីមានគោលដៅប្រយុទ្ធប្រឆាំងដីខ្សោះជីជាតិ

វិធីមួយក្នុងការដោះស្រាយការប្រឈមរបស់កម្ពុជាលើផ្នែកបរិស្ថាន គឺការគ្រប់គ្រងដីធ្លីដោយនិរន្តរភាព ដែលជាវិធីមួយបានការទទួលស្គាល់ជាអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងដីខ្សោះជីជាតិ និងរហោស្ថានកម្ម។ នេះជាវិធីដែលផ្អែកលើចំណេះដឹងដែលជួយដាក់បញ្ចូលការគ្រប់គ្រងដីធ្លី ទឹក ជីវៈចម្រុះ និងបរិស្ថាន ទៅក្នុងគោលនយោបាយ និងការអនុវត្តនានាតាមរូបភាព ដែលអាចឆ្លើយតបទៅនឹងកំណើនតម្រូវការស្បៀង ទន្ទឹមនឹងការទ្រទ្រង់ការចិញ្ចឹមជីវិត និងសេវាប្រព័ន្ធអេកូឡូស៊ីឱ្យមាននិរន្តរភាព។ នៅឆ្នាំ ២០០៨ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ (MAFF) បានរួមជាដៃគូជាមួយយូអិនឌីភី ដើម្បីប្រកាសកិច្ចប្រឹងប្រែងថ្មីមួយដើម្បីពង្រឹងបរិយាកាសអំណោយផលសម្រាប់ការគ្រប់គ្រងដីធ្លីឱ្យមាននិរន្តរភាព ទន្ទឹមនឹងការធានាឱ្យមានការគាំទ្រទូលំទូលាយខាងគោលនយោបាយ និងសហគមន៍ដល់ដំណើរការនេះ។

ក្រុមមួយដែលមានសមាសភាពមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងបរិស្ថាន បានចាប់ផ្តើមធ្វើបច្ចុប្បន្នភាព និងពង្រីកផែនការសកម្មភាពជាតិរបស់កម្ពុជា ដើម្បីលើកកំពស់ការគ្រប់គ្រងដីធ្លីឱ្យមាននិរន្តរភាព។ សន្និសីទជាតិមួយដែលមានអ្នកចូលរួមចំនួន ៦០ នាក់ បានពិភាក្សាអំពីការប្រយុទ្ធប្រឆាំងដីខ្សោះជីជាតិសម្រាប់និរន្តរភាពកសិកម្ម ដែលជាបញ្ហាមួយដែលគេចាប់អារម្មណ៍ខ្ពស់នៅកម្ពុជា។ ក្រុមនេះក៏បានចាប់ផ្តើម


*រូបភាព: យូអិនឌីភី/អ៊ីសាបែល លេសេរ*

ប្រមូលព័ត៌មានអំពីដីខ្សោះជីជាតិដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់ដាក់បញ្ចូលវិធីនានានៃការគ្រប់គ្រងដីធ្លីឱ្យមាននិរន្តរភាពទៅក្នុងគោលនយោបាយនិងការកសាងផែនការនៅថ្នាក់ជាតិនិងថ្នាក់តំបន់ផងដែរ។ ការយល់ដឹងអំពីគោលការណ៍នានានៃវិធីនេះត្រូវបានជម្រុញតាមរយៈកម្មវិធីព្រៃឈើជាតិនិងសេចក្តីព្រាងគោលនយោបាយគ្រប់គ្រងដីធ្លី។

ដើម្បីបង្ហាញពីផលប្រយោជន៍នៃវិធីនេះ ក្រុមនេះបានចែករំលែកឧបករណ៍ងាយៗ សម្រាប់ការប្រើប្រាស់នៅកម្រិតឃុំ ដែលបានជួយថ្នាក់ដឹកនាំនៅមូលដ្ឋាន ធ្វើការវាយតម្លៃដីខ្សោះជីជាតិ និងទម្លាប់អនុវត្តល្អៗ ជាមួយមន្ត្រីកសិកម្មនៅក្នុងខេត្តចំនួនពីរ។ មន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងមូលដ្ឋាន បានទទួលការបណ្តុះបណ្តាលអំពីការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ី នៅកម្រិតឃុំ។ ការពិគ្រោះយោបល់ និងទស្សនកិច្ចសិក្សានានា បានផ្តោតលើបញ្ហានានាដែលរួមទាំងតម្លៃនៃការចូលរួមរបស់ស្ត្រី និងកុមារ នៅក្នុងការប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិផងដែរ។

## កម្ពុជាត្រៀមខ្លួន ប្រយុទ្ធប្រឆាំង និងបន្សាំជាមួយការប្រែប្រួលអាកាសធាតុ

**កំណើនកំដៅពិភពលោក** បង្កភាពប្រឈមជាច្រើនសម្រាប់កម្ពុជា។ ឥទ្ធិពលដែលអាចកើតឡើងបណ្តាលពីកំណើនសីតុណ្ហភាពរួមមាន ការប្រែប្រួលទម្រង់នៃការធ្លាក់ភ្លៀង ព្រឹត្តិការណ៍កំណាចនៃអាកាសធាតុកាន់តែមានញឹកញាប់ ដូចជា ទឹកជំនន់ និងភាពរាំងស្ងួត និងកំណើនប្រេវ៉ាឡង់នៃជម្ងឺត្រូពិក ដែលរួមទាំងជម្ងឺរាគ និងគ្រុនឈាម។ ខ្សែឆ្នេរដ៏វែងរបស់កម្ពុជា ក៏ងាយរងគ្រោះចំពោះកំណើនកំពស់ទឹកសមុទ្រ សំណឹកឆ្នេរ និងការជ្រៀតចូលនៃទឹកសមុទ្រផងដែរ។ គេរំពឹងថា ឥទ្ធិពលនានានឹងបង្កឱ្យឃើញមុនគេ និងធ្ងន់ធ្ងរចំពោះការចិញ្ចឹមជីវិត និងសន្តិសុខស្បៀងរបស់ជនក្រីក្រ

*គម្រោងតូចៗអនុញ្ញាតឱ្យសហគមន៍ស្វែងរកដំណោះស្រាយចំពោះបញ្ហាជាសកល។*

*"ទំហំដីដែលប្រើប្រាស់សម្រាប់ដាំស្រូវបានកើនឡើងពី ៤៤៨.៧៨០ ហិកតា នៅឆ្នាំ ២០០២ ដល់ ២.៦ លានហិកាតា នៅឆ្នាំ ២០០៧។ តួលេខនេះបង្ហាញថា យើងបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះកំណែលម្អ និងការគ្រប់គ្រងដីកសិកម្ម នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ"។*

ឯកឧត្តម លឹម សុគន្ធ រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងនៅក្នុងទិវាពិភពលោកប្រយុទ្ធប្រឆាំងរហោស្ថានកម្ម។



រូបភាព: យូអិនឌីភី

*ជនក្រីក្រនៅជនបទងាយ រងគ្រោះបំផុត ដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ*

នៅជនបទ។ ក្នុងនាមជាភាគីសមាជិកមួយនៃពិធីសារក្យូតូ និងសមាជិកនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) កម្ពុជាមានកាតព្វកិច្ចជាអន្តរជាតិ ដើម្បីប្រមូល និងចែករម្លែកព័ត៌មានអំពីសកម្មភាពជាតិ ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ យូអិនឌីភី ធ្វើការជាដៃគូជាមួយមូលនិធិបរិស្ថានពិភពលោក ដើម្បីគាំទ្រកិច្ចការនេះ។

នៅឆ្នាំ ២០០៨ ការិយាល័យប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន បានបង្កើយផ្នែកសំខាន់ៗនៃរបាយការណ៍ជាតិលើកទីពីរ សម្រាប់កិច្ចប្រជុំនៃភាគីសមាជិកក្នុងអនុសញ្ញា UNFCCC ដែលរួមទាំងការធ្វើសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ផងដែរ។កិច្ចការនេះក៏បានប្រមូលផងដែរ នូវទិន្នន័យអំពីការបញ្ចេញឧស្ម័នកាបូនិកពីវិស័យសំខាន់ៗនៅកម្ពុជា រួមមានវិស័យថាមពល កសិកកម្ម ឧស្សាហកម្ម សំណល់ ការប្រែប្រួលលើការប្រើប្រាស់ដីធ្លី និងព្រៃឈើ។ របាយការណ៍នេះក៏នឹងពិនិត្យមើលផងដែរ នូវវិស័យសំខាន់ៗដែលងាយរងគ្រោះ ពោលគឺវិស័យកសិកម្ម ធនធានទឹក សុខភាពមនុស្ស និងតំបន់ឆ្នេរ ហើយព្យាយាមធ្វើអត្តសញ្ញាណវិធានការនានា ដើម្បីកសាងភាពធន់នៅក្នុងវិស័យទាំងនោះទល់នឹងការប្រែប្រួលអាកាសធាតុ។

ក្រុមការងារផ្នែកភាពងាយរងគ្រោះ និងការបន្សាំ (V&A) បានរៀបចំសិក្ខាសាលាមួយ ស្តីពីការវាយតម្លៃ V&A និងបានជ្រើសរើសកម្មវិធីកុំព្យូទ័រមួយចំនួន ដែលសមស្របសម្រាប់កម្ពុជា។ ការអង្កេត V&A ត្រូវបានបង្កើតឡើង និងបានសាកល្បងនៅលើទីតាំងភូមិសាស្ត្រជាក់ស្តែងក្នុងខេត្តព្រៃវែង ដែលស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា ដែលត្រូវបានធ្វើអត្តសញ្ញាណថាងាយរងគ្រោះបំផុតចំពោះព្រឹត្តិការកំណាចនៃអាកាសធាតុ។ កិច្ចការត្រៀមរៀបចំបានបន្តលើកម្មវិធីនានា ដែលផ្សំដោយវិធានការ ដើម្បីជួយកម្ពុជា បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយផលប៉ះពាល់។

## ការបញ្ឈប់ការប្រើប្រាស់សារធាតុត្រជាក់ នឹងកាត់បន្ថយការបំផ្លាញស្រទាប់អូហ្សូន

កម្ពុជាកំពុងធ្វើការដើម្បីកាត់បន្ថយការប្រើប្រាស់ឧស្ម័នក្លរ៉ូហ្លួរូកាបូន (CFCs) ដែលបំផ្លាញស្រទាប់អូហ្សូន ដែលការពារនៅជុំវិញស្រទាប់បរិយាកាសនៃផែនដីយើងនេះ។ នៅកម្ពុជា CFCs ត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងប្រព័ន្ធបង្កក និងម៉ាស៊ីនត្រជាក់។ ក្នុងនាមជាភាគីមួយនៅក្នុងអនុសញ្ញាវីយែន និងពិធីសារម៉ុងរេអាល់ កម្ពុជាបានកាត់បន្ថយការប្រើប្រាស់ឧស្ម័ន CFCs ពីបរិមាណ ៩៤ តោន នៃសក្តានុពលបំផ្លាញស្រទាប់អូហ្សូន (ODP) នៅក្នុងឆ្នាំគោល ២០០២ មកត្រឹម ១២ តោន ODP នៅក្នុងឆ្នាំ ២០០៧។ កម្ពុជាមានការប្តេជ្ញា ដើម្បីលុបបំបាត់ការប្រើប្រាស់ឧស្ម័ន CFCs ថ្មី រហូតដល់ឆ្នាំ ២០១០ និងធានាថា មិនមានការនាំចូលឡើងវិញឡើយ។ ផ្នែកអូហ្សូនជាតិនៅក្នុងក្រសួងបរិស្ថាន កំពុងដោះស្រាយភាពប្រឈមនេះ ក្រោមភាពជាដៃគូជាមួយយូអិនឌីភី កម្មវិធីបរិស្ថានសហប្រជាជាតិ និងមូលនិធិពហុភាគីនៃយូអិនឌីភី។ យុទ្ធសាស្ត្រនានា រាប់បញ្ចូលការបំពាក់បរិក្ខារនៅលើយានយន្ត ដែលមានប្រព័ន្ធម៉ាស៊ីនត្រជាក់ចល័ត ដែលប្រើប្រាស់ឧស្ម័នបំផ្លាញស្រទាប់អូហ្សូន បណ្តុះបណ្តាលជាង សហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីទប់ស្កាត់ការចេញផ្លាកលេខដល់យានយន្តណាដែលមានប្រើប្រាស់ប្រព័ន្ធ CFC-១២ និងធ្វើការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងកាំកុងត្រូល ដើម្បីទប់ស្កាត់ពាណិជ្ជកម្មល្មើសច្បាប់ឆ្លងដែនលើយានយន្តបែបនេះ។

នៅឆ្នាំ ២០០៨ រថយន្តចំនួន ៩៧៤គ្រឿង បានបំពាក់បរិក្ខារថ្មី និងឧស្ម័ន CFC-១២ ប្រមាណ ២,៥៥ តោន ODP ត្រូវបានបូមចេញ និងកែច្នៃសម្រាប់ការប្រើប្រាស់ឡើងវិញ ក្រោមការគាំទ្រពីយូអិនឌីភី។ ផ្នែកអូហ្សូនជាតិ បានធ្វើការបណ្តុះបណ្តាលបំប៉នដល់ជាងចំនួន ៤១ នាក់ មកពីរោងជាងជួសជុលរថយន្តចំនួន ២៣ កន្លែង និងនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗទៀត។ ការរៀបចំនានាបានចាប់ផ្តើមសម្រាប់ការបង្កើតជាសមាគមឧស្សាហកម្មសារធាតុត្រជាក់។

## សកម្មភាពរបស់សហគមន៍សម្រាប់ការរស់នៅប្រសើរជាងមុន ក៏ផ្តល់ប្រយោជន៍ដល់បរិស្ថានផងដែរ

ក្នុងនាមភាពជាដៃគូជាមួយមូលនិធិបរិស្ថានពិភពលោក យូអិនឌីភីគ្រប់គ្រងកម្មវិធីជំនួយខ្នាតតូចពី GEF ដែលផ្តល់ជាមូលនិធិសម្រាប់គម្រោងនៅថ្នាក់សហគមន៍ ដែលធ្វើការដោះស្រាយបញ្ហាសកលលោក ទន្ទឹមនឹងទ្រទ្រង់ការអភិវឌ្ឍដោយចីរភាព។

នៅឆ្នាំ ២០០៨ តាមរយៈទឹកប្រាក់ ៥៧០.០០០ដុល្លា ពីមូលនិធិបរិស្ថានពិភពលោក និង ៥៤០.០០០ដុល្លា មកពីយូអិន-ឌីភី កម្មវិធី GEF-SGP បានផ្តល់មូលនិធិដល់គម្រោងថ្មីៗចំនួន ៣៧ ដោយមានគោលដៅអភិរក្សជីវៈចម្រុះ និងដែនទឹកអន្តរជាតិ កាត់បន្ថយការប្រែប្រួលអាកាសធាតុ និងបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងទប់ស្កាត់ដីខ្សោះជីជាតិ។ កម្មវិធីនេះបានបង្កើនថវិកាបដិភាគរបស់ខ្លួនជាមួយម្ចាស់ជំនួយខ្នាតតូចដទៃផ្សេងទៀត ដែលរួមទាំងអង្គការរុក្ខជាតិ និងសត្វអន្តរជាតិ និងអង្គការអុកស្វាមអង់គ្លេសផងដែរ។

ដើម្បីអភិវឌ្ឍន៍មូលធនមនុស្ស សមាគមកសិករថ្មីចំនួន ២៦ នៅមូលដ្ឋាន បានរួមគ្នាដើម្បីបង្កើតជាបណ្តាញជាតិកសិករ ហើយក្រុមជួយខ្លួនឯងថ្មីចំនួន ៦៥ នៅកម្រិតភូមិ ក៏ត្រូវបានបង្កើតឡើងផងដែរ។

គម្រោងទាំងនេះ មានគោលដៅលើកកំពស់ការប្រើប្រាស់ធនធានដោយនិរន្តរភាព ទន្ទឹមនឹងការកែលម្អរបរចិញ្ចឹមជីវិត

ជាពិសេស សម្រាប់ប្រជាជន ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ និងទីកន្លែងសំបូរជីវៈចម្រុះ ។ កិច្ចផ្តួចផ្តើមដែលរាប់បញ្ចូលចាប់ពីការអភិរក្សបឹងធម្មជាតិនានា និងសហគមន៍នេសាទ រហូតដល់ការដាំដើមឈើ និងសហគមន៍ព្រៃឈើ ។ ជំនាញសិប្បកម្មដែលមិនបំផ្លាញបរិស្ថានដែលកំពុងស្ថិតក្នុងគ្រោះថ្នាក់នៃការបាត់បង់ទៅនោះ ក៏ត្រូវបានថែរក្សាផងដែរ ។

នៅក្រោមគម្រោងអភិរក្សដែនទឹកអន្តរជាតិ ដែលមានទំនាក់ទំនងជាមួយគម្រោងសមុទ្រចិនខាងត្បូង ថ្នាក់តំបន់ អង្គការសហគមន៍ចំនួនពីរនៅក្នុងខេត្តកំពត បានដាំដើមកោងកាងលើផ្ទៃដីទំហំ ៤០ ហិកតា និងអភិរក្សព្រៃកោងកាងដែលមានស្រាប់ទំហំ ២០០ ហិកតា និងវាលស្មៅសមុទ្រទំហំ ៤០ ហិកតា ។ សមាជិកគណៈកម្មការសហគមន៍នេសាទច្រើនជាង ៧០០ នាក់ បានចូលរួមនៅក្នុងការងារនេះ ដោយអភិវឌ្ឍន៍ជំនាញ និងភាពជាអ្នកដឹកនាំ ក៏ដូចជាចំណេះដឹងបច្ចេកទេសនៃការអភិរក្សកោងកាងផងដែរ ។

ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ បានផ្តោតលើការកាត់បន្ថយការបង្ហុយឧស្ម័នផ្ទះកញ្ចក់ តាមរយៈការជួយសហគមន៍ក្នុងការទទួលយកបច្ចេកវិទ្យានានា សម្រាប់ប្រសិទ្ធិភាពថាមពល និងថាមពលកកើតឡើងវិញ ។ បច្ចេកវិទ្យាទាំងនោះ រាប់បញ្ចូលឡជីវឧស្ម័នចំនួន ២០០ សម្រាប់បម្លែងលាមកសត្វទៅជាឧស្ម័ន និងចង្ក្រានដាំស្ល ដែលមានប្រសិទ្ធិភាពចំនួន ២.៨៨៦ ។ ស្ថានីយ៍បញ្ចូលអាគុយចំនួនបួនកន្លែង ដែលប្រើប្រាស់បន្ទះទទួលពន្លឺព្រះអាទិត្យជំនួសម៉ាស៊ីនភ្លើង និងស្ថានីយ៍ថាមពលខ្យល់ចំនួនប្រាំបីសម្រាប់បូមទឹកត្រូវបានតម្លើងផងដែរ ។ដើម្បីបន្ថយសម្ពាធមកលើព្រៃឈើធម្មជាតិ ដើមឈើពូជ ដែលដុះលូតលាស់រហ័សចំនួន ៩០.០០០ ដើម ត្រូវបានដាំសម្រាប់ផលិតជាអុស ។

ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ បានផ្តោតលើកម្មវិធីទឹកសម្រាប់ជីវិត និងទឹកសម្រាប់របរចិញ្ចឹមជីវិត ដែលគ្របដណ្តប់គ្រួសារចំនួន ៤៧.៨៦០ នៅក្នុងភូមិចំនួន ២៤៧ ក្នុងខេត្តចំនួន ១៤ ។ ធុងសេរ៉ាមិកសម្រាប់ច្រោះទឹកចំនួន ១០.៩២៨ គ្រឿង ត្រូវបានចែកចាយ ជាពិសេសដល់គ្រួសារដែលរស់នៅជុំវិញបឹងទន្លេសាប ។ ប្រព័ន្ធត្រងទឹកភ្លៀងចំនួន ១៨៥០ គ្រឿង ត្រូវបានតម្លើង ហើយបឹងធម្មជាតិចំនួន ៨ អណ្តូងចំនួន ២៩៣ ស្រះ និងអាងទឹកចំនួន ៣០ ប្រឡាយ ឬស្នាមភ្លោះសម្រាប់ការស្រោចស្រពចំនួន ៥ ខ្សែ ត្រូវបានកសាង និងស្តារឡើងវិញ ។

ដើម្បីប្រយុទ្ធប្រឆាំងនឹងដីខ្សោះជីជាតិ កសិករបានទទួលការលើកទឹកចិត្តឱ្យប្រើប្រាស់បច្ចេកទេសដាំដំណាំជាច្រើនបែប ដែលរួមទាំងប្រព័ន្ធប្រពលវប្បកម្មស្រូវ តាមគោលការណ៍ធម្មជាតិដែលជាបច្ចេកទេសស្ទូងស្រូវមួយដើម និងទទួលទិន្នផលខ្ពស់ជាងមុន បច្ចេកទេសកសិកម្មសរីរាង្គ ដូចជា ស្រះចិញ្ចឹមត្រី និងសួនបន្លែ ។ ដើមឈើចំនួនច្រើនជាង ៨.០០០ ដើម ត្រូវបានដាំ ហើយបច្ចេកទេសចម្រុះគ្រប់គ្រងដំណាំ ការធ្វើជីកំប៉ុសដែលផ្សំដោយលាមកសត្វ និងសំណល់បែតង ការស្រោចស្រពដោយតំណក់ទឹក និងកសិក-រុក្ខកម្ម ក៏ត្រូវបានលើកទឹកចិត្តផងដែរ ។



រូបភាព: យូអិនឌីភី/អ៊ីសាបែល លេសេរ

ផលស្តុកត្រីដែលអាចទុកចិត្តបាននាំឱ្យមានការពង្រឹងសន្តិសុខស្បៀង និងកំណើនប្រាក់ចំណូលប្រចាំគ្រួសារ

## បឹងសហគមន៍ ជួយសង្គ្រោះជីវិតប្រជាពលរដ្ឋនៅក្នុងភូមិមួយ

*វាលស្រែបៃតងខ្ចី និងស្រះឈូក ដែលព័ទ្ធជុំវិញភូមិពាមជ្រៃ បង្ហាញថា ការរស់នៅមានភាពងាយស្រួល និងសំបូរបែប ប៉ុន្តែតំបន់ទេសភាពដ៏ស្រស់ត្រកាលបែបនេះ គ្របដណ្តប់ពីលើភាពពិតប្រកបដោយការលំបាក ។ នេះជាផ្ទៃដីដែលរហូតមកដល់ប៉ុន្មានឆ្នាំមុននេះ ប្រជាពលរដ្ឋរស់នៅដោយភ័យខ្លាចនឹងភាពអត់ឃ្លានជារៀងរាល់ថ្ងៃ ។*

*នៅលើកោះនេះក្នុងដងទន្លេសាប ក្នុងខេត្តកំពង់ឆ្នាំង ប្រជាជនពឹងផ្អែកជាខ្លាំងលើបឹងទាំងនេះ និងផលត្រីជាច្រើនដែលពីមុនពួកគាត់ធ្លាប់នេសាទបាន ។ប៉ុន្តែមកដល់ឆ្នាំ២០០៦ ការនេសាទច្រើនហួសកម្រិតបានធ្វើឱ្យផលស្តុកត្រីនៅក្នុងបឹងទាំងនេះស្ទើរតែបាត់បង់ទាំងស្រុង ហើយគ្រួសារដែលអស់សង្ឃឹមទាំងនេះត្រូវបង្ខំចិត្តធ្វើនេសាទដោយប្រើខ្សែភ្លើងឆក់ដែលបំពាក់ដោយអាគុយ ។*

*អ្នកស្រី ផាន សារុធ អាយុ ៥១ឆ្នាំ បានរំលឹកថា "យើងមានការភ័យខ្លាចខ្លាំងណាស់អំពីការបាត់បង់របរចិញ្ចឹមជីវិត ។ ជួនកាលខ្ញុំសំដែងការព្រួយបារម្ភទៅអ្នកភូមិដទៃទៀត ដែលបាននេសាទកូនត្រី ប៉ុន្តែខ្ញុំទទួលបានការចំអក និងជេរ ពីពួកគេមកវិញ" ។*

*ឥឡូវនេះ ត្រីវិលត្រឡប់មកវិញហើយ ។ ជារៀងរាល់ថ្ងៃ អ្នកខ្លះស្ទូចបានត្រីមួយដែលមានទំហំរហូតដល់ ៧-៨ គ.ក ហើយអ្នកណាដែលចង់បានខ្លាំង ក៏អាចនេសាទរហូតដល់ ២០ គ.ក ក្នុងមួយថ្ងៃ ។ នៅរដូវប្រាំង អ្នកមានជំនាញនេសាទស្ទើរតែអាចចាប់ត្រីបានដោយដៃទទេ ។*

*ចំណុចផ្លាស់ប្តូរ បានមកដល់នៅពេលដែលអ្នកភូមិបានបង្កើតឱ្យមានគណៈកម្មការសហគមន៍នេសាទ និងបានបង្កើតតំបន់អភិរក្សនៅក្នុងបឹងក្រចាប់ តាមរយៈជំនួយ ៥.០០០ដុល្លា ពីកម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក និងការណែនាំពី NGO មួយនៅមូលដ្ឋានដែលមានឈ្មោះថា អង្គការអភិវឌ្ឍន៍សមត្ថភាពសហគមន៍ ។*

*ពួកគេបានរាំងព្រួលជុំវិញផ្ទៃទឹក ៣,៤ ហិកតា ដែលជាចំណែកមួយនៃបឹង ទាំងមូលដែលមានទំហំ ៧ ហ.ត ដោយមានសង់ប៉ុស្តិ៍ និងរបងលួសបន្លា និងបានពន្លិចលូបេតុងចំនួន ៣៥ កំណាត់ សម្រាប់ជាជម្រកត្រីពង ។ អ្នកស្ម័គ្រចិត្តបានធ្វើការល្បាតជុំវិញបឹងនេះ ដើម្បីទប់ស្កាត់ពីការប៉ុនប៉ងចូលលួចនេសាទបំពុល ឬកាត់ឈើក្នុងព្រៃលិចទឹក ។*

*ប្រាក់ចំណូលបន្ថែម ត្រូវបានបង្វិលទៅក្រុមជួយខ្លួនឯង និងក្រុមសន្សំប្រាក់ ដែលធ្វើឱ្យគ្រួសារនានាអាចទិញស្រូវ ជី និងប្រេងសម្រាប់បូមទឹកស្រោចស្រព ។*

*អ្នកស្រី ចាន់ ធី អាយុ ៤៣ ឆ្នាំ ដែលជាអ្នករក្សាសៀវភៅកំណត់ត្រារបស់ សហគមន៍ពោលថា "ឥឡូវនេះ យើងមានការបារម្ភតិចជាងមុនអំពីភាពអត់ឃ្លាន ដោយសារគ្រួសារនានាអាចរកប្រាក់បាន-ច្រើនជាងមុន ។ ជាលទ្ធផល ពួកគេមានអំពើហឹង្សាក្នុងគ្រួសារតិចជាងមុន ។*

# ធ្វើការជាមួយគ្នា


*រូបភាព: យូអិនឌីភី/ណេថាន់ ហ័រតុន*

*ដំរីឈ្មោះសំបូរ និងហ្មរបស់វា នៅវត្តភ្នំ ក្នុងក្រុងភ្នំពេញ កំពុងអានដោយយកចិត្តទុកដាក់នូវក្រដាសយុទ្ធនាការហាមឃាត់ការប្រើប្រាស់គ្រាប់បែកចង្កោម ។*

## ភាពជាដៃគូប្រើស្មារតីសហការ ដើម្បីសម្រេចបាននូវចក្ខុវិស័យរួម

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ គឺជាបណ្ដាញអភិវឌ្ឍន៍ពិភពលោកនៃអង្គការសហប្រជាជាតិ ដែលជាអង្គការមួយធ្វើការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្ដូរ និងតភ្ជាប់ប្រទេសនានាទៅនឹងចំណេះដឹង បទពិសោធន៍ និងធនធាន ដើម្បីប្រជាពលរដ្ឋកសាងការរស់នៅមួយប្រសើរជាងមុន ។ យើងធ្វើការនៅក្នុងប្រទេសចំនួន ១៦៦ ដោយជួយប្រទេសទាំងនោះទាក់ទាញ និងប្រើប្រាស់ជំនួយឱ្យមានប្រសិទ្ធិភាព និងគាំទ្រពួកគេ ក្នុងការស្វែងរកដំណោះស្រាយរបស់ខ្លួន ចំពោះការប្រឈមនៃការអភិវឌ្ឍន៍នៅកម្រិតពិភពលោក និងនៅថ្នាក់ជាតិ ។

អង្គការយូអិនឌីភីនៅកម្ពុជា ធ្វើការតាមរយៈភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល អង្គការសហគមន៍ ក្រុមហ៊ុនឯកជន ទីភ្នាក់ងារផ្ដល់ជំនួយពហុភាគី និងម្ចាស់ជំនួយទ្វេភាគី ។ ភាពជាដៃគូជាមួយ DFID, SIDA, សហភាពអឺរ៉ុប អូស្ត្រាលី កាណាដា មូលនិធិបរិស្ថានពិភពលោក ក្នុងចំណោមដៃគូដទៃទៀត មានសារៈសំខាន់ណាស់ក្នុងការទទួលបានសមិទ្ធផលនៅក្នុងឆ្នាំ ២០០៨នេះ ។

នៅថ្នាក់ជាតិ យូអិនឌីភី ធ្វើការជាមួយសភា ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងកិច្ចការនារី ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ។ នៅថ្នាក់ក្រោមជាតិ យូអិនឌីភី បានធ្វើការជាមួយខុទ្ទកាល័យអភិបាលខេត្តនានា មន្ទីរនានាចំណុះក្រសួងនៅថ្នាក់ជាតិ គណៈកម្មការប្រតិបត្តិខេត្ត ។

យូអិនឌីភី បានធ្វើការជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោត និងគណៈកម្មការនេះនៅថ្នាក់ខេត្ត និងឃុំ ។ សមាភាគីដ៏សំខាន់ផ្សេងទៀតនៅថ្នាក់ជាតិ រួមមាន ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាជ្ញាធរប្រេងកាតជាតិកម្ពុជា អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនរងគ្រោះដោយសារមីន មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា ស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ។

ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល មានសារៈសំខាន់ណាស់ក្នុងការសម្រេចបានគោលដៅរបស់ យូអិនឌីភី នៅឆ្នាំ ២០០៨ ។ នៅក្នុងការគាំទ្រដល់ការបោះឆ្នោតដោយគ្មានអំពើហឹង្សា និងសម្រាប់ទាំងអស់គ្នា យូអិនឌីភី បានធ្វើការជាមួយវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការអព្យាក្រឹត្យ និងមិនលំអៀង ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា វិទ្យាស្ថានជាតិប្រជាធិបតេយ្យ អង្គការជនពិការកម្ពុជា គណៈកម្មការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងគណៈកម្មាធិការ ដើម្បីលើកកំពស់ស្ត្រីនៅក្នុងនយោបាយ ។ នៅក្នុងការគាំទ្រឱ្យមានការពង្រឹងសិទ្ធិទទួលបានយុត្តិធម៌ យូអិនឌីភី ធ្វើការជាមួយមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ។ នៅក្នុងវិស័យបរិស្ថាន យូអិនឌីភី បានធ្វើការជាមួយសមាគមអភិរក្សសត្វព្រៃ ដែលជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ។ យូអិនឌីភី បានគ្រប់គ្រងមូលនិធិមកពីស្ថាប័នមូលនិធិបរិស្ថានពិភពលោក ដែលបានប្រើប្រាស់នៅក្នុងកម្មវិធីជំនួយខ្នាតតូចនៃកិច្ចផ្ដួចផ្ដើមបរិស្ថាននៅថ្នាក់សហគមន៍ ។ អង្គការយូអិនឌីភី បានធ្វើការជាមួយអង្គការវេទិកាអង្គការមិនមែនរដ្ឋាភិបាលនៃកម្ពុជា ដើម្បីធ្វើអត្តសញ្ញាណភ្នាក់ងារដែលមានសក្ដានុពលជាអ្នកទទួលជំនួយ និងជាមួយអង្គការមិនមែនរដ្ឋាភិបាលជាច្រើននៅក្នុងស្រុក ដើម្បីអនុវត្តគម្រោង ។

## យូអិនឌីភី គ្រប់គ្រងមូលនិធិសម្រាប់ភាគីកម្ពុជា នៅក្នុងសាលាក្ដីខ្មែរក្រហម

យូអិនឌីភី គ្រប់គ្រងមូលនិធិ ដែលបានផ្ដល់ទៅឱ្យភាគីកម្ពុជាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC) ។ អង្គជំនុំជម្រះនេះ ត្រូវបានបង្កើតឡើង ដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់នៃអតីតរបបខ្មែរក្រហម មកកាត់ក្ដីអំពីការកាប់សម្លាប់ដ៏ឃោរឃៅ ដែលបានប្រព្រឹត្តនៅរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ។ តុលាការនេះ មានផ្នែកពីរជាសំខាន់ គឺភាគីអង្គការសហប្រជាជាតិ និងភាគីជាតិកម្ពុជា ។ ភាគីនីមួយៗ មានមូលនិធិដាច់ដោយឡែកពីគ្នា ។

នៅខែ មិថុនា ឆ្នាំ ២០០៦ យូអិនឌីភី បានបង្កើតគម្រោងពិសេសមួយ ដើម្បីគ្រប់គ្រងមូលនិធិនានាដែលផ្ដល់ឱ្យភាគីរដ្ឋាភិបាលកម្ពុជាសម្រាប់តុលាការនេះ ពីសំណាក់នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ ។ នោះ គឺជាមូលនិធិដែលនៅសល់ពីបេសកកម្មនៃអាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ដែលនៅក្នុងឆ្នាំ ១៩៩៣ បានចាត់ចែងឱ្យមានការបោះឆ្នោតតាមបែបប្រជាធិបតេយ្យជាលើកដំបូងនៅក្នុង

ប្រទេសនេះ។ ម្ចាស់ជំនួយដទៃទៀត ដែលរួមមានគណៈកម្មការសហគមន៍អឺរ៉ុប បារាំង និងអូស្ត្រាលី បានរួមចំណែកជាមូលនិធិទៅភាគីជាតិកម្ពុជានៃតុលាការនេះ តាមរយៈគម្រោងគ្រប់គ្រងដោយយូអិនឌីភី។

## អ្នកស្ម័គ្រចិត្តចែករម្លែកថាមពលរបស់ពួកគេ និងទទួលបានបទពិសោធន៍ដ៏មានតម្លៃ

អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ (UNV) ធ្វើការតស៊ូមតិដើម្បីឱ្យមានភាពជាអ្នកស្ម័គ្រចិត្ត ដាក់បញ្ចូលភាពស្ម័គ្រចិត្តទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកៀងគរអ្នកស្ម័គ្រចិត្ត ដើម្បីគាំទ្រឱ្យមានសន្តិភាព និងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍នៅទូទាំងពិភពលោក។ UNV បានចាប់ផ្តើមធ្វើការនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ១៩៩២ ហើយចាប់តាំងពីពេលនោះមក មានជនស្ម័គ្រចិត្តច្រើនជាង ១២០០ នាក់ បានចូលបម្រើការជាមួយទីភ្នាក់ងារ អង្គការសហប្រជាជាតិស្ទើរទាំងអស់ និងទីភ្នាក់ងាររបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន។ ចាប់ពីឆ្នាំ ២០០៦ មក UNV បានគាំទ្រដល់អង្គការអ្នកស្ម័គ្រចិត្តជាតិនៅក្នុងការបង្កើតអ្នកស្ម័គ្រចិត្តក្នុងស្រុកសម្រាប់កិច្ចផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន នៅក្នុងខេត្តក្រីក្រជាងគេខ្លះ។ នៃប្រទេសកម្ពុជា។

នៅឆ្នាំ ២០០៨ ជនស្ម័គ្រចិត្តអន្តរជាតិចំនួន ៣៤ នាក់ និងជនស្ម័គ្រចិត្តជាតិចំនួន ១៣ នាក់ នៃអង្គការសហប្រជាជាតិបានធ្វើការនៅកម្ពុជាលើវិស័យច្រើនជាង ២៥ ដែលរាប់ចាប់ពីមេរោគអេដស៍/ជម្ងឺអេដស៍ គោលនយោបាយពាណិជ្ជកម្មនិងការបោះឆ្នោត រហូតដល់ការបោសសំអាតគ្រាប់មីន ការផ្តល់សិទ្ធិអំណាចដល់យុវជន និង ICT សម្រាប់ការអប់រំ។ ប្រមាណ ៦០ភាគរយ នៃជនស្ម័គ្រចិត្តបានធ្វើការនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ៣៥ភាគរយនៅក្នុងរដ្ឋាភិបាល និងអ្នកដែលនៅសល់ធ្វើការនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលនិងគ្រឹះស្ថានសិក្សា និងវិស័យឯកជន។ ជនកម្ពុជាចំនួន ៩ នាក់ នៅក្នុងបេសកកម្មផ្សេងទៀតនៃការរក្សាសន្តិភាព និងអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនៅអាហ្វ្រិក និងកន្លែងផ្សេងទៀតនៅអាស៊ី។ យូអិនឌីភី ក៏បានទទួលអ្នកស្ម័គ្រចិត្តចំនួន ៥ រូប ធ្វើការនៅក្រោមឯកអគ្គរដ្ឋទូតយុវជនអូស្ត្រាលី ដើម្បីបណ្តាញអភិវឌ្ឍន៍ផងដែរ ក៏ដូចជាកម្មសិក្សាការីជាតិ ចំនួន ៤៦ នាក់ និងកម្មសិក្សាការីអន្តរជាតិចំនួន ១២ នាក់ ផងដែរ។

យូអិនឌីភី បន្តគាំទ្រដល់គម្រោងអភិរក្សបឹងទន្លេសាបនៃ UNDP/GEF/ក្រសួងបរិស្ថាន តាមរយៈការផ្តល់អ្នកស្ម័គ្រចិត្តជាតិអង្គការសហប្រជាជាតិ ដែលធ្វើការនៅក្នុងកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍សហគមន៍នៅក្នុងភូមិនានានៃបរិយាជីវមណ្ឌលបឹងទន្លេសាប។ គម្រោងនេះ ដែលបានទទួលការគាំទ្រពីមូលនិធិត្រាស់នៃប្រទេសជប៉ុន បានធ្វើឱ្យអ្នកស្ម័គ្រចិត្តជាតិនៃអង្គការសហប្រជាជាតិធ្វើការដោយផ្ទាល់ជាមួយគ្រួសារនានា និងក្រុមសន្សំប្រាក់នៅមូលដ្ឋានដោយផ្តល់ការបណ្តុះបណ្តាល និងបច្ចេកទេស ដើម្បីលើកទឹកចិត្តឱ្យមានសកម្មភាពនៃការចិញ្ចឹមជីវិតនៅជនបទ ដែលមិនបំផ្លាញបរិស្ថាន។

UNV គឺជាសមាជិកសកម្មនៃ VolCam ដែលជាបណ្តាញមួយនៃទីភ្នាក់ងារអ្នកស្ម័គ្រចិត្តដែលប្រតិបត្តិការនៅកម្ពុជា។

នៅទិវាអ្នកស្ម័គ្រចិត្តអន្តរជាតិ បណ្តាញនេះបានចាត់ចែងឱ្យមានពិពណ៌អ្នកស្ម័គ្រចិត្ត ដែលមានការចែកផ្សាយសម្ភារៈ


រូបភាព: យូអិនឌីភី/នីសាន់ បេសហាវ៉ាទី

ផ្សព្វផ្សាយនានាជាភាសាអង់គ្លេស និងភាសាខ្មែរ។ UNV បានសហការជាមួយអង្គការយុវជនស្តារកម្ពុជា ដើម្បីគាំទ្រ និងបោះពុម្ពផ្សាយគម្រោងស្រាវជ្រាវ ឈ្មោះ ភាពស្ម័គ្រចិត្ត : ពង្រឹងសក្តានុពលដើម្បីអភិវឌ្ឍន៍កម្ពុជា។ ការសិក្សានេះបានរកឃើញថា មានភាពសំបូរបែបនៃការស្ម័គ្រចិត្តនៅក្នុងប្រទេសកម្ពុជា បើទោះជានៅពុំទាន់មានការទទួលស្គាល់នៅឡើយក៏ដោយ និងបានអះអាងថាភាពជាអ្នកស្ម័គ្រចិត្តមានសក្តានុពល ដើម្បីរួមចំណែកយ៉ាងច្រើនទៅក្នុងការកែលម្អការចិញ្ចឹមជីវិត និងសម្រេចបានគោលដៅអភិវឌ្ឍន៍សហប្រជាជាតិ។ សព្វថ្ងៃនេះ UNV កំពុងធ្វើការជាមួយដៃគូនានា ដើម្បីអភិវឌ្ឍន៍បរិស្ថានមួយ ដែលនឹងអាចធ្វើឱ្យភាពស្ម័គ្រចិត្តរីកលូតលាស់ ដែលជាការតស៊ូមតិ ដើម្បីឱ្យមានគោលនយោបាយ និងការគាំទ្រពីរដ្ឋាភិបាល និងពីវិស័យឯកជនផងដែរ។

កញ្ញា អាឡិក្ស ហ៊ីនីគ័រ មន្ត្រីទំនាក់ទំនង និងតស៊ូមតិនៃយូអិនឌីភី នៅក្នុងគម្រោងដោះមីនរបស់កម្ពុជា បានពោលថា នាងសម្រេចចិត្តធ្វើការជាអ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ដោយសារនាងចង់ប្រើប្រាស់ជំនាញរបស់នាង សម្រាប់បុព្វហេតុដែលមានប្រយោជន៍។ នាងបានពោលថា "មុនដំបូង ខ្ញុំមិនរំពឹងរៀនបានច្រើនប៉ុន្មានទេ នៅក្នុងដំណើរការនេះ"។

"ផ្នែកដែលខ្ញុំចូលចិត្តអំពីការងាររបស់ខ្ញុំ គឺការធ្វើដំណើរទៅខេត្តនានា ដើម្បីនិយាយជាមួយប្រជាពលរដ្ឋដែលទទួលផលពីការងាររបស់យើង។ បន្ថែមលើការរៀនសូត្រអំពីកម្ពុជាតាមរយៈសកម្មភាពនៃវិជ្ជាជីវៈរបស់ខ្ញុំ ការរស់នៅទីនេះបានផ្តល់ឱ្យខ្ញុំនូវការយល់ឃើញយ៉ាងច្រើន អំពីការលំបាកដែលកម្ពុជាប្រឈម និងចំណុចខ្លាំងរបស់ប្រជាជន ដែលធ្វើការដើម្បីជំនះការលំបាកទាំងនោះ។ ខ្ញុំក៏បានរៀនសូត្រជាច្រើនផងដែរ ពីអ្នកស្ម័គ្រចិត្តជាសហសេវិករបស់ខ្ញុំ ដែលមកពីប្រទេសនានានៅជុំវិញពិភពលោកនៅក្នុងវិស័យការងារជាច្រើន"។

*នៅឆ្នាំ ២០០៨ អ្នកស្ម័គ្រចិត្ត ៤៧ នាក់ នៃអង្គការសហប្រជាជាតិ បានបំរើការនៅក្នុងភ្នាក់ងារអង្គការសហប្រជាជាតិ រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ និងផ្នែកឯកជន។*

# ម្ចាស់ជំនួយ

| | |
|---|---|
| យូអិនឌីភី (មូលនិធិស្នូល) | ៧.៩៤៥.៨៥៨,២៧ |
| SIDA-ស៊ុយអែដ | ៦.២០៤.៥៩០,១៩ |
| DFID-ចក្រភពអង់គ្លេស | ៥.៣០៨.៣៤២,០៨ |
| CIDA- កាណាដា | ៣.៥៤៤.៩៩៦,០១ |
| គណៈកម្មការសហគមន៍អឺរ៉ុប | ៣.០០៣.៩០១,៥៣ |
| AusAID-អូស្ត្រាលី | ២.៧០៦.៣៨៣,៤១ |
| ទីភ្នាក់ងារប្រទេសអេស្ប៉ាញ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ | ២.៣៦៦.៤៧៦,១៦ |
| មូលនិធិបរិស្ថានពិភពលោក | ១.១១៦.១៦៨,៤២ |
| នូវ៉ែលហ្សេឡង់ | ២៩២.៣៣៦,៧៨ |
| ន័រវែស | ២៦០.៩៨៧,៤៦ |
| សមាគម UN នៃស.រ.អា | ១៨៩.១៣៨,៣៧ |
| ពិធីសារម៉ុងរេអាល់ | ១៥៧.៧៤០,៦៧ |
| អៀរឡង់ | ១២២.២៨៨,៣២ |
| DANIDA-ដាណឺម៉ាក់ | ១១៧,២៩៣ |
| **សរុប** | **៣២.៩៣៦.៥០១,១១** |

# ការចំណាយ




# គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា




១. លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ

២. សម្រេចការអប់រំជាសកលនៅកម្រិតបឋមសិក្សា

៣. លើកកំពស់សមភាពខាងយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

៤. កាត់បន្ថយមរណៈភាពកុមារ

៥. លើកកំពស់សុខភាពមាតា

៦. ប្រយុទ្ធប្រឆាំងមេរោគអេដស៍/ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺផ្សេងទៀត

៧. ធានានិរន្តរភាពបរិស្ថាន

៨. បង្កើតភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍ

៩. បោសសម្អាតមីន យុទ្ធភ័ណមិនទាន់ផ្ទុះ និងជួយជនរងគ្រោះ

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| Camcontrol | នាយកដ្ឋានត្រួតពិនិត្យការនាំចូលនាំចេញ និងប្រឆាំងការក្លែងបន្លំនៃកម្ពុជា |
| CCCO | ការិយាល័យប្រែប្រួលអាកាសធាតុនៃកម្ពុជា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CRDB | ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កម្ពុជា |
| CMAA | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនរងគ្រោះដោយសារមីន |
| CMAC | មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា |
| CNMC | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| DFID | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ – ចក្រភពអង់គ្លេស |
| EC | គណៈកម្មការសហគមន៍អឺរ៉ុប |
| EU | សហភាពអឺរ៉ុប |
| GDP | ផលទុនក្នុងស្រុកសរុប |
| GEF | មូលនិធិបរិស្ថានពិភពលោក |
| GTZ | ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហការបច្ចេកទេស |
| ILO | អង្គការពលកម្មអន្តរជាតិ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NEC | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| Organic Law | ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| PEC | គណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោត |
| CEC | គណៈកម្មាធិការឃុំរៀបចំការបោះឆ្នោត |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SLM | ការគ្រប់គ្រងដីធ្លីដោយនិរន្តរភាព |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ |
| Trade SWAp | អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម |
| UNCTAD | សន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ |
| UNIDO | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFPA | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UNV | អង្គការអ្នកស្ម័គ្រចិត្តសហប្រជាជាតិ |
| WCS | សមាគមអភិរក្សសត្វព្រៃ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ សហប្រជាជាតិ |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |



*រូបភាព: WCS/អេលេន័រ ប្រ៊ីកស៏*

*កុមារនៅក្នុងសាលារៀនក្នុងភូមិមួយជិតតំបន់ការពារធម្មជាតិនៅខ្ពង់រាបខាងជើង ទទួលបានការអប់រំ អំពីតម្លៃនៃកិច្ចការពារបរិស្ថានប្លែកពីគេរបស់ខ្លួន។*




ឆ្មាំនៅដែនជម្រកសត្វស្លាបព្រែកទ័ល កំពុងល្បាតតំបន់ការពារធម្មជាតិ នៅលើបឹងទន្លេសាប ដែលជាផ្លូវទឹកសាបធំជាងគេនៃប្រទេសកម្ពុជា

Design by Graphic Roots - www.graphicroots.com.kh

UNDP Cambodia


**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

អាគារលេខ ៥៣ វិថីប៉ាស្ទ័រ សង្កាត់បឹងកេងកង
ប្រអប់សំបុត្រលេខ ៨៧៧ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៨៥៥ (0)២៣ ២១៦ ១៦៧ / ២១៤ ៣៧១
ទូរសារ : ៨៥៥ (0)២៣ ២១៦ ២៥៧ / ៧២១ 0៤២
អ៊ីម៉ែល: registry.kh@undp.org
http://www.un.org.kh/undp